ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jun-2015, 14:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៩២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក ហ្វីលីព រ៉ូជឺ *(Mr. PHLLIPS Roger)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក សេង លាង

លោក ដេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេប្រា ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ស៊ូ សឿន (2-TCW-887) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោកស្រី ស៊ូ សឿន** (2-TCW-887)

សួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................ទំព័រ ១៣
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................ទំព័រ ២១
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........................................ទំព័រ ៤៦
សួរដោយលោក គង់ សំអុន ផ្ដើមពី ........................................ទំព័រ ៦០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ូ សឿន បញ្ចប់ ហើយនិងមុនពេលចាប់ផ្តើមដំណើរការដោយសារក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅ មេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសបង្ហាញនូវ -- ធ្វើសារណាជាផ្ទាល់មាត់ពាក់ព័ន្ធនឹងបញ្ហាការដាក់ឯកសាររបស់សហព្រះរាជាអាជ្ញារងអន្តរជាតិ កាលពីព្រឹកម្សិលមិញ ហើយនិងបញ្ហាមួយចំនួនទៀតពាក់ព័ន្ធនឹងបញ្ហានេះ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងហ្នឹងសាលក្រម ០០២/០១។

លោក ឯម ហាយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទលោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវផ្តល់ -- មកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ស៊ូ សឿន។ លោកស្រីមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព

ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។ មេធាវីការពារក្ដីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបៗខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺខ្នង ឈឺចង្កេះរ៉ាំរ៉ៃ មិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងតាមបញ្ញត្តិនៃមាត្រា -- នៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:១០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ អង្គជំនុំជម្រះ ក៏សូមជម្រាបជូនផងដែរថា នៅក្នុងការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មសាក្សីនៅថ្ងៃនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ លោកចៅក្រម យូរ ឧត្ដរា ដែលជាចៅក្រមជាតិអវត្តមានដោយមូលហេតុគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន បន្ទាប់ពីយើងបានពិគ្រោះ ពិភាក្សាជាមួយនឹងបណ្ដាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្ដរា ដែលអវត្តមាន រហូតដល់ពេលចៅក្រម យូរ ឧត្ដរា មានវត្តមាន និងអាចមានលទ្ធភាពបំពេញការងារនៅក្នុងកិច្ចដំណើរការសវនាការ

នៅអង្គជំនុំជម្រះវិញបាន។ ការសម្រេចនេះផ្អែកតាមបទបញ្ញត្តិវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

[០៩:០៧:២៥]

បាទ តើលោក -- ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីឡើងធ្វើសារណាពាក់ព័ន្ធអំពីបញ្ហាដែលលោកស្នើសុំកាលពីម្សិលមិញ សុំធ្វើសារណាផ្ទាល់មាត់ពាក់ព័ន្ធជាមួយនឹងរបៀបនៃការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ និងបញ្ហាដូចគ្នាពាក់ព័ន្ធនឹងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម ០០១ -- ០០២/០១ កន្លងមក។

សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់។ កាលពីពីរថ្ងៃមុន យើងទទួលបានការជូនដំណឹងពីសហព្រះរាជអាជ្ញាអន្តរជាតិ អំពីការបង្ហាញឯកសារបន្ថែមទៀតគឺចម្លើយ -- ការស្តាប់ចម្លើយក្នុងសំណុំរឿង០០៣។ ខ្ញុំគិតថាវាជាការចាំបាច់ក្នុងការជម្រាបជូនដល់អង្គជំនុំជម្រះឲ្យបានជ្រាបថា រហូតមកដល់ពេលនេះយើងបានទទួលបានកំណត់ហេតុស្តាប់ចម្លើយ៤៣៦ មកពីសំណុំរឿង០០៣, ០០៤។ គឺកើនបន្ថែមចំនួនទំព័រ ៦៣៩៧ បន្ថែមពីលើអ្វីដែលមានពីមុនមក។ យើងដឹងថាឯកសារដែលបង្ហាញមកថ្មីនេះ គឺមកពីសំណុំរឿង០០៣ គឺមានចំនួនរាប់ពាន់ទំព័រមកពីកំណត់ហេតុស្តាប់ចម្លើយដែលមានចំនួន៨៩។ ដូច្នេះ ជាសរុបមកខ្ញុំគិតថា ចំនួនទំព័រទាំងអស់គឺមានប្រហែលជា ៧៤០០ ទំព័រ ដូច្នេះឥឡូវនេះ យើងត្រូវប្រឈមជាមួយនឹងភស្តុតាងដែលមានទំហំយ៉ាងធំដែលទទួលបានពីសំណុំរឿង ០០៣, ០០៤។ ទោះបីថាយើងមិនទាន់បានទទួលឯកសារហ្នឹងដោយផ្ទាល់ក៏ដោយ ប៉ុន្តែយើងក៏អាចប្រមើលមើលអំពីទិដ្ឋភាពដែលយើងនឹងត្រូវទទួលបាននៅពេលឆាប់ៗខាងមុខនេះ។ នៅពេលដែលយើងពិនិត្យទៅលើទិដ្ឋភាពជារួមនេះ យើងសង្កេតឃើញថាយ៉ាងហោចណាស់ក៏មានកំណត់ហេតុស្តាប់ចម្លើយពីរយ៉ាងតិចដែលពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ គឺឯកសារគឺ E319/23.3.1 ជាកំណត់ហេតុស្តាច់ចម្លើយដើមបណ្តឹង រដ្ឋប្បវេណីពីថ្ងៃ០៦ ខែមេសា ឆ្នាំ២០១២។ ហើយយើងក៏បានឃើញផងដែរនូវឯកសារ គឺ E319/23.3.57 គឺកំណត់ហេតុស្តាប់ចម្លើយថ្ងៃ២២ ឧសភា ឆ្នាំ២០១២ គឺទាក់ទងទៅនឹងព្រលានយន្ត ហោះកំពង់ឆ្នាំងផងដែរ។

យើងដឹងថាកំណត់ហេតុស្តាប់ចម្លើយថ្មីៗមានពាក់ព័ន្ធទៅនឹងការបោសសម្អាតភូមិភាគបូព៌ាផង

ដែរ ហើយវាមានយោងនៅក្នុងដីកាដំណោះស្រាយទាក់ទងទៅនឹងកងទ័ពដែលធ្វើការនៅព្រលានយន្ត-ហោះកំពង់ឆ្នាំង ដែលភាគច្រើនពួកគាត់ជាកងទ័ពមកពីភូមិភាគបូព៌ា។

[០៩:១១:៣៧]

ដូច្នេះកំណត់ហេតុស្តាប់ចម្លើយថ្មីៗនេះប្រហែលជាអាចពាក់ព័ន្ធផងដែរទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ ក្រៅពីនេះទៀតមានឯកសារមួយចំនួននិយាយអំពីរចនាសម្ព័ន្ធយោធា គឺរចនាសម្ព័ន្ធកងទ័ពបដិវត្តន៍កម្ពុជា គឺមានឯកសារចំនួន៨៩ ដែលត្រូវបានបង្ហាញ ហើយដែលហាក់ដូចជាពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ ដោយសារតែវាជាដំណាក់កាលដំបូង វាអាចបង្កជាសំណួរ ហើយយើងក៏ចាប់ផ្តើមស្តាប់ភស្តុតាងអំពីព្រលានយន្តហោះកំពង់ឆ្នាំងឆាប់ៗនេះ។ ដូច្នេះ ខ្ញុំសង្ឃឹមថាប្រហែលជាខាងព្រះរាជអាជ្ញា គាត់អាចបង្ហាញថាការព្រួយបារម្ភរបស់យើងមានការពាក់ព័ន្ធដោយសារតែកំណត់ហេតុស្តាប់ចម្លើយមកពី០០៣, ០០៤ វាមានភាពពាក់ព័ន្ធជាមួយនឹងព្រលានយន្តហោះកំពង់ឆ្នាំងផងដែរ។

[០៩:១២:៣៩]

នៅពេលនេះ យើងទើបតែទទួលបានការជូនដំណឹងអំពីការដាក់បង្ហាញឯកសារ ដែលនឹងមកដល់ក្នុងពេលឆាប់ៗនេះ ទោះបីថាយើងមិនទាន់បានទទួលក៏ដោយ ហើយវាជាការមួយដែលធ្វើ គឺថាភាគីនីមួយៗមានការចាប់អារម្មណ៍យ៉ាងខ្លាំង រួមទាំងអង្គជំនុំជម្រះផងដែរ ហើយវាជាបញ្ហាដែលយើងត្រូវប្រឈមនៅពេលមុខ ដោយសារតែសវនាការអំពីព្រលានយន្តហោះកំពង់ឆ្នាំងនឹងចាប់ផ្តើមនៅសប្តាហ៍ក្រោយ។

ខ្ញុំក្នុងពេលឥឡូវនេះ យើងមិនលើកអំពីបញ្ហាថាតើយើងអាចអានឯកសារបញ្ចប់ ឯកសាររាប់ពាន់ទំព័រត្រូវឲ្យបានចប់ក្នុងរយៈពេល៤៨ម៉ោងមុនពេលនឹងសវនាការនឹងចាប់ផ្តើមនៅពេលក្រោយនោះឡើយ។ ប៉ុន្តែយើងនឹងធ្វើការលើកជាសារណាបន្ទាប់ពីយើងបានស្តាប់អំពីខាងព្រះរាជអាជ្ញាទាក់ទងទៅនឹងឯកសារថ្មីដែលថាតើវាពាក់ព័ន្ធនឹងព្រលានយន្តហោះកំពង់ឆ្នាំងឬក៏យ៉ាងណា។ ទាំងអស់នេះសុទ្ធតែជាបញ្ហាដែលកើតឡើងដោយសារតែការដាក់បង្ហាញឯកសារថ្មីៗពីខាងព្រះរាជអាជ្ញា ហើយខ្ញុំសង្ឃឹមថាខាងព្រះរាជអាជ្ញានឹងអាចបញ្ជាក់ទៅលើចំណុចនេះ។

ដូច្នេះចំណុចទី២ ដែលខ្ញុំចង់និយាយបន្ថែមទៀតគឺការកំណត់ហេតុ -- គឺការកំណត់កាលបរិច្ឆេទស្តាប់ទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង គឺថាយើងត្រូវស្តាប់សក្ខីកម្មប្រហែលជាប្រាំបីថ្ងៃកន្លះ

នៃថ្ងៃធ្វើការ។ ហើយប្រហែលជាយើងត្រូវកោះអញ្ជើញសាក្សីដែលបានបញ្ជើញមកម្តងឲ្យមកមួយសាទៀត ដើម្បីនិយាយអំពីទំនប់១មករាផងដែរ។

[០៩:១៥:១៨]

ដូច្នេះខ្ញុំគិតថា យើងនៅសល់ពេលតែពីរបីថ្ងៃប៉ុណ្ណោះមុនពេលដែលយើង -- យើងនៅសល់ពេលថែមតែពីរបីថ្ងៃទៀតប៉ុណ្ណោះ ទើបយើងចូលទៅដល់ពេលឈប់សម្រាករបស់តុលាការទៅហើយ។ ហើយនៅពេលដែលឈប់សម្រាកហ្នឹង គឺខាងតុលាការកំពូលនឹងដំណើរការសវនាការបន្ថែមទៀត ហើយតុលាការកំពូលគ្រោងនឹងកោះហៅសាក្សីចំនួនបី។ ខ្ញុំគិតថាប្រហែលជាយើងយល់ថាខាងមេធាវីការពារក្តីត្រៀមខ្លួនសម្រាប់សាក្សីចំនួនបីបន្ថែមទៀតនេះផងដែរ។ ខ្ញុំចង់ធ្វើឲ្យប្រាកដថា តើយើងនៅសល់ពេលប៉ុន្មានថ្ងៃនៅចុងខែមិថុនា ដើម្បីឲ្យយើង -- ដូច្នេះដើម្បីឲ្យយើងអាចនឹង មុននឹងយើងចាប់ផ្តើម អាងទឹកត្រពាំងថ្មបន្តទៅទៀតនោះ នៅពេលដែលយើងត្រូវធ្វើការងារ។ ដូច្នេះ អ្វីដែលខ្ញុំចង់បញ្ជាក់បន្ថែមគឺថា គឺជាការរៀបចំការងាររបស់អង្គជំនុំជម្រះសាលាដំបូងនៅចុងខែមិថុនា ហើយខ្ញុំលើកយកចំណុចនេះព្រោះថា វាប្រសើរជាងដែលយើងលើកយកមកពិភាក្សានៅពេលនេះ ជាជាងទៅដល់ពេលនោះ ទើបយើងយកមកជជែកគ្នា។ ខ្ញុំគិតថា គួរតែទុកពេលវេលានៅចុងខែមិថុនា មុនពេលយើងបន្តទៅមុខទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[០៩:១៦:២០]

**កញ្ញា អង់តា ហ្គីសសេះ**

អរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីទាំងអស់គ្នា។ ខ្ញុំគិតថាជាការល្អ ខ្ញុំនិយាយក្នុងពេលឥឡូវ មុនព្រះរាជអាជ្ញាតែម្តងទៅ។ ដូចអ្វីដែលបានកើតឡើងទាក់ទងនឹងក្រាំងតាចាន់ គឺថាមានឯកសារថ្មីជាច្រើនដែលដាក់បន្ថែម អ៊ីចឹងជា -- ឥឡូវនេះដូចគ្នាដែលសហព្រះរាជអាជ្ញាផ្តល់ឯកសារបន្ថែមទៀត។ ហើយយើងគោលជំហរយើងមិនទាន់ច្បាស់លាស់នៅឡើយទេ ព្រោះយើងមិនទាន់អានឯកសារ មិនទាន់ឃើញឯកសារនៅឡើយទេ គ្រាន់តែដឹងពីសេចក្តីសង្ខេបតែប៉ុណ្ណោះ ទាក់ទងនឹងឯកសារដែលបន្ថែមមកទៀតនេះ។ ដូចក្រុម នួន ជា ដែរ គឺថាមានសាក្សី ពីរនាក់និយាយពីកំពង់ឆ្នាំង–ព្រលានយន្តហោះកំពង់ឆ្នាំង។ អ៊ីចឹងកាលវិភាគបឋមរបស់យើងដែលយើងធ្វើនោះ ទាក់ទងទៅនឹង

ចម្លើយ៥១ ទាក់ទងនឹងការបោសសម្អាត។ អ៊ីចឹងជាការសំខាន់ណាស់ ក្នុងការយល់អំពីសមាសភាពយោធា ហើយនេះជាព័ត៌មានដ៏សំខាន់ ធាតុដ៏សំខាន់មួយសម្រាប់ព្រលានយន្តហោះកំពង់ឆ្នាំង។ ហើយការចាប់ផ្ដើមនិយាយអំពីព្រលានយន្តហោះកំពង់ឆ្នាំងនេះ ដោយមិនផ្ដល់លទ្ធភាពឲ្យយើងអាននូវឯកសារឬក៏ចម្លើយថ្មីទាំងអស់នេះ នឹងពិបាកក្នុងការត្រៀមការពារកូនក្ដីរបស់យើងណាស់។ ហើយយើងចាំព័ត៌-មានដែល ឬក៏ឯកសារដែលសហព្រះរាជអាជ្ញាផ្ដល់ឲ្យយើង តែឥឡូវនេះ បើសិនជាយើងចាប់ផ្ដើមត្រង់ថ្ងៃចន្ទទៅហើយនេះ គឺថាយើងនឹងមានបញ្ហាក្នុងការរៀបចំត្រៀមលក្ខណៈណាស់។ ចំណុចទី២ គឺទាក់ទងទៅនឹងការរៀបចំសវនាការ បណ្ដឹងសាទុក្ខ ហើយមានការកោះហៅសាក្សីមកថ្មីៗ។ ហើយទុក្ខកង្វល់របស់យើងដូចគ្នាដដែល ព្រោះថាយើងពិបាកនឹងត្រៀមលក្ខណៈឲ្យបានគ្រប់គ្រាន់ អ៊ីចឹងយើងចាំព័ត៌មានពីសហព្រះរាជអាជ្ញាទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ ហើយការត្រៀមលក្ខណៈដើម្បីចូលរួមក្នុងតុលាការកំពូលខាងមុខនេះ គឺវាធ្វើឲ្យយើងមានការព្រួយបារម្ភខ្លាំងណាស់ដើម្បីការពារលោក ខៀវ សំផន ឲ្យមានប្រសិទ្ធភាពនោះ ព្រោះត្រូវត្រៀមតុលាការកំពូលផង សាលាដំបូងនេះផង។

[០៩:១៨:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ ប្រគល់នាទីជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ។ សូមអញ្ជើញបាទ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងបញ្ហាមួយចំនួនដែលបានលើកឡើងជាការពិត គឺមានការសម្ភាសថ្មីបន្ថែមពីរទៀតដែលមានការទាក់ទងផ្ទាល់ទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ គឺថា វាមានហេតុផលពីរដែលថា ច្បាស់លាស់ គឺថា នេះមិនមែនជាការស៊ើបអង្កេតលម្អិតតែក្នុងសំណុំរឿង ០០៣ នោះឡើយ ព្រោះថា វាជាផ្នែកនៃសំណុំរឿង ០០២ រួចទៅហើយ។ ហើយហេតុផលទី២គឺថា កាលពីម្សិលមិញមានការប្រកាសជាសាធារណៈ ឬក៏ គឺការប្រកាសអំពីការស្លាប់របស់ ស៊ូ ម៉េត ដែលបានស្លាប់កាលពី១ឆ្នាំ ២ឆ្នាំមុនមក។ ដូច្នេះ វាជាការ ដូច្នេះការស៊ើបអង្កេតពីតាំងឧក្រិដ្ឋនោះវាបានចប់តាំងពីពេលនោះមកម្ល៉េះ។ ដូច្នេះ គឺថានៅក្នុងសំណុំរឿង០០៣, ០០៤ ប្រហែលជា៩០០កំណត់ហេតុដែលយើងបានធ្វើ គឺមានតែប្រាំមួយ ប្រហែលប្រាំមួយប៉ុណ្ណោះ ដែលពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង ហើយកំណត់ហេតុបីបានបង្ហាញកាលពីឆ្នាំមុន ហើយមួយបានបង្ហាញពីពេលកន្លងមក ហើយនៅសល់ពីរទៀតគឺនៅពេលឥឡូវនេះ។ ដូចដែលខ្ញុំបានបញ្ជាក់ពីមុនរួចមកហើយ

ដូច្នេះលោក កូប៉េ ប្រហែលជាពាក់ព័ន្ធទៅនឹងអ្វីដែលយើងបានស្នើក្នុងការបង្ហាញឯកសារ គឺថាសំណើនោះយើងបានធ្វើតាំងពីជាង១ឆ្នាំមុន ប៉ុន្តែសំណើហ្នឹងត្រូវបានបដិសេធកាលពីពេល១ឆ្នាំមុន ហើយទើបតែប៉ុន្មានសប្តាហ៍ ដែលយើងទទួលបានការអនុញ្ញាតវិញ។

[០៩:២១:០៧]

ដូច្នេះ យើងមិនអាចធ្វើអ្វីឲ្យបានច្រើននោះទេ ក្រៅពី -- ចង់បញ្ជាក់ថា យើងបានស្នើសុំឲ្យបង្ហាញឯកសារហ្នឹង តាំងពី១ឆ្នាំមុនមកម្ល៉េះ ប៉ុន្តែកំណត់ហេតុហ្នឹងត្រូវបានបដិសេធ។ ហើយក្រោយមកទៀត យើងបានធ្វើការបំបែកទៅលើសំណើរបស់យើងជាកង់ៗ ទើបសហចៅក្រមស៊ើបអង្កេតគាត់យល់អំពីបញ្ហាទាំងអស់នេះ ហើយសហចៅក្រមស៊ើបអង្កេតគាត់អនុញ្ញាត។ ដូច្នេះ អ្វីដែលយើងចង់ជម្រាបបាន គឺថាខាងព្រះរាជអាជ្ញា -- ខាងសហចៅក្រមស៊ើបអង្កេត គាត់ធ្វើការវាយតម្លៃ ធ្វើការពិនិត្យមើលទៅតាមករណីជាក់ស្តែង ហើយប្រសិនបើពួកគាត់យល់ឃើញថាវាមានភាពពាក់ព័ន្ធ ក៏ដូចជាសាក្សីអាចមានភាពទាក់ទង ទើបគាត់បង្ហាញ។ ដូច្នេះ ខ្ញុំមិនអាចបញ្ជាក់ឲ្យបានលម្អិតអំពីសំអាងហេតុនៃការអនុម័តយល់ព្រម ឬក៏មិនយល់ព្រមនោះឡើយ។ អ្វីដែលយើងអាចបញ្ជាក់បាន គឺថាយើងបានធ្វើសំណើ ហើយនៅពេលដែលមានការអនុញ្ញាត យើងនឹងដាក់បង្ហាញ។ ឯកសារមួយមានទំហំប្រាំមួយទំព័រ ឯកសារមួយទៀតមានទំហំត្រឹមតែ១០ទំព័រ។ ដូច្នេះ វាជាការសម្ភាសដ៏ខ្លី ការស្តាប់ចម្លើយសាក្សីដ៏ខ្លី។

គឺថាតាមដែលខ្ញុំដឹង គឺថាយើងនឹងកែឯកសារពីឯកសារក្រដាស ទៅជាឯកសារអេឡិចត្រូនិកដើម្បីឲ្យមានភាពងាយស្រួល ហើយមិនចាំបាច់ត្រូវការការព្រីន កូពីអ្វីនោះឡើយ។ ដូច្នេះ ខ្ញុំគិតថា យើងប្រហែលជាចំណាយពេលពីរបីថ្ងៃប៉ុណ្ណោះ យើងដើម្បីធ្វើការកែទៅជាអេឡិចត្រូនិក។ នៅពេលដែលខ្ញុំចូលរួមនៅទីនេះ ខ្ញុំនឹងបញ្ជូនអ៊ីម៉ែលទៅសហការីរបស់ខ្ញុំដើម្បីឲ្យពួកគាត់បញ្ជាក់ តើគាត់អាចផ្តល់ឯកសារពីរដែលពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំងទៅដល់ភាគីនៅពេលណា។

[០៩:២៣:០៤]

ចំពោះបញ្ហាទាក់ទងទៅនឹងភូមិភាគបូព៌ា។ ភូមិភាគបូព៌ាមិនមែនប្រធានបទនៃស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣នោះឡើយ ប៉ុន្តែមិនមែនមានន័យថា មិនអាចមានព័ត៌មានពាក់ព័ន្ធទៅនឹងភូមិភាគបូព៌ានោះទេ។ ដូច្នេះ អ្វីដែលខ្ញុំអាចជម្រាបបាន គឺថាភូមិភាគបូព៌ាមិនមែនជាប្រធានបទនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣នោះឡើយ។ អ្វីដែលយើងស៊ើបអង្កេតសំខាន់នៅក្នុងសំណុំរឿង០០៣ គឺ

ព័ត៌មានដែលដឹងដោយកងពល១៦៤។ ប៉ុន្តែនៅក្នុងនោះ ក៏ប្រហែលជាអាចមានផងដែរ ថាមានព័ត៌មានមួយចំនួនទាក់ទងទៅនឹងរចនាសម្ព័ន្ធ ប៉ុន្តែខ្ញុំសង្ឃឹមថា មិនមានអ្វីដែលពាក់ព័ន្ធថ្មីបន្ថែម ក្រៅពីព័ត៌មានដែលយើងមានសម្រាប់ ដូចជាព័ត៌មានអំពីព្រលានយន្តហោះកំពង់ឆ្នាំងជាដើមនោះផងដែរ។

ចំពោះសំណើទាក់ទងទៅនឹងអង្គជំនុំជម្រះតុលាការកំពូល យើងមិនមានបញ្ហាអ្វីទាក់ទងទៅនឹងការលើកឡើង ដែលថាមិនគួរចាប់ផ្ដើមត្រពាំងថ្មភ្លាមៗ នៅពេលដែលយើងបញ្ចប់កំពង់ឆ្នាំងឆាប់រហ័សនោះឡើយ។ ខ្ញុំគិតថា ការរៀបចំហាក់ដូចជាមិនទាមទារច្រើនសម្រាប់សាក្សីបីរបស់តុលាការកំពូលនោះឡើយ ព្រោះថាសាក្សីមួយ គឺជាសាក្សីដែលមានមេធាវីការពារក្ដីគាត់បានដឹង គាត់បានជ្រាបច្បាស់រួចទៅហើយ ហើយគឺជាសាក្សីដែលមេធាវីការពារក្ដីគាត់ស្គាល់ច្បាស់ផងដែរ។ ដូច្នេះហើយ ខ្ញុំគិតថា មិនមានអ្វីដែលយើងគួរបារម្ភនោះឡើយ ដូច្នេះយើងគួរតែបញ្ចប់ព្រលានយន្តហោះកំពង់ឆ្នាំងឲ្យបានពីរបីថ្ងៃជាមុនសិន បន្ទាប់មកទៀត សឹមយើងគិតដល់អាងទឹកត្រពាំងថ្ម។ ប្រសិនបើមានសំណួរឬក៏មានបញ្ហាបន្ថែម ខ្ញុំនឹងព្យាយាមធ្វើឲ្យបានអស់ពីលទ្ធភាព។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរពីរ។ តើលោកដឹងទេថាពេលណាឯកសារដែលត្រូវបានដាក់បង្ហាញ នឹងត្រូវប្រគល់ទៅដល់ភាគីនានា? តើលោកគិតថា នឹងត្រូវការពេលបីឬបួនថ្ងៃ ឬក៏បីបួនសប្ដាហ៍?

[០៩:២៥:៣០]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនដឹងច្បាស់អំពីបញ្ហានេះទេ ប៉ុន្តែខ្ញុំនឹងសួរសហការីរបស់ខ្ញុំអំពីដំណើរការទាំងអស់នេះ ហើយយើង -- ហើយខ្ញុំ ហើយគេប្រាប់ខ្ញុំថា គឺគេនឹងរៀបចំនៅថ្ងៃចន្ទឲ្យបានជាមួយហ្វូលឌ័រតែម្ដង ហើយចូលទៅក្នុងហ្វាយឡេបនៅក្នុងអង្គារ ប៉ុន្តែចំពោះឯកសារទាក់ទងនឹងកំពង់ឆ្នាំង ខ្ញុំនឹងព្យាយាមទទួលឲ្យបានឆាប់ៗបំផុត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ក្នុងករណីដែលលោកដឹងថា មានការបង្ហាញ -- ដាក់បង្ហាញឯកសារបន្ថែមទៀត ឧទាហរណ៍ថា តើមុនពេលដែលយើងឈប់សម្រាកមានការដាក់បង្ហាញឯកសារបន្ថែមទៀតដែរឬក៏អត់?

**លោក ឌេល លីសាក់៖**

ខ្ញុំមិនច្បាស់អំពីបញ្ហានេះទេ ព្រោះខ្ញុំកំពុងតែធ្វើការងារទៅលើបញ្ហាសាក្សី។ ប៉ុន្តែនៅពេលដែល

មានការអនុញ្ញាតឲ្យមានការដាក់បង្ហាញឯកសារ គឺប្រហែលជាដាក់ឯកសារនៅក្នុងសំណុំរឿង០០៤ ហើយការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងយើង គឺមានតែការដាក់បង្ហាញឯកសារមកពីសំណុំរឿង ០០៣ ទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំតែប៉ុណ្ណោះ ហើយព័ត៌មានភាគច្រើន គឺទាក់ទងតែទៅនឹងកងពល១៦៤នោះទេ។ ទោះជាយ៉ាងណាក្តីខ្ញុំមិនមានចំនួនជាក់ស្តែង ជាក់ច្បាស់ដើម្បីបង្ហាញជូនលោកស្រីចៅក្រមនោះឡើយ។ ខ្ញុំគិតថាមិនមានឯកសារច្រើនដាក់បង្ហាញទេ ប៉ុន្តែកុំបន្ទោសខ្ញុំប្រសិនបើវាមានបញ្ហាឯកសារច្រើននោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:២៧:៣២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមនិយាយដដែលៗទាក់ទងនឹងការផ្សាយព័ត៌មាន គឺថាយើងមានគោលជំហរជាក់លាក់ ព្រោះយើងគាំទ្រសហព្រះរាជអាជ្ញា ក៏ប៉ុន្តែយើងត្រូវឯករាជ្យផងដែរ។ អ៊ីចឹងយើងត្រូវការពេលវេលាដើម្បីសិក្សាឯកសារ ហើយអ៊ីចឹងយើងមាន -- ឥឡូវនេះយើងមានគោលជំហរដូចខាងការពារក្តីដែរ គឺថាត្រូវឲ្យផ្សព្វផ្សាយព័ត៌មានទាំងអស់នោះ យើងត្រូវដឹងពីបញ្ជីនៃឯកសារទាំង៩៤ហ្នឹងជាអ្វីដែលសំខាន់សម្រាប់យើង គឺឧបសម្ព័ន្ធដែលផ្ញើមកសហមេធាវីនាំមុខ ដោយលក្ខណៈសម្ងាត់បំផុត។ អ៊ីចឹងក្នុងដំណាក់កាលនេះ ខ្ញុំមិនមានសិទ្ធិចែកចាយព័ត៌មានទាំងអស់នេះ ទៅមេធាវីនោះទេ។ ជាមេធាវីដែលត្រូវជួយយើង គាំទ្រយើងក្នុងការការពារផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីនោះ។ ហើយយើងបានរៀបចំការការពាររួមមួយ សម្រាប់ព្រលានយន្តហោះកំពង់ឆ្នាំង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ យើងបានត្រៀមគាត់ដើម្បីផ្តល់សក្ខីកម្ម រហូតដល់ពេលនេះ យើងមិនអាចបែងចែក ចែករំលែកព័ត៌មាននេះជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ។ ដូច្នេះ ជាការសំខាន់ណាស់សម្រាប់ពួយើងទាំងអស់គ្នាក្នុងការដឹងអំពីឯកសារ សំណុំឯកសារទាំងអស់នេះទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ នេះជាការកត់សម្គាល់ទី១។

ហើយការកត់សម្គាល់ទី២ ទាក់ទងទៅនឹងសំណើរបស់សហភាគា កូប៉េ ដែលសូមឲ្យពន្យារពេលសិនមុននិយាយអំពីត្រពាំងថ្មនោះ យើងត្រូវ -- បើសិនជាយើងបញ្ចប់មុនចុងខែមិថុនា នោះមិន

មានបញ្ហាអ្វីទេសម្រាប់យើងនោះ។ អ៊ីចឹងយើងគាំទ្រនឹងគោលជំហររបស់លោកមេធាវី កូប៉េ សូមឲ្យពន្យារពេលសិន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវរាល់មតិយោបល់របស់ភាគីដែលលើកឡើងពាក់ព័ន្ធនឹងបញ្ហាការដាក់បង្ហាញឯកសារថ្មីៗ អំពីសំណុំរឿង០៣, ០៤ មកសំណុំរឿង០០២/០២នេះ ហើយបញ្ហាទាំងអស់នេះ អង្គជំនុំជម្រះនឹងយកទៅពិនិត្យពិចារណា ហើយនិងដោះស្រាយជាបណ្ដើរៗនៅពេលខាងមុខ ដើម្បីឲ្យធ្វើយ៉ាងណាឲ្យលទ្ធភាពនៃការការពារក្ដីរបស់ភាគីគឺថាអាចប្រព្រឹត្តទៅបានផង ហើយនិងធ្វើយ៉ាងណាឲ្យដំណើរការរបស់យើងប្រព្រឹត្តទៅបានឆាប់រហ័សផងដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោក កូប៉េ បន្ទាប់ពីលោកបានស្ដាប់ឮអ្វីដែលព្រះរាជអាជ្ញាបានថ្លែងថាតើលោកមានការប្រែប្រួល ឬក៏មានអ្វីលម្អិតបន្ថែមទៀតទេ?

[០៩:៣០:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយដែលលោកស្រីប្រគល់ឱកាសនេះមកឲ្យខ្ញុំ។ ខ្ញុំមានការចាប់អារម្មណ៍ដែលខ្ញុំបានស្ដាប់ពីខាងព្រះរាជអាជ្ញា គាត់ហាក់ដូចជាបដិសេធនូវសារណារបស់យើង ទាក់ទងទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ៨៧ ទៀតដែលនិយាយអំពីរចនាសម្ព័ន្ធយោធា ក៏ដូចជាការបោសសម្អាតនៅភូមិភាគបូព៌ា ដែលពួកគេប្រហែលជាភាគច្រើនអាចត្រូវបានបញ្ជូនមកព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំគិតថាយើងអាចទទួលបានកំណត់ហេតុស្ដាប់ចម្លើយពីរ ទាក់ទងដោយផ្ទាល់ទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ ប៉ុន្តែចុះឯកសារ៨៧ ទៀត? វិធីសាស្ត្រដ៏ល្អក្នុងការដោះស្រាយ គឺថាយ៉ាងហោចណាស់គឺទុកឱកាសឲ្យយើងបី -- ពីរ ឬបីថ្ងៃនៅសប្ដាហ៍ក្រោយដើម្បីឲ្យយើងអាចធ្វើការសិក្សាទៅលើកំណត់ហេតុស្ដាប់ចម្លើយទាំង៨៩ ដែលអាចថាមានភាពពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏អាចថាយើងចាប់ផ្ដើមថ្ងៃសវនាការនៅថ្ងៃពុធ ឬក៏ថ្ងៃព្រហស្បតិ៍។ ការធ្វើដូច្នេះ គឺជាវិធីសាស្ត្រល្អក្នុងការបន្តកិច្ចដំណើរការនីតិវិធី ប្រសើរជាងការដែលយើងចាប់ផ្ដើមសាក្សីថ្មី ហើយយើងអត់មានព័ត៌មាន ឬក៏អត់ដឹងអ្វីសោះអំពីសាក្សីទាំងអស់នោះក៏ដូចជាអំពីហេតុការណ៍។

ខ្ញុំគិតថា យើងមានសំណុំ -- នៅក្នុងសំណុំរឿង ០០៣, ០០៤ មានប្រហែលជា៩០០ កំណត់-

ហេតុស្តាប់ចម្លើយ។ ប៉ុន្តែទាក់ទងទៅនឹងកំណត់ហេតុចំនួន៨៩ កំណត់ហេតុស្តាប់ចម្លើយ គឺយើងមានប្រហែលជា៥២៥ នៅសល់ទៀត ប្រសិនជាការគណនារបស់ខ្ញុំ ប្រហែលជាមានឯកសារ៣៧៥ ទៀតដែលនឹងត្រូវដាក់បង្ហាញនៅពេលបន្តបន្ទាប់ខាងមុខនេះ។ ខ្ញុំដឹងថាព្រះរាជអាជ្ញាគាត់មិនទាន់ដឹង ប៉ុន្តែយ៉ាងណាក៏ដោយ វាអាចមានលទ្ធភាពដោយថាកំណត់ហេតុដែលនៅសល់ទាំងប៉ុន្មាននឹងត្រូវបានបង្ហាញមកយើង។

ហើយឥឡូវនេះយើងដឹងថា សំណុំរឿង០០៣ និង ០០៤ គឺមានការប្រែប្រួលថ្មី ដោយសារមានការចោទប្រកាន់ទៅលើសាក្សី -- ទៅលើជនសង្ស័យទាំងបួននាក់នោះរួចទៅហើយ។ ដូច្នេះហើយវាជាការប្រសើរម្យ៉ាងដែរ ដែលយើងទទួលបានកំណត់ហេតុស្តាប់ចម្លើយពីភាគី ពីសំណុំរឿង០០៣, ០០៤។ ប្រសិនបើអាចគួរតែមានការផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយដែលនៅសល់ពីសំណុំរឿង ០០៣, ០០៤ ហើយដល់ពេលដែលមានឯកសារច្រើនបែបនេះ គឺយើងត្រូវការពេលវេលាច្រើន ហើយយើងក៏មានការលំបាក ដូចជាហត់នឿយដែរ នៅក្នុងការពិនិត្យមើលទៅលើឯកសារទាំងអស់នោះ។

[០៩:៣៣:៤៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ដើម្បីឲ្យមានសមហេតុសមផលហ្នឹង គឺថា យើងៗធ្វើការកត់សម្គាល់បន្ថែមឥឡូវតែម្តង។ បើសិនជាខ្ញុំយល់មិនច្រឡំទេ ថាព្រះរាជអាជ្ញាបាននិយាយថា យើងមានលទ្ធភាព ពិគ្រោះឯកសារទាំងអស់ចាប់ពីថ្ងៃចន្ទហ្នឹងទៅ បើសិនជាថ្ងៃចន្ទហ្នឹងមាននៅក្នុងហ្សាយឡេបហើយ។ នេះបើខ្ញុំយល់មិនច្រឡំទេ។ បើសិនជាយើងត្រូវការរយៈពេលប្រហែលបីបួនថ្ងៃនោះ តើយើងត្រូវធ្វើយ៉ាងណា ធ្វើយ៉ាងម៉េចនឹងកើតដើម្បីចាប់ផ្តើម ធ្វើសវនាការនៅកំពង់ឆ្នាំងនោះ នៅសប្តាហ៍មួយទៀតនោះបន្ទាប់ -- ចំពោះយើងជាការលំបាកណាស់ក្នុងការនិយាយពីឯកសារដែលយើងមិនបានដឹងហើយនោះ សូម្បីតែដល់ផ្នែកមិនទាន់នឹងដឹងផង ពីព្រោះថាមានតែចម្លើយពីរទេ ដែលនិយាយអំពីព្រលានយន្តហោះកំពង់ឆ្នាំងនោះ។ ហើយឯកសារផ្សេងទៀតនោះមិនពាក់ព័ន្ធទេ ហើយអ៊ីចឹង មិនមែនដោយសារថាមានឯកសារតែពីរហ្នឹងទេ ដែលឯកសារផ្សេងទៀតនោះ វាពាក់ព័ន្ធទៅនឹងយោធា និងការបោសសម្អាតនោះ ដែលៗគេថាមិនពាក់ព័ន្ធចំពោះភាគីការពារក្តីនោះ ព្រោះអានោះក៏វាអាចពាក់ព័ន្ធដែរ។ សហព្រះរាជអាជ្ញាអាចនិយាយគាត់ថាមានតែពីរឯកសារមែន ព្រោះថាខ្លួនបានពិនិត្យមើលឯកសាររួចហើយ អ៊ីចឹងត្រូវយល់ផងដែរថាមានឯកសារផ្សេងដែលនៅសេសសល់ទាំងប៉ុន្មាននោះ មើលទំនងទៅដូចតិចជាមិនសំខាន់ទេ ក៏ប៉ុន្តែ

ចំពោះភាគីការពារក្ដីអាចថាមានភាពពាក់ព័ន្ធខ្លាំងដែរ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់ដោយសង្ខេប។ ខ្ញុំចង់ឲ្យច្បាស់ខ្លាំងប្រសិនបើមានការស្ដាប់ចម្លើយទៅលើទាហាន នៅភូមិភាគបូព៌ាដែលត្រូវបានគេបញ្ជូនទៅកំពង់ឆ្នាំង គឺនឹងមានការពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋនោះ។ ការលើកឡើងដែលថាអាចថាមានឯកសារដទៃទៀតពាក់ព័ន្ធទៅនឹងការបោសសម្អាតទៅអាចឈានទៅ ដល់ព្រលានយន្តហោះកំពង់ឆ្នាំង ខ្ញុំនឹងមិនជំទាស់នោះទេ ព្រោះថាការស្ដាប់ចម្លើយនោះវាអាចពាក់ព័ន្ធ ទៅនឹងយោធា ទៅនឹងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ការផ្ដោត សំខាន់នៃការៗស្ដាប់ចម្លើយគឺទៅលើកងពល១៦៤ តែប៉ុណ្ណោះ។ ដូច្នេះ វាគឺជាការវាយតម្លៃរបស់ខាង ដើម -- ខាងមេធាវីការពារក្ដីទាក់ទងទៅនឹងស្ថានភាពទាំងអស់នេះ។

[០៩:៣៦:៣៨]

វាអាចមានលទ្ធភាពដែលថាមានការបង្ហាញឯកសារបន្ថែមទៀត។ ខ្ញុំប្រាកដអំពីចំណុចនេះ ព្រោះថាវាមានកំណត់ហេតុស្ដាប់ចម្លើយ៩០០។ ដូច្នេះពាក់ព័ន្ធទៅនឹងអ្វីដែលមិនទាន់បានបង្ហាញគឺកំពុង តែធ្វើការពិនិត្យវាយតម្លៃ ហើយគេក៏កំពុងតែបន្តការស្ដាប់ចម្លើយបន្ថែមតទៅទៀត ហើយឯកសារ ប្រហែលជា៣០ កំពុងតែធ្វើការវាយតម្លៃ ហើយការស៊ើបអង្កេតកំពុងតែបន្តទៅមុខទៀត។ ប៉ុន្តែ ចំពោះឯកសារដែល -- ឯកសារនៃការស្ដាប់ចម្លើយដែលបានធ្វើរួចទៅហើយ ខ្ញុំនឹងត្រួតពិនិត្យមើលអំពី ចំនួន ប៉ុន្តែតាមដែលខ្ញុំដឹង ការបង្ហាញក្នុងពេលកន្លងមក គឺបង្ហាញនូវកំណត់ហេតុស្ដាប់ចម្លើយសឹងតែ ទាំងអស់ ដែលយើងបានស្នើ ហើយការស្នើរបស់យើងសឹងតែទាំងអស់ត្រូវបានទទួលការអនុញ្ញាតយល់ ព្រម ភាគច្រើននៃកំណត់ហេតុស្ដាប់ចម្លើយនោះ គឺទទួលបានពីសំណុំរឿង០០៣។ ខ្ញុំមិនមែនជាបុគ្គលិក ខាងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែភាគច្រើនការចោទប្រកាន់ហ្នឹង គឺវាៗបង្ហាញថា ហាក់ដូចជាមានភាពសមស្រប ដែលថាអាចអនុញ្ញាតឲ្យមានការបង្ហាញនូវឯកសារភាគច្រើន។ ការ ដែលគេមិនចង់បង្ហាញឯកសារទាក់ទងទៅនឹងសំណុំរឿង០០៣ ក្នុងពេលកន្លងមកដោយសារតែឯកសារ ទាំងអស់នោះវាពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតកំពុងតែបន្តទៅមុខ មិនមានបញ្ហាអ្វីនោះទេ។ ដូច្នេះ ខ្ញុំនឹង ព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីទទួលបានឯកសារដែលអាចទាក់ទងទៅនឹងព្រលានយន្តហោះកំពង់ ឆ្នាំង។ ប៉ុន្តែខ្ញុំបញ្ជាក់ដដែលៗអ៊ីចឹង គឺការស៊ើបអង្កេតពាក់ព័ន្ធតែទៅនឹងកងពលធំ១៦៤ តែប៉ុណ្ណោះ។ ខ្ញុំមិនមែនដើបឡើងថា វាមិនមានភាពពាក់ព័ន្ធ ឬក៏អាចមានលទ្ធភាពពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា

នោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ បញ្ហានេះចប់ត្រឹមនេះចុះ។ បាទ ផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្ត ការតាំងសំណួរដេញដោលចំពោះសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

[០៩:៣៩:១០]

**ការតាំងសំណួរដោយចៅក្រម**

**សួរបន្តដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំនៅសល់ពីរសំណួរទៀតដើម្បីសួរលោកស្រី។ កាលពីម្សិលមិញ លោកស្រីបានបញ្ជាក់ថានៅពេលដែលលោកស្រីធ្វើជាគណៈស្រុកចំការលើលោកស្រីមានកូនម្នាក់ ហើយបន្ទាប់ពីកូននោះកើតមក លោកស្រីមិនសូវចូលរួមនៅក្នុងកិច្ចការស្រុកទេ។ តើលោកស្រីអាចចាំទេថា នៅថ្ងៃខែឆ្នាំណាដែរ ដែលកូនលោកស្រីកើតនោះ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស កូនខ្ញុំកើតអាក្រោយបង្អស់ គឺតាមខ្ញុំចាំ គឺឆ្នាំម្សាញ់។ ឆ្នាំម្សាញ់មកឥឡូវនេះវាប៉ុន្មានហើយទេ ខ្ញុំមិនចាំ។ កើតឆ្នាំម្សាញ់ កើតហើយក៏ខ្ញុំឈឺរហូត អត់បានរួមធ្វើការអីទេ។ សូមជម្រាប។

**ស៖** អ៊ីចឹងចាប់ពីពេលដែលលោកស្រីកើតមក លោកស្រីលែងចូលរួមច្រើននៅក្នុងកិច្ចការរបស់ស្រុកទៀតហើយ។ អ៊ីចឹងមែនទេ ការដែលខ្ញុំយល់អ៊ីចឹងគឺត្រឹមត្រូវទេ?

**ឆ៖** ចាស ដល់ពេលខ្ញុំឆ្លងទន្លេរួចហើយ ខ្ញុំចាប់ផ្តើមឈឺ ដូច្នេះការងារខ្ញុំអត់បានជាប់ នឹងមូលដ្ឋានក៏មិនបានជាប់ ជាប់នឹងគណៈស្រុកក៏ខ្ញុំមិនបានជាប់។ ទៅប្រគល់ភារកិច្ចឱ្យប្រធានស្រុកអ្នកធ្វើការនិងសង្កាត់គាត់បានធ្វើការ។ ចំណែកខ្ញុំសូមផ្អាកមួយរយៈ។ មួយរយៈគឺ២ឆ្នាំ។ ២ឆ្នាំហ្នឹង តាមខ្ញុំចាំគឺ ៧៧-៧៨។ ដូច្នេះដល់ពេលនោះ ឆ្នាំ៧៨ត្រូវបែកគ្នាអស់។ សូមជម្រាបត្រង់ហ្នឹង។

[០៩:៤១:៥៣]

**ស៖** តើអ្នកណាជាប្រធានស្រុកចំការលើ?

**ឆ៖** តាមខ្ញុំចាំគឺឈ្មោះ តាបាន ហ្នឹងហើយ តាមចាំ។ ចាំម្នាក់ហ្នឹងគឺធ្លាប់ស្និទ្ធស្នាលហ្នឹងគ្នា

ផ្កាប់រស់នៅ ឬគេហៅផិតអ៊ីចឹង គឺស្គាល់តែម្នាក់ហ្នឹងជាប់។ ក្រៅពីហ្នឹងមក ខ្ញុំមិនបានទេ មិនបានស្គាល់គេទេ បែកគ្នាអស់ទៅ។

**ស៖** នៅពេលដែលលោកស្រីនិយាយថា លោកស្រីលែងចូលរួមនៅក្នុងសកម្មភាពរបស់គណៈស្រុក មានន័យថាលោស្រីឈប់ទាំងស្រុងតែម្តង ឬក៏លោកស្រីគ្រាន់តែកាត់បន្ថយសកម្មភាពមួយចំនួន? ខ្ញុំហាក់ដូចជាយល់ថា ការសាងសង់ទំនប់១មករា បានប្រព្រឹត្តទៅក្នុងអំឡុងឆ្នាំ១៩៧៧។ អ៊ីចឹងតើលោកស្រីមានទៅ -- លោកស្រីទៅទំនប់១មករាហ្នឹងទៀតទេ ក្រោយពីលោកស្រីសម្រាលកូនហើយនោះ?

**ឆ៖** ចាស ពេលនោះខ្ញុំទៅ ប៉ុន្តែគ្រាន់ទៅក្នុងនាមទៅលេង ខ្ញុំលេងក្នុងរឿង -- ក្នុងនាមជាគ្រួសារ តែកិច្ចការការងារអ្វី គឺនៅក្នុងទំនប់១មករា ក៏ខ្ញុំគ្មានភារកិច្ចចូល ហើយកន្លែងផ្សេងៗក៏ខ្ញុំអត់បានចូល តែកន្លែងស្រុកគឺខ្ញុំបាន គ្រាន់តែពេលណាគេប្រជុំ គណៈស្រុកគេប្រជុំ គេគ្រាន់តែមកប្រាប់ខ្ញុំកិច្ចការនេះធ្វើអ៊ីចេះ កិច្ចការនោះធ្វើអ៊ីចុះបង តែប៉ុណ្ណឹង។

**ស៖** លោកស្រីអាចបញ្ជាក់ឲ្យច្បាស់បន្តិចទេថា ភារកិច្ចរបស់គាត់ហ្នឹងមានអីខ្លះ?

**ឆ៖** ភារកិច្ចរបស់ខ្ញុំដល់ពេលខ្ញុំឈប់ធ្វើការមួយរយៈមក គឺថាប្រគល់ភារកិច្ចឲ្យគេហើយ ភារកិច្ចខ្ញុំគឺនៅតែផ្ទះ ហើយមើលសហករណ៍ដែលនៅរោងបាយហ្នឹង រោងបាយនៅសហករណ៍តែប៉ុណ្ណឹងឯង អត់មានភារកិច្ចទៅទាក់ទងកន្លែងផ្សេងទៀតទេ។ ការងារនៅក្នុងស្រុក គឺប្រគល់ឲ្យស្រុកអស់ហើយ ខ្ញុំអត់មានទាក់ទងភារកិច្ចហ្នឹងតទៅទៀតទេ ប៉ុនការណ៍ក្នុងគេនិយាយប្រាប់ហ្នឹង គឺនិយាយប្រាប់ក្នុងនាមថាខ្ញុំជាបងអ៊ីចឹង គេមកប្រាប់ថាបងកិច្ចការនេះធ្វើអ៊ីចេះ កិច្ចការនោះធ្វើអ៊ីចុះ។ គ្រាន់តែដឹងឮ ប៉ុន្តែភារកិច្ចខ្ញុំដូចអស់ត្រឹមហ្នឹង។

[០៩:៤៥:២៤]

**ស៖** អ៊ីចឹងនៅពេលដែលគេរាយការណ៍នោះ គឺគេប្រាប់លោកស្រីថា អ្វីៗគឺថាល្អប្រសើរទាំងអស់អត់មានបញ្ហាអីទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ក្នុងគេនិយាយប្រាប់ គាត់និយាយប្រាប់ថា សហករណ៍ហ្នឹងគឺគេបានរៀបចំគ្រប់គ្រាន់អស់ហើយ។ កន្លងមកគឺខ្ញុំអត់បានចុះទៀតទេ ខ្ញុំចុះនៅត្រឹមបាយរួម តែកន្លែងផ្ទះខ្ញុំ មន្ទីរខ្ញុំហ្នឹងដល់កន្លែងសហករណ៍ឆ្ងាយៗខ្ញុំអត់បានទៅដល់ទេ។ ហើយប្រធានសង្កាត់ក៏គាត់បាននិយាយថា ជីវភាពសហករណ៍យើងគ្រប់គ្រាន់មិនខ្វះអីទេ។ នេះខ្ញុំ គេគ្រាន់តែមកនិយាយប្រាប់ជាធម្មតាអ៊ីចឹង ដែលការងារខ្ញុំអត់មាន។ ចាឥឡូវ ខ្ញុំនៅមានភារកិច្ចត្រូវណែនាំបងប្អូនថា ឥឡូវណែនាំប្រធានសង្កាត់ ឬឲ្យទៅមើល

បងប្អូនយ៉ាងម៉េចៗ ខ្ញុំអស់ហើយ អស់សិទ្ធិទៅប្រាប់គេហើយ អស់សិទ្ធិនឹងទៅណែនាំគេហើយ ព្រោះខាងស្រុក ខាងតំបន់ គេថាឲ្យបងឯងសម្រាកទៅ២ឆ្នាំហ្នឹង ខ្ញុំអត់បានចូលរួមទៀតទេ។ ចាស ខ្ញុំសូមចប់។

**ស៖** នៅក្នុងឯកសាររបស់លោកស្រី លោកស្រីបានបញ្ជាក់ថា មុខងាររបស់លោកស្រីនៅក្នុងគណៈស្រុកមានពីរផ្នែក។ ផ្នែកទី១ នោះគឺដឹកនាំប្រជាជននៅសហករណ៍ឲ្យសាងសង់ទំនប់ និងជីកប្រឡាយ។ លោកស្រីក៏បានបញ្ជាក់ផងដែរថា លោកស្រីមានមុខងារអប់រំប្រជាជន។ នេះគឺជាចម្លើយដែលលោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារE3/5294, ERNជាភាសាបារាំងគឺ 00367812, ERNជាភាសាខ្មែរ 00348835, ជាភាសាអង់គ្លេស ប្រហែលជាខ្ញុំនឹងឲ្យនៅពេលក្រោយ ព្រោះថាពេលនេះ ខ្ញុំអត់ទាន់រកឃើញទេ។ ខ្ញុំសូមបញ្ជាក់ថា ពេលនោះគេសួរលោកស្រីថា តើការអប់រំហ្នឹងមានន័យថាយ៉ាងម៉េច? លោកស្រីបានឆ្លើយថា៖ “បន្ទាប់ពីបានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ស្រុកពាក់ព័ន្ធទៅនឹងការសម្រេចក្នុងការអនុវត្តផែនការ ខ្ញុំបានណែនាំប្រជាជននៅតាមសហករណ៍ឲ្យគោរពទៅតាមផែនការដើម្បីអភិវឌ្ឍប្រទេសជាតិ”។ បន្ទាប់មកគេសួរសំណួរមួយទៀត “តើលោកស្រីធ្វើយ៉ាងម៉េចចំពោះអ្នកដែលមិនគោរពតាមការណែនាំរបស់លោកស្រី? នៅពេលដែលគេមិនគោរពតាមការណែនាំយើង យើងអប់រំពួកគេម្តង ឬពីរដង បើពួកគេនៅតែបន្តទៅទៀត នៅតែមិនគោរពដដែល ស្រុកនឹងចាត់វិធានការចាំបាច់។ ខ្ញុំមិនដឹងថា គេនាំទាំងនោះ ទៅណាទេ”។

សំណួរទី១ របស់ខ្ញុំ ខ្ញុំចង់សួរលោកស្រីថា តើពាក្យថា ការ-- ខ្ញុំសុំទោស -- គឺថាការអប់រំហ្នឹងវាជាផ្នែកមួយនៃមុខងាររបស់លោកស្រី មែនទេ?

[០៩:៤៩:០៣]

**ផ៖** ចាស ពីមុនៗដែលខ្ញុំឆ្លងទន្លេ ខ្ញុំបានធ្វើការហ្នឹងគឺបានចុះជាប់ប្រជាជន បានណែនាំប្រជាជនអីចឹងមែន ប៉ុន្តែអាផ្នែករឿងថា ណែនាំមិនបានអីមិនបានហ្នឹង គឺភារកិច្ចខាងស្រុកត្រូវថា បើរឹងប៉ឹងរឹងត្អឹងអីចឹង គេនាំទៅណា អាហ្នឹងស្រេចតែខាងលើលេខាស្រុកគេសម្រេច តែខ្ញុំគ្រាន់តែជាសមាជិក។ ដូច្នេះការជួយមតិ ការអី ជួនកាលមិនបានចុះជាប់ទេ ចាស។

**ស៖** តើលោកស្រីចង់មានន័យថាម៉េច ថាស្រុកនាំមនុស្សទៅណាស្រេចតែចិត្តដែលគេចង់នោះ លោកស្រីចង់មានន័យថាម៉េច?

**ផ៖** ចាស ខ្ញុំត្រង់ហ្នឹង ខ្ញុំគ្រាន់តែឆ្លើយថា វាមិនច្បាស់លាស់ដែរ ព្រោះរឿងហ្នឹងដូចថាការ

រៀបចំដូចថាសង្កាត់គេអ្នករាយការណ៍ថា បុគ្គលហ្នឹង មានការណែនាំទៅ គាត់មិនស្តាប់ ដល់មិនស្តាប់ទៅ ពិភាក្សា គឺថាវិធានការនៅស្រុកហ្នឹង គឺគាត់មានសិទ្ធិ។ ចង់បញ្ជាក់អ៊ីចេះគឺមានសិទ្ធិសម្រេចថា ដក ឬក៏អីៗ ខ្ញុំមិនដឹងទេ ត្រង់ហ្នឹងនោះ។

**ស៖** តើលោកស្រីដឹងទេថា ពេលធ្វើសេចក្តីសម្រេចនោះ គឺស្រុកគិតគូទៅលើប្រវត្តិរូបរបស់អ្នកដែលពាក់ព័ន្ធ?

**ឆ៖** ចាស ក្នុងហ្នឹងដូចថាខ្ញុំចាំមិនបានដែរ វាកន្លងយូរឆ្នាំមកហើយ អាចភ្លេចខ្លះ ខ្ញុំឆ្លើយអាចវំលងខ្លះ ក៏វាខុស ឬត្រូវ ព្រោះការភ្លេចភ្លាំងវាច្រើន ដូច្នេះខ្ញុំនិយាយបានត្រឹមតែថា ខ្ញុំចាំខ្លះ ខ្ញុំបាននិយាយក្នុងមុខប្រធាន ខ្ញុំវារវង្វេងខ្លះហើយ ស្តាប់ -- ចម្លើយខ្លះក៏ឆ្លើយខុស។ បើមកពីវាមិនចាំ បានថាមិនចាំ វាភ្លេច។ វិញ្ញាណវាភ្លេច ចាស។

[០៩:៥១:៥៥]

**ស៖** តើលោកស្រីចាំទេថា អតីតទាហាន ឬក៏អតីតមន្ត្រីរដ្ឋការដែលធ្វើការនៅរបបលន់ នល់ហ្នឹង គេចាត់ទុកយ៉ាងម៉េចដែរ?

**ឆ៖** ចាស រឿងរបប លន់ នល់ គឺខ្ញុំរឹងតែក្តាប់មិនបានទៀតហើយ។ បើរឿងរបបហ្នឹង គឺមិនដឹងគេចាត់ទុកយ៉ាងម៉េច បើខ្ញុំអត់ដឹង ដូចថាវាឆ្ងាយពេកអ៊ីចឹង ស្តាប់មិនយល់ ស្តាប់មិនដឹង។ ដូច្នេះខ្ញុំមិនដឹង មិនដឹងថារឿងយ៉ាងម៉េច។

**ស៖** លោកស្រី កាលពីម្សិលមិញ និងថ្ងៃហ្នឹង ខ្ញុំកត់ត្រាថា កត់សម្គាល់ឃើញថា លោកស្រីសុំជំនួយពីបុគ្គលិក ធី.ភី.អូ។ អង្គការហ្នឹង គឺជាទូទៅគឺមានគោលដៅផ្តល់ជំនួយដល់អ្នកដែលជនរងគ្រោះនៃអំពើ -- នៃភាពតក់ស្លុត ឬក៏ភ័យរន្ធត់។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកស្រីមានរោគភ័យតក់ស្លុតអីទេ? ហើយអ្វីដែល -- នៅពេលដែលលោកស្រីរំឭកអំពីរឿងហេតុដែលកើតឡើងកាលពីអំឡុងឆ្នាំនុំង ធ្វើឲ្យលោកស្រីឈឺចាប់ទេ ហើយប្រសិនបើឈឺចាប់ហ្នឹង ថាហេតុអ្វីដែរ?

**ឆ៖** ចាស ក្នុងហ្នឹង វាគ្រាន់តែភ័យតក់ស្លុត តែមិនដឹងថាបត់បែនរបៀបម៉េចទៀត ខ្ញុំក៏មិនដឹងដែរ ព្រោះខ្ញុំគ្រាន់តែថា មានការ -- ពេលនោះវាមានច្របូកច្របល់ទាំងអស់គ្នា វាភ័យតក់ស្លុតទាំងអស់គ្នា។ វាភ័យឆោឡោទាំងអស់គ្នា វាមិនដឹងរឿងថា រឿងហ្នឹងវាកើតឡើងយ៉ាងម៉េច ខ្ញុំអត់ដឹងដែរ ចាស។

[០៩:៥៤:១៩]

**ស៖** លោកស្រីនិយាយថា "យើងគ្រប់គ្នាភ័យតក់ស្លុតហ្នឹង" តើលោកស្រីខ្លាចអ្នកណា? ហើយ

លោកស្រីខ្លាចអ្វីដែរ នៅពេលនោះ?

**ឆ៖** ខ្ញុំ -- ចាស ខ្ញុំខ្លាចមែនទែន គឺខ្លាចគ្រាប់ផ្លោង។ គ្រាប់ទម្លាក់គ្រាប់បែក គឺភ័យតក់ស្លុត។ ពេលនុ៎ង គឺបែកកូនបែកម៉ែអស់ មិនថាតែខ្ញុំ មិនថាតែគេ គ្រប់គ្នាគឺថាពេលណាកប៉ាល់ហោះមក គឺតក់ស្លុតទាំងអស់គ្នា។ ភ័យទាំងអស់គ្នា វាខ្លាចគ្រាប់។ ខំរត់ដឹកកូនដឹកចៅរត់ បែកបាក់គ្នា គឺខ្ញុំភ័យតក់ស្លុតអ៊ីចឹង។

**ស៖** លោកស្រី តាំងពីម្សិលមិញមកដល់ថ្ងៃនេះ យើងអត់មានបាននិយាយអំពីការទម្លាក់គ្រាប់បែកទេ។ ដូច្នេះលោកស្រីខ្លាចក្នុងការនិយាយ ឬក៏ៗលោកស្រីមិនប៊ានធ្វើអ្វីដែលថា មិនឲ្យខុសចិត្តអង្គការមែនទេ?

**ឆ៖** ចាស ខ្ញុំអត់មានចាប់អារម្មណ៍អ៊ីចឹងទេ លោកប្រធាន។ ខ្ញុំចាប់អារម្មណ៍ថា ការជាក់ស្ដែងរបស់ខ្ញុំ គឺខ្ញុំខ្លាចអ៊ីចឹងមែន ខ្ញុំមិនខ្លាចប្រធានម៉េចគឺ បងគាត់អ្នកគ្រប់គ្រងម៉េចទេ តែខ្ញុំជាក់ស្ដែង ខ្ញុំនិយាយតាមជាក់ស្ដែង និយាយតាមត្រង់ ដូចថា ខ្ញុំខ្លាចៗមែន។ ខ្លាចដោយសារអី? ដោយសារតែគ្រាប់ដែលអត់ស្គាល់មនុស្ស តែទម្លាក់ហើយគឺត្រូវងាប់ អ៊ីចឹងវាភ័យទាំងអស់គ្នា។ ត្រង់ថា ឲ្យខ្ញុំខ្លាចម៉េច ដូចប្រសាសន៍លោកថា "ខ្លាចប្រធាន"។ ខ្ញុំអត់មានជាប់ពាក់ព័ន្ធរឿងហ្នឹងទេ ខ្ញុំមិនខ្លាច ដឹងអី ខ្លាចរឿងគ្រាប់មួយ គ្រាប់ផ្លោង គ្រាប់កាំភ្លើងដែលទម្លាក់មក។ នេះ គឺខ្ញុំនិយាយត្រង់ហើយ ហើយស្មារតីខ្ញុំនៅចាំត្រង់ហ្នឹងខ្លះ។

[០៩:៥៦:៤៨]

**ស៖** លោកស្រី តើលោកស្រីខ្លាចក្នុងការចោទសំណួរមែនទេ? លោកស្រីបាននិយាយកាលពីម្សិលមិញថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺម្នាក់ៗត្រូវគិតតែរឿងកិច្ចការរបស់ខ្លួន សក់អ្នកណាក្បាលអ្នកហ្នឹង។ អ៊ីចឹងលោកស្រីខ្លាចមិនប៊ានចោទសំណួរមែនទេ នៅពេលនោះ?

**ឆ៖** ទេ ដូច -- ចាស ដូចខ្ញុំមិនយល់ ខ្ញុំមិនយល់ថា លោកប្រធានបញ្ជាក់ហើយបញ្ជាក់ទៀតថា "ខ្ញុំខ្លាចមិនប៊ាននិយាយ" តែខ្ញុំនិយាយហ្នឹង គឺនិយាយជាក់ស្ដែងៗ ទោះដល់ខ្ញុំខ្លាចមែន ខ្លាចរឿងគ្រាប់រឿងអ៊ីចឹងមែន។ ខ្ញុំអត់មាននិយាយរឿងថា ម៉េចទៀតទេ។ ចាចាំ បានជាចាំអាហ្នឹងមកពីអី មកចាំហ្នឹងមកពីការជាក់ស្ដែងៗ គឺខ្លាចអ៊ីចឹង។ រួចបែកបាក់កូនចៅអ៊ីចឹងមែន។ ខ្ញុំនិយាយតាមត្រង់ តាមដែលខ្ញុំបានឆ្លងកាត់គ្រាប់ផ្លោង គ្រាប់កាំភ្លើងទម្លាក់គ្រាប់បែកនេះ ខ្ញុំខ្លាច។ ហើយខ្ញុំនិយាយតាមត្រង់អ៊ីចឹងទៅ។ តែរឿងអីទៀត ខ្ញុំអត់ចាំទេ ក៏អត់បានធ្វើអនុវត្តអីខុសពីនុ៎ងដែរ។

**ស៖** លោកស្រីក្រោយថ្ងៃ១៧ មេសា ១៩៧៥ហ្នឹង មានទម្លាក់ មានការទម្លាក់គ្រាប់បែកដែរ?

**ឆ៖** ចាស ថ្ងៃ១៧មេសា មានតែកាំភ្លើង ចាស មានតែកាំភ្លើងផ្តោងដេញតាម។ ពេលនោះ គឺយួនវាចូលកម្ពុជា ដូច្នេះនាំគ្នារត់ចោលផ្ទះចោលសម្បែង ចោលកូនចោលចៅខ្លះ។ ហ្នឹងខ្ញុំចាំអ៊ីចឹង។

**ស៖** លោកស្រីនិយាយអំមិញហ្នឹង គឺនៅថ្ងៃ១៧ មេសា ៧៥ មែនទេ?

**ឆ៖** ១៧មេសា ៧៥ហ្នឹង? ខ្ញុំតាមដែលស្តាប់បាន គឺខ្ញុំថា ពេល៧៩ – ៧៩ គឺរត់ចៀសគ្រាប់ផ្តោងរត់បែកកូនបែកចៅ ខ្ញុំបញ្ជាក់ត្រង់ហ្នឹងទេ។ មួយរឿងរដ្ឋប្រហារនៅភ្នំពេញ។ មួយទៀតដែលត្រូវរត់ចេញភៀសខ្លួនទៅពីផ្ទះ ពីសម្បែងទៅជ្រកតាមព្រំដែន គឺឆ្នាំ៧៩ បែកកូនបែកចៅ។ អាហ្នឹង ខ្ញុំខ្លាចគ្រាប់អី ខ្លាចគ្រាប់ផ្តោង វាដេញតាម។ អ៊ីចឹងហើយខ្ញុំបញ្ជាក់ថាពីរផ្នែក។ ចាស មានប៉ុណ្ណឹង។

[១០:០០:២៦]

**ស៖** នៅពេលដែលកម្មាភិបាលនៅជុំវិញលោកស្រីបាត់ខ្លួន នៅពេលដែលអ្នកមូលដ្ឋានបាត់ខ្លួន នៅពេលដែលអ្នកសហករណ៍បាត់ខ្លួន តើលោកស្រីមានសួរគេ សួរឯងទេពីបញ្ហាហ្នឹង? លោកស្រីបានសួរគេទេ ឬក៏លោកស្រីខ្លាចមិនបានសួរគេទេអំពីរឿងបាត់ខ្លួននេះ?

**ឆ៖** ចាស រឿងបាត់ខ្លួន ខ្ញុំសូមជម្រាបថារឿងបាត់ខ្លួន បើភារកិច្ចប្រគល់ឲ្យគេហើយ ខ្លួនខ្ញុំអត់មានសិទ្ធិទៅសួរទេ គឺជានារីធម្មតា អ្នកផ្ទះ មេផ្ទះធម្មតា កិច្ចការអីទាំងអស់គឺនៅលើស្រុក ចាស ខ្ញុំជម្រាប។

**ស៖** អ៊ីចឹង លោកស្រីមិនខ្វល់ចង់ដឹងថាអ្នកដែលបាត់ខ្លួនហ្នឹងហេតុអី លោកស្រីមិនៗព្យាយាមចង់ដឹងទេថាតើមានរឿងអីកើតឡើងចំពោះអ្នកទាំងអស់ហ្នឹង លោកស្រីមិនខ្វល់អីទាំងអស់ហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** ចាស អារឿងខ្វល់ មានហើយ ប៉ុនថាភារកិច្ចខ្ញុំ សិទ្ធិខ្ញុំសួរបានត្រឹមណា ហើយសិទ្ធិរបស់ខ្ញុំ វាអស់សិទ្ធិនៅក្នុងស្រុក ឬអត់មានទៅសួរគេបានទេ បើខ្លាចតែសួរទៅវាពាក់ព័ន្ធដល់ខ្ញុំទៀត។ យើងចង់ដឹងអីរឿងគេ គេអ្នកដោះស្រាយ ដូច្នេះខ្ញុំប្រយ័ត្នដែរ ការពារជីវិតខ្ញុំដែរ ដូច្នេះខ្ញុំអត់សួរ។ ចាស មានប៉ុណ្ណឹង។

**ស៖** អ៊ីចឹងលោកស្រី គឺនៅពេលហ្នឹងគឺថាលោកស្រីគិតតែពីខ្លួនឯងទេមែនទេ ឬក៏គេណែនាំអប់រំមកថាឲ្យត្រូវតែធ្វើតែអ៊ីចឹង គិតតែខ្លួនឯង អត់គិតពីរឿងអ្នកផ្សេង?

[១០:០២:៥២]

**ឆ៖** ចាស ព្រោះពេលយើងអស់សិទ្ធិហើយ អត់មានត្រូវការទៅសួរទេ ត្រូវគិតថាខ្លួនឯងដូចនៅជានារីធម្មតា ធ្វើការធ្វើងារ ផ្ទះសម្បែងធម្មតា បាយរួមនៅជាមួយអ៊ីចឹងទៅ តែយើងសិទ្ធិទៅដេញដោលគេ វាមិនមានសិទ្ធិទេ មិនប៉ានសិទ្ធិទេ។

**ស៖** លោកស្រី តើលោកស្រីគិតថា តើក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង មានបញ្ហាណាមួយដំណើរការមិនល្អអីទេ ហើយបើសិនជាមាននោះ តើបញ្ហាអីដែរ?

**ឆ៖** ចាស ចំពោះខ្ញុំផ្ទាល់ ដូចជារកឆ្លើយមិនឃើញ ព្រោះវាភ្លេចភ្លាំងអស់ហើយ ប៉ុន្តែខ្ញុំចាំអារឿងសិទ្ធិការពារខ្លួន និងសិទ្ធិមិនប៉ានសួរគេ ព្រោះយើងអត់មានសិទ្ធិ ប៉ុណ្ណឹង។ តែយ៉ាងម៉េចទៀតខ្ញុំដូចជាមិនយល់ ហើយក៏ចាំមិនបាន។

**ស៖** បាទ សូមអរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែខ្ញុំសូមការបញ្ជាក់ពីសហព្រះរាជអាជ្ញាបន្តិច។ លោក ឌេល លីសាក់ អម្បាញ់មិញនេះ លោកស្រីហាក់ -- លោកដូចជានិយាយថា លោកអាចផ្តល់ជូនភាគីនូវឯកសារជាក្រដាសនៃកំណត់ហេតុស្តាប់ចម្លើយពីរ ដែលប្រហែលជាមានភាពពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង។ តើលោកអាចបញ្ជាក់បានទេ ថាឯកសារកូពីហ្នឹង ថតចម្លងហ្នឹង អាចផ្តល់ជូននៅថ្ងៃនេះបានទេ លោក ឌេល លីសាក់?

[១០:០៤:៥៧]

**លោក ឌេល លីសាក់៖**

ចៅក្រម ឡាវែន ខ្ញុំនឹងផ្តល់ចម្លើយជូនលោកចៅក្រមបន្ទាប់ពីពេលសម្រាកនេះ។ ឥឡូវនេះខ្ញុំកំពុងតែឆែកមើលអ៊ីម៉ែលរបស់ខ្ញុំ ប៉ុន្តែខ្ញុំអត់ទាន់មានចម្លើយត្រឡប់មកវិញពីអ៊ីម៉ែលរបស់ខ្ញុំទេ។ ដូច្នេះខ្ញុំនឹងផ្តល់ចម្លើយជូនលោកចៅក្រមក្រោយពីឈប់សម្រាកនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលតទៅរហូតដល់ម៉ោងដប់ម្ភៃនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់និងម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះ គឺប្រគល់ទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍។ ខ្ញុំគិតថាប្រហែលជាដល់ពេលឈប់សម្រាកថ្ងៃត្រង់ទើបយើងអាចចែករំលែកនូវឯកសារជាក្រដាស ព្រោះថាយើងមានឯកសារចំនួន១៦ទំព័រ ដែលវាមានរយៈពេលវែងដែរក្នុងការកូពីចែកជូន។ ដូច្នេះ ខ្ញុំគិតថា ដល់ពេលសម្រាកថ្ងៃត្រង់ទើបយើងអាចចែកបានដល់ភាគីនានា។

**ប្រធានអង្គជំនុំ៖**

អរគុណនូវព័ត៌មាននេះ។

សូមអញ្ជើញលោកមេធាវី ក្រុមមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមានសំណួរខ្លះៗដែលខ្ញុំចង់សាកសួរលោកស្រីនៅព្រឹកនេះ ហើយប្រហែលជាត្រូវបន្តដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយទៀត។ មុនពេលឈប់សម្រាកលោកស្រីបានឆ្លើយទៅនឹងសំណួរមួយចំនួនទាក់ទងទៅនឹងកូនប្រុស កូនពៅរបស់លោកស្រីដែលថាកើតនៅឆ្នាំម្សាញ់។ ចំណែកកូនបងបំផុតរបស់អ្នកស្រីកើតនៅឆ្នាំ១៩៧៦២ ប៉ុន្តែខ្ញុំមិនច្បាស់ ជាពិសេសតាមរយៈការបកប្រែជាភាសាអង់គ្លេសនៅចម្លើយរបស់លោកស្រី។ ខ្ញុំចង់ដឹងថា តើកូនប្រុស ឬក៏កូនស្រី ដែលលោកស្រីថាកើតឆ្នាំ(១៩)៦២? ព្រោះមានកូនប្រុសរបស់លោកស្រីមួយរូបផ្តល់ចម្លើយថាគាត់កើតឆ្នាំ៦២ ដូច្នេះខ្ញុំចង់បញ្ជាក់ថាតើ កូនដែលកើតឆ្នាំ៦២ ហ្នឹងកូនប្រុស ឬកូនស្រី?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស កើតឆ្នាំ១៩៦២ គឺកូនប្រុស។

**ស៖** ចុះកូនស្រីរបស់លោកស្រីឈ្មោះ សុខ នី ហៅ ចាន់ នោះ តើគាត់កើតនៅឆ្នាំណាដែរ?

**ឆ៖** ខ្ញុំអត់សូវចាំទេ ព្រោះវាកើតឆ្នាំ បើខ្មែរយើងកើតឆ្នាំរោង ដល់ទៅសាកល ខ្ញុំមិនចាំ។

**ស៖** ខ្ញុំកើតឆ្នាំរោងដែរ គឺឆ្នាំ៦៤។ នៅក្នុងចម្លើយរបស់លោកស្រីជាមួយនឹងអ្នកស៊ើបអង្កេតសហចៅក្រមស៊ើបអង្កេត លោកស្រីនិយាយថា គឺកូនស្រីរបស់លោកស្រីដែលលោកស្រីយកទៅឆ្នាំហុកជាងហ្នឹងទៅក្នុងព្រៃ។ អ៊ីចឹងតើកូនស្រីហ្នឹងកើតនៅឆ្នាំ៦៤ មែនទេ?

[១០:៣៤:៣៣]

**ឆ៖** ចាស ខ្ញុំអត់ចាំឆ្នាំទេ ខ្ញុំចាំតែឆ្នាំខ្មែរហ្នឹង កើតឆ្នាំរោង ដឹងតែប៉ុណ្ណឹង។ តែឆ្នាំសាកល ខ្ញុំអង្គាល់ហ្នឹងគឺខ្ញុំអត់ចេះ ដឹងថាឆ្នាំនេះ ឆ្នាំនោះទេ។ ដឹងថាកូនហ្នឹងវាបី-ពីរ ទៅរាប់ទៅត្រូវឆ្នាំរោង ចាស ខ្ញុំបញ្ជាក់ប៉ុណ្ណឹង។

**ស៖** ខ្ញុំចប់បញ្ជាក់ឲ្យច្បាស់ថា តើគឺកូនស្រីរបស់ស្រីហ្នឹងឬ ដែលលោកស្រីយកតាម នៅពេលដែលលោកស្រីចូលទៅព្រៃម៉ាគី ឆ្នាំ៧០ តើជាកូនស្រីម្នាក់ហ្នឹងមែនទេ?

**ឆ៖** ចាស ខ្ញុំពេលនោះ គឺមានតែកូនស្រីមួយដែលតាម។ កូនប្រុសគឺបែក វង្វេងគ្នា បែកមិនដឹងថា -- ដល់ក្រោយមកបានជួបគ្នា។ បែកគ្នានៅកំពង់ចាម។

**ស៖** អ៊ីចឹង កូនស្រីច្បងរបស់លោកស្រីកើតឆ្នាំ៦៤ ហើយលោកស្រីនាំទៅព្រៃជាមួយ។ តើកូន

ស្រីរបស់លោកស្រីហ្នឹង នៅជាមួយលោកស្រីរហូតដល់ពេលរំដោះក្នុងឆ្នាំ៧៥ មែនទេ?

**ឆ៖** ចាស នៅរហូត។ បើកូនស្រីគឺនៅរហូត ជាមួយម៉ែរហូត ដល់ឆ្នាំរំដោះឆ្នាំ៧៥ បានមានការងារធ្វើតាម ចែកតាមផ្នែកសហករណ៍ ឬក៏ទៅធ្វើការតាមកុមារ ធ្វើតាមកន្លែងកុមារ។

**ស៖** ហើយមានមួយពេលនោះ ចន្លោះក្នុងឆ្នាំ៧៥ ដល់ឆ្នាំ៧៩ តើកូនស្រីរបស់លោកស្រីហ្នឹងបានធ្វើការនៅក្រសួងសង្គមកិច្ចដែរមែនទេ?

**ឆ៖** ចាស ឆ្នាំ -- ធ្វើការតាំងពីនុំងមក ទាល់មកសព្វថ្ងៃខាងសង្គមកិច្ច ធ្វើឆ្មប នៅស្រុកអន្លង់វែង ប៉ុន្តែនៅតាមឃុំមួយផ្សេងទៀត។

[១០:៣៧:២៦]

**ស៖** តើក្នុងពេលឥឡូវហ្នឹង គាត់នៅតែធ្វើជាពេទ្យនៅអន្លង់វែង អ៊ីចឹងមែនទេ?

**ឆ៖** ចាស ឥឡូវហ្នឹងនៅតែធ្វើការពេទ្យអន្លង់វែង ជួយសង្គ្រោះប្រជាជន ខាងពេទ្យឆ្មប នៅតាមឃុំ។

**ស៖** ហើយកូនប្រុសច្បងរបស់លោកស្រី តាមដែលខ្ញុំដឹង គាត់នៅ គាត់រស់នៅអន្លង់វែងដែរ អ៊ីចឹងមែនទេ?

**ឆ៖** ចាស កូនប្រុស គឺស្លាប់៤ឆ្នាំ ៥ឆ្នាំហើយ កូនប្រុសបង។ ៥ឆ្នាំហើយ។

**ស៖** ខ្ញុំសូមទោសអ្នកស្រីសាក្សី ខ្ញុំដឹងអំពីបញ្ហានេះដែរ។ នៅក្នុងចម្លើយរបស់អ្នកស្រីៗបាននិយាយថា អ្នកស្រីចូលបដិវត្តន៍ក្នុងឆ្នាំ១៩៦៩ ប៉ុន្តែនៅខែតុលា ៧០ អ្នកស្រីចូលព្រៃជាមួយកូនស្រីរបស់អ្នកស្រី តាមការអំពាវនាវរបស់សម្តេចព្រះវររាជបិតា។ តើអ្នកស្រីអាចពន្យល់បានទេ ឬក៏តើអ្នកស្រីចាំទេ ថាតើហេតុអ្វីទើបការហៅរបស់សម្តេចឪហ្នឹង ធ្វើឲ្យអ្នកស្រីចូលទៅតាមការអំពាវនាវនោះ?

**ឆ៖** ចាស អង្កាល់ហ្នឹង គឺសម្តេចឪបានអំពាវនាវហើយ ខ្ញុំក៏ឃើញអ្នកភាគច្រើន គេទៅ ក៏ខ្ញុំក៏លះបង់ទៅតាមបងប្អូនដែលគេទៅចូលព្រៃទាំងអស់គ្នា ក៏ទៅជាមួយនឹងគេទៅ។

**ស៖** ប៉ុន្តែអ្នកស្រីនិយាយរួចហើយថា អ្នកស្រីចូលបដិវត្តន៍នៅឆ្នាំ៦៩ គឺមួយឆ្នាំមុន។ ប៉ុន្តែហេតុអ្វីបានជាអ្នកស្រីជឿជាក់លើការអំពាវនាវរបស់សម្តេចឪ ហើយអ្នកស្រីចូលព្រៃម៉ាគីនោះ?

[១០:៤០:១៨]

**ឆ៖** ចាស ការនៅកំណត់ហេតុខ្ញុំនិយាយអ៊ីចឹងមែន ប៉ុន្តែខ្ញុំនៅនឹងផ្ទះ នៅរកស៊ីធម្មតាជាមួយប្រជាជនធម្មតា ជាមួយកូនជាមួយអីធម្មតា។ ដល់ពេលសម្តេចឪប្រកាសបងប្អូននៅស្រុកភូមិហ្នឹង គេ

បបួលថាទៅ -- "ឥឡូវសម្ដេចឪយើងត្រូវប្រកាសឲ្យចូលព្រៃម៉ាគី"។ ដូច្នេះក៏បងប្អូនទាំងអស់គាត់ទៅ ខ្ញុំក៏ទៅនឹងគេនឹងឯងទៅ ជាមួយគេជាមួយឯងអ៊ីចឹងទៅ។

**ស៖** សម្ដេចឪសីហនុ បានចូលទៅព្រៃម៉ាគីនៅក្នុងឆ្នាំ៧៣។ តើអ្នកស្រីមានវត្តមានទេ នៅពេលដែលសម្ដេចឪចូលទៅព្រៃម៉ាគីនោះ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំសូមឆ្លើយថា ខ្ញុំអត់យល់ពីរឿងវត្តមានទេ។ មិនដឹងវត្តមានហ្នឹងរបៀបម៉េចមានន័យថាម៉េចខ្ញុំមិនយល់។ គ្រាន់តែថា បងប្អូន -- អ៊ីចេះកសិករដល់វាត្រូវការថា "ហ៎! សម្ដេចឪប្រកាសថាចូលព្រៃម៉ាគី កូនចៅទាំងអស់ត្រូវតែចូល"។ អ្នកស្រុកក៏ត្រូវរៀបចំចូលទៅតាមសម្ដេចឪ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាមានបញ្ហានៅក្នុងការបកប្រែ ខ្ញុំនឹងបញ្ជាក់សំណួរខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរអ្នកស្រីអំពីព្រះរាជទស្សនកិច្ចឆ្នាំ៧៣ របស់សម្ដេចឪសីហនុ ចូលទៅក្នុងព្រៃ ដែលនៅទីនោះ គាត់ជួបជាមួយ ប៉ុល ពត, ខៀវ សំផន តើអ្នកស្រីនៅក្នុងពិធី ឬក៏អ្នកស្រីបានចូលរួមនៅក្នុងពិធីដែលសម្ដេចឪយាងទៅធ្វើទស្សនកិច្ចឆ្នាំ៧៣ ដែរឬទេ?

**ឆ៖** ចាស ពេលសម្ដេចឪទៅធ្វើពិធីនៅក្នុងព្រៃហ្នឹង ខ្ញុំអត់បានទៅចូលរួមទេ ហើយខ្ញុំនៅជាមួយប្រជាជនទេ។ ខ្ញុំអត់បានដឹងថាសម្ដេចឪទៅឆ្នាំណាអីឆ្នាំណា។ ខ្ញុំជម្រាបថា ខ្ញុំវាភ្លេចបាត់ហើយ មិនចាប់អារម្មណ៍រឿងថា ស្ដេចឪយាងទៅព្រៃពេលណា គឺមិនចាំ។

[១០:៤៣:៣៥]

**ស៖** ខ្ញុំនឹងទុកបន្តនៅពេលខាងក្រោយទៀត ប៉ុន្តែឥឡូវខ្ញុំបន្តទៅឆ្នាំ៧៦វិញ។ តើអ្នកស្រីចាំទេថា សម្ដេចឪបានទៅធ្វើព្រះរាជទស្សនកិច្ចនៅកំពង់ចាមនៅក្នុងឆ្នាំ៧៦ ហើយមានការធ្វើពិធីលៀងសាយ-ភោជន៍ ដើម្បីស្វាគមន៍សម្ដេចឪនៅពេលនោះ។ តើអ្នកស្រីចាំថាមានទេ?

**ឆ៖** ចាស ដូចខ្ញុំភ្លេចបាត់ហើយ រកនឹកមិនឃើញ មិនដឹងថា ឥឡូវសម្ដេចឪយាងទៅមែន ឬយ៉ាងណា។ ភ្លេចបាត់ហើយ រកនឹកមិនឃើញទេ។

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់អ្នកស្រី ដើម្បីឲ្យអ្នកស្រីហ្នឹងឃើញ។ E3/5294, អង់គ្លេសមានលេខ 00360119, បារាំងមានលេខ 00367801 និងខ្មែរមានលេខ 00348836។ "សំណួរ៖ តើអ្នកស្រីដឹងអំពីសម្ដេចឪទៅកំពង់ចាមនៅឆ្នាំ៧៦ទេ? អ្នកស្រីឆ្លើយថា៖ ខ្ញុំដឹងថា មានការជប់លៀង

ទទួលសម្តេចនរោត្តមសីហនុ តែខ្ញុំមិនបានចូលរួមទេ”។ តើអ្នកស្រីអាចនឹកឃើញទេ?

**ឆ៖** ចាស វាដល់ពេលអ៊ីចឹងការភ្លេចភ្លាំងរបស់ខ្ញុំវាអាចលើខ្វះអ៊ីចឹង។ ជួនកាល ក៏នឹកឃើញ ជួនកាល ក៏នឹកមិនឃើញ។ អ៊ីចឹងបានខ្ញុំឆ្លើយថា ខ្ញុំនឹកមិនឃើញទេ វាភ្លេចបាត់ទៅហើយ។ ឥឡូវនេះ ទាល់តែអានជាសម្តី -- ឯកសារមក គ្រាន់តែយល់ថា ប្រហែលជាអ៊ីចឹងមែនហ្នឹង ព្រោះខ្ញុំវាភ្លេចទៅ។

**ស៖** អ្នកស្រី នៅក្នុងសំណុំរឿងគឺមានការបញ្ជាក់ថា សម្តេចឪបានទៅការដ្ឋានជាច្រើននៅក្នុង កម្ពុជាប្រជាធិបតេយ្យ ប្រហែលជាប្រាំទៅប្រាំមួយដង។ តើអ្នកស្រីចាំអំពីការធ្វើទស្សនកិច្ចផ្សេងៗ ទៀតដែរឬទេ? គឺថាទៅកន្លែងដែលអ្នកស្រីធ្វើការ ឬកន្លែងដែលអ្នកស្រីរស់នៅនោះ?

**លោក ខេល លីសាក់៖**

លោកប្រធាន ប្រសិនបើមេធាវីចង់សួរ គឺអត់មានបញ្ហាទេ ប៉ុន្តែគួរតែមានបញ្ជាក់អំពីសំណុំរឿង ឯកសារ នៅក្នុងសំណុំរឿងដែលនិយាយអំពីការធ្វើទស្សនកិច្ច។ គាត់អាចនិយាយអំពីទស្សនកិច្ចជាក់លាក់ ឬក៏ឯកសារជាក់លាក់ ឬក៏លេខយោងជាក់លាក់ណាមួយ ដែលខ្ញុំគិតថាវាមិនមានបញ្ហាទេ បើគាត់ធ្វើដូច្នេះ។ ប៉ុន្តែគ្រាន់តែនិយាយថា មាននៅក្នុងសំណុំរឿង វាជាការនាំមុខសាក្សីរួចទៅហើយ។

[១០:៤៧:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងផ្តល់នូវឯកសារយោងជាក់លាក់។ លោកប្រធាន គឺ E3/7-- ខ្ញុំនឹងបន្តនៅពេលមុខបន្តិច ទៀត ប៉ុន្តែឥឡូវនេះខ្ញុំសូមរំឭកការចងចាំរបស់អ្នកស្រីបន្តិច។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកស្រីនិយាយអំពីការទៅចុះទៅកំពង់ចាមនៅឆ្នាំ៧៦ ហើយមានការជប់លៀង អាចមាន ឬក៏មិនមាន។ ប៉ុន្តែអ្នកស្រីចាំអំពីការធ្វើទស្សនកិច្ចដែលសម្តេចឪបានទៅកន្លែងផ្សេងទៀត នៅក្នុង ប្រទេសដែរឬទេ គឺចន្លោះពីឆ្នាំ៧៥ ដល់៧៩?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ខ្ញុំ ចាស ខ្ញុំដូចអត់បានចាំទេ ដែលសម្តេចឪយាងទៅ។ គិតពីនោះមកដល់ឥឡូវ វាការភ្លេច ភ្លាំងវាច្រើន ហើយការនិយាយក៏ខ្ញុំនិយាយក្នុងការពិត តែបើខ្ញុំដឹង ខ្ញុំនិយាយថាខ្ញុំដឹង។ បើខ្ញុំភ្លេច និយាយ ថាខ្ញុំភ្លេច។ ពីនោះមកដល់នេះ វាគិតពីអាយុ គិតពីអាយុនិងឆ្នាំនោះ វា -- ការវ័យរបស់ខ្ញុំ វាភ្លេចច្រើន។ ការនិយាយ ក៏វាមិនប៉ិនប្រចុយដែរ កន្លែងខ្លះទាល់ច្បាស់ បានខ្ញុំនិយាយ។ បើមិនច្បាស់ ខ្ញុំមិននិយាយ។

សម្ដេចឪយាងទៅពេលណាក៏ ដូចថាខ្ញុំមិនៗចាំ។ និយាយមួយម៉ាត់ថាមិនចាំ។

[១០:៤៩:១៧]

**ស៖** អត់បញ្ហាទេ អ្នកស្រីសាក្សី។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីពេលពីឆ្នាំ៧០ ដល់៧៥ ដែលអ្នកស្រីនិងកូននៅក្នុងព្រៃម៉ាគី។ នៅព្រឹកមិញនេះ អ្នកស្រីបានឆ្លើយទៅនឹងសំណួរដែលនិយាយអំពីឈ្មោះវន -- អំពី -- និយាយអំពីគ្រាប់បែកដែលទម្លាក់ពីលើយន្តហោះមក។ ក្នុងពេលដែលទម្លាក់គ្រាប់បែកទៅលើព្រៃម៉ាគីដោយកងទ័ពអាកាសអាមេរិក តើកូនស្រីរបស់អ្នកស្រីនៅជាមួយអ្នកស្រីដែរឬទេ? តើអ្នកស្រីនិងកូនរបស់អ្នកស្រីមានៗជួបប្រទះការទម្លាក់គ្រាប់បែកពីយន្តហោះ បេ៥២ ដែរឬទេ?

**ឆ៖** ចាស ពេលហ្នឹងគឺវាជួបប្រទះ ហើយពេលទម្លាក់ ក៏វាទម្លាក់ខ្លាំងដែរ គឺថាមូលដ្ឋាននៅតំបន់១៣០ វាទម្លាក់ក្នុងព្រៃហ្នឹង ហើយបងប្អូនទាំងអស់ ទាំងខ្ញុំទាំងគេហ្នឹង ក៏រត់គេចទៅ ក៏ជីករណ្ដៅជ្រកអីចឹងដែរ តែការជ្រកវាមិនដូចការរត់ទេ រត់វាផុតទៅហើយ វាលែងភ័យ។ អានៅក្នុងរណ្ដៅបើត្រូវមួយគ្រាប់ ពីរគ្រាប់ទៅ វាត្រូវតែងាប់អស់ ដូច្នេះចេះតែរត់ទៅ ដឹកដៃកូនរត់ ជ្រកតាមព្រៃ តាមអីអីចឹង ជួនកាលវាមើលមិនឃើញ ក៏វាមិនទម្លាក់ដែរ។ អាកន្លែងខ្លះ ក៏វាទម្លាក់តាមភូមិ ខ្ទេចខ្ទីអស់អីចឹងទៅ អានេះខ្ញុំនិយាយរឿងជាក់ស្ដែង ហើយនិងរឿងចាំខ្លះ។ រឿងអាម៉េចទៀត គឺខ្ញុំមិនសូវដឹងទេ ដឹងថាទើបតែជាក់ស្ដែងគឺវាទម្លាក់អីចឹងមែន។ ផ្ទះប្រជាជនត្រូវបាក់បែកខ្ទេចខ្ទី ក៏ទម្លាក់ទៅ អាបេ៥២ ហ្នឹងវាទម្លាក់គ្មានពិចារណាទេ។ សូមអស់។

**ស៖** តើអ្នកស្រីបានឃើញការស្លាប់ច្រើនទេដោយសារការទម្លាក់គ្រាប់បែកនេះ?

**ឆ៖** ចាស ពេលខ្លះ អ្នកខ្លះដែលនៅក្នុងរណ្ដៅ ជួនខ្លះងាប់អស់ទាំងគ្រួសារ។ អាខ្លះក៏រត់គេចផុតទៅ អាខ្លះក៏នៅក្នុងរណ្ដៅ ងាប់ក្នុងរណ្ដៅក៏មាន វាមានងាប់ច្រើនដែរ ទម្លាក់គ្រាប់បែក មិនមែនធម្មតាឯណា គោក្របីងាប់ដូចគេហាល មិនមែនធម្មតាទេ គ្រាប់បែក។ អានេះខ្ញុំចាំៗខ្លះ អានេះចិត្តចាំហ្នឹងគឺយ៉ាងម៉េច ចាំមកពីការស្មារតីវាជាក់ស្ដែង វាបានរត់ដឹកដៃកូនរត់មែន អត់មានថា អ៊ូពន្លើសខ្វះអីទេ គឺខ្ញុំនិយាយជាក់ស្ដែង។ អានេះ វាជាក់ស្ដែងហើយ ខ្ញុំសូមអស់ប៉ុណ្ណឹងហើយ។

[១០:៥២:៣៣]

**ស៖** សូមអរគុណអ្នកស្រី។ ខ្ញុំមានសំណួរបន្ថែមទៀត អំពីរយៈពេលឆ្នាំ៧០ ដល់ ៧៥។ កូនប្រុសរបស់អ្នកស្រីគឺ កែ ពេជ្រវណ្ណៈ ឯកសារE3/35។ បាទ ផ្ដល់សំណួរទាក់ទងនឹងរយៈពេលនោះ ហើយខ្ញុំសូមអាននូវសំណួរចម្លើយរបស់គាត់ ហើយខ្ញុំសួរអ្នកស្រី ថាតើអ្នកស្រីចាំអ្វីទេអំពីអ្វីដែលគាត់

ឆ្លើយនោះ?

លោកប្រធានគឺ ឯកសារ E3/35, ERN ភាសាអង់គ្លេសមានលេខ 00346148, ខ្មែរមានលេខ 00340568 និងបារាំងមានលេខ 00367720។ គេសួរទៅដល់កូនប្រុសរបស់អ្នកស្រីថា "តើមានជនបរទេសមកការដ្ឋានជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដែរឬទេ?" ហើយកូនប្រុសរបស់អ្នកស្រីនិយាយថា៖ "ខ្ញុំឃើញយួន គឺ តាន់ វ៉ាន់ដុង។ យួន បានមកម្តង ប៉ុន្តែនៅពេលនោះ ខ្ញុំបម្រើតែ ហើយនិងម៉ាស្សាឲ្យគាត់។ នៅពេលដែលពួកគាត់មក ខ្ញុំឃើញ ប៉ុល ពត ប្រជុំជាមួយពួកយួន។ ខ្ញុំមិនដឹងថាអ្នកបកប្រែនោះជាអ្នកណានោះទេ។ ក្នុងពេលប្រជុំ ខ្ញុំឮសួរមនុស្សពីរនាក់និយាយអំពីការចូលរួមជាមួយបក្សឥណ្ឌូចិន ប៉ុន្តែ ប៉ុល ពត បដិសេធមិនចូល។ បុគ្គលទាំងពីរនាក់និយាយជាមួយគ្នាដោយម៉ឺងម៉ាត់ ហើយខ្ញុំនៅទីនោះដែរនៅពេលនោះ"។ លោកស្រីសាក្សី តើកូនប្រុសរបស់អ្នកស្រី ធ្លាប់ប្រាប់អ្នកស្រីថាតើគាត់បានស្តាប់ឮការសន្ទនារវាង ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ពីររបស់វៀតណាម គឺយួន និង ផាន់វ៉ាន់ -- គឺ ឡេ យន់ និង ផាន់ វ៉ាន់ដុង នោះដែរឬទេ?

**ឆ៖** ចាស អារឿងកូន ខ្ញុំសូមជម្រាបថា ពេលនោះកូនអត់បាននៅជាមួយខ្ញុំទេ កូននៅតាមយោធា ឬក៏ទៅតាមឪពុករបស់កូន តែចំណែកខ្ញុំៗអត់ដឹងទេអារឿងកិច្ចការ ហើយកូនក៏មិនបាននិយាយប្រាប់ខ្ញុំពីរឿងអីៗដែរ និយាយតែពីរឿងនៅទំនប់១មករា ធ្វើការជាមួយបងប្អូន។ អានេះគឺចែកគ្នាដាច់ព្រោះមិនបាននៅជាមួយគ្នា។ ដូចខ្ញុំជម្រាបខាងលើអ៊ីចឹង ខ្ញុំថាខ្ញុំ គ្រួសារនៅផ្សេង ខ្ញុំនៅផ្សេង។ កូនក៏នៅផ្សេង កូនស្រីខ្ញុំដែលធំហើយក៏មិនបាននៅជាមួយគ្នា នៅដោយខ្លួន នៅតែកូនតូចទេដែលនៅជាមួយ អាធំៗគឺនៅតាមសហករណ៍ ឬក៏ទៅរៀនសូត្រកន្លែងផ្សេងៗទៅ។ ឯកូនដល់និយាយពីរឿងលោកបានលើកនេះ ខ្ញុំអត់ៗដឹងទេ អត់ដឹងអត់ឮទេ ព្រោះខ្ញុំអត់បានជួបកូនទេ កូនក៏មិនបាននិយាយប្រាប់អារឿងអ៊ីចឹងៗដែរ។

[១០:៥៦:០៦]

**ស៖** ខ្ញុំដឹងថាអ្នកស្រីមិននៅជាមួយគាត់នៅពេលនោះទេ។ ប៉ុន្តែខ្ញុំគិតថាវាជាការប្រជុំដ៏សំខាន់នៅក្នុងព្រៃ។ ប៉ុន្តែអ្នកស្រីប្រាកដថា គាត់មិនដែលប្រាប់អ្នកស្រីនៅពេលក្រោយមកទៀត អាចថាក្រោយឆ្នាំ៧៥ ក្រោយឆ្នាំ៧៩ អំពីការប្រជុំរវាងមេដឹកនាំជាន់ខ្ពស់វៀតណាម ជាមួយនឹង ប៉ុល ពត នោះ គាត់អត់ដែលនិយាយទេ?

**ឆ៖** ចាស មិន -- កូនមិនដែលនិយាយប្រាប់ទេ អារឿងអ៊ីចឹងៗខ្ញុំមិនដឹងទេ។ រឿងនិយាយ

ព្រោះកូនមិនបាននិយាយប្រាប់ នៅឆ្ងាយពីគ្នា ដល់អ៊ីចឹងទៅខ្ញុំអត់ដឹងរឿងទេ រឿងប្រជុំរឿងអីរឿងគេប្រជុំរឿងអី វាមិននិយាយប្រាប់ខ្ញុំផង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ តើពាក្យ “បក្សឥណ្ឌូចិន” អ្នកស្រីនឹកឃើញអំពីអ្វីដែរទេ?

**ឆ៖** ចាស “បក្សឥណ្ឌូចិន” ខ្ញុំមិនបាននឹកឃើញទេ ព្រោះកន្លងមក គឺដឹងថាធ្វើការងារខាងបងប្រធានគាត់និយាយអំពីឧទ្ទេសនាមការងាររបស់យើងនៅក្នុងស្រុក តែភ្ញៀវមកពីបរទេស ខ្ញុំអត់ក្តាប់បានទេ។

**ស៖** អរគុណអ្នកស្រី។ កូនប្រុសរបស់អ្នកស្រីនៅក្នុងទំព័រដដែលក៏បាននិយាយប្រាប់អ្នកស៊ើបអង្កេតអំពី តាធុច គឺ កុយ ធួន នោះ។ តើអ្នកស្រីចាំអំពី កុយ ធួន ទេ? តើអ្នកស្រីស្គាល់ កុយ ធួន ទេនៅពេលនោះ?

**ឆ៖** ស្គាល់! កុយ ធួន ខ្ញុំស្គាល់ តែការងាររបស់គាត់ផ្សេង ខ្ញុំគ្រាន់តែស្គាល់ជាមិត្ត ជាភក្តិរបស់គាត់ប៉ុណ្ណឹង។ ឯស្គាល់ជ្រៅតទៅទៀត ខ្ញុំអត់ស្គាល់ទេ។

**ស៖** តើប្តីរបស់អ្នកស្រីធ្លាប់និយាយអំពី កុយ ធួន គឺខ្ញុំចង់និយាយអំពីចន្លោះឆ្នាំ៧០ ដល់៧៦ តើប្តីអ្នកស្រីដែលនិយាយអំពី កុយ ធួន ទេ?

**ឆ៖** ចាស កន្លងមកៗខ្ញុំច្រើនតែនិយាយថា តាមខ្ញុំចាំទេ ពីម្សិលមកថ្ងៃនេះ ខ្ញុំចាំថារឿងទាំងអស់នេះការងារធំៗ គ្រួសារមិនដែលនិយាយប្រាប់មកខ្ញុំទេ និយាយតែការងារណារាប់អានជាគ្រួសារជាកូនជាអីហ្នឹងមកលេងជាធម្មតា។ កិច្ចការដែលធំៗអ៊ីចឹង គឺអត់ដែលនិយាយ។ ហើយដូចជា កុយ ធួន អ៊ីចឹងជាមេ -- ហៅថាមិត្តភក្តិអ៊ីចឹង មករាប់អានទាក់ទាក់ទាក់អ៊ីចឹង។ ប៉ុន្តែក្នុងការការងាររបស់គាត់មិនដែលនិយាយ ការណ៍មិនដែលនិយាយប្រាប់ខ្ញុំទេ។

[១១:០០:១០]

**ស៖** តើនៅពេលនោះ នៅពេលនោះ តើអាចទេ អាចអ្នកស្រីឮពីអ្នកដទៃទេថា កុយ ធួន គាត់គ្រោងនឹងធ្វើរដ្ឋប្រហារប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ។ តើអ្នកស្រីធ្លាប់ឮទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ អត់ដឹង ក៏អត់មានអ្នកណានិយាយប្រាប់ខ្ញុំដែរ អត់ដឹងទេ ចាស។

**ស៖** តើអ្នកស្រីចាំទេនៅក្នុងបណ្តាឆ្នាំទាំងអស់នោះ គឺមេដឹកនាំភូមិភាគបូព៌ា សោ ភឹម តើអ្នកស្រីស្គាល់គាត់ទេ សោ ភឹម?

**ឆ៖** ចាស ខ្ញុំអត់ដែលស្គាល់ទេ សោ ភឹម នោះមិនដែលស្គាល់។

**ស៖** តើអ្នកស្រីធ្លាប់ឮប្តីរបស់អ្នកស្រីនិយាយអំពីឈ្មោះ សោ ភឹម ទេ?

**ឆ៖** ចាស ខ្ញុំបញ្ជាក់ពីរបីដងហើយថា រឿងការងាររបស់គាត់ គាត់មិនដែលនិយាយទេ រឿងទាក់ទងជាមួយមេធំៗមិនដែលប្រាប់ខ្ញុំ ថា អើរឿងនេះ ឈ្មោះនេះ នៅភូមិភាគនេះគឺ មិនដែលសោះ។ តាមខ្ញុំចាំគឺអ៊ីចឹង ការងារវាមានលក្ខខណ្ឌ គឺថាការលាក់ការណ៍ គឺសូម្បីតែប្រពន្ធ សូម្បីតែកូន ក៏មិនដែលនិយាយទេ រឿងការងារមានលក្ខខណ្ឌរបស់គេ។ ប្រពន្ធក្នុងនាមប្រពន្ធ ការងារក្នុងនាមការងារ អត់មានទៅច្របូកច្របល់ជាមួយគ្នាទេ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ ខ្ញុំសូមអាននូវសម្រង់ដែលដកស្រង់ចេញពីកំណត់ហេតុស្តាប់ចម្លើយកូនប្រុសរបស់អ្នកស្រី ប្រហែលជាអាចជាព័ត៌មានអ្នកស្រីស្តាប់ឮពីកូនប្រុសរបស់អ្នកស្រីក្រោយគឺក្រោយឆ្នាំ៧៥។ គឺឯកសារ E3/35, អង់គ្លេសមានលេខ 00346153, ខ្មែរមានលេខ 00340566 ដល់ 67 និងបារាំងមានលេខ 00367724 ដល់ 25។ គឺជាសម្រង់ដ៏វែងមួយ ដែលខ្ញុំនឹងអានជូនអ្នកស្រីស្តាប់ ហើយខ្ញុំនឹងអានដោយយឺតៗ។ ខ្ញុំនឹងរង់ចាំឲ្យអ្នកបកប្រែគាត់អាចតាមខ្ញុំទាន់។ សំណួរទៅកាន់កូនប្រុសរបស់អ្នកស្រីគឺ “យើងនិយាយអំពីឆ្នាំ៧៧ ដល់ពាក់កណ្តាល ៧៨។ បន្ទាប់មកទៀត តើគេបញ្ជូនលោកទៅណា ហើយគេឲ្យលោកធ្វើអី? ក្រោយមកខ្ញុំបានត្រឡប់មកនៅជាមួយឪពុកខ្ញុំវិញ នៅភូមិស្ទឹង ខាងកើតស្នួល ដែលជាទីបញ្ជាការភូមិភាគកណ្តាល និងភូមិភាគបូព៌ា។ សោ ភឹម ជាប្រធានភូមិភាគ និងជាមេបញ្ជាការភូមិភាគ។ ចំណែកឯឪពុកខ្ញុំជាប្រធានភូមិភាគកណ្តាល និងជាអនុបញ្ជាការយោធាភូមិភាគប្រចាំជួរមុខ។ ការងាររបស់ខ្ញុំគឺបើកឡាន និងការពារឲ្យឪពុករបស់ខ្ញុំ។ សំណួរ៖ ពេលដែលលោកធ្វើការនៅជាមួយឪពុករបស់លោក តើលោកមានឃើញព្រឹត្តិការណ៍អ្វីគួរឲ្យកត់សម្គាល់ដែរឬទេ?” ហើយកូនប្រុសរបស់អ្នកស្រីបានឆ្លើយដូចតទៅនេះ៖ “ខ្ញុំចាំបានថា មានព្រឹត្តិការណ៍បោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា។ ការបោសសម្អាតនោះមានពីរដំណាក់កាល។ ដំណាក់កាលទី១ គឺមានការបញ្ជាពីមជ្ឈិម ឲ្យឃាត់ខ្លួន ហេង សំរិន។ ក្រោយពីទទួលបានព័ត៌មានហើយ ឪពុកខ្ញុំបានទៅជួបជាមួយ សោ ភឹម។ ឪពុកខ្ញុំបានប្រាប់ សោ ភឹម ថា បងថ្នាក់លើឲ្យឃាត់ខ្លួន មិត្តហេង។ សោ ភឹម ឆ្លើយថា បើអ៊ីចឹង ពក ឯងឲ្យអាហេង មកផ្ទះខ្ញុំ។ ក្រោយពីឪពុកខ្ញុំជូនដំណឹងដល់ពូហេង។ ក្រោយមកទៀត គឺបាត់ពូហេង រហូត។ ពេលនោះពូ ហេង សំរិន គាត់ជាប្រធានតំបន់២០ និងជាប្រធានកងពល។ ដំណាក់កាលទី២ គឺការបោសសម្អាតភូមិភាគកងពល និងតំបន់របស់ភូមិភាគបូព៌ា។ ការបោសសម្អាតនោះ គឺមានការបញ្ជាដោយ សុន សេន ផ្ទាល់។ ពេលនោះ សុន សេន បានចុះមកទីបញ្ជាការភូមិភាគ

ដោយផ្ទាល់ ដែលមានក្រុមសន្តិសុខឈុតខ្មៅចំនួនពីរឡានធំមកជាមួយផង។នៅពេលជាមួយគ្នានោះដែរ មានរថក្រោះចំនួនពីរគ្រឿងមកការពារ ដែលដឹកនាំបញ្ជាដោយឈ្មោះ ចិន (មិនដឹងស្លាប់ ឬរស់)។ ពេល សុន សេន មកដល់ គាត់បានបញ្ជាឲ្យឪពុកខ្ញុំហៅមេៗមកប្រជុំ រួចឃាត់ខ្លួនទាំងអស់។ ពេលនោះ សោ ភឹម មិននៅទីនោះទេ។ ខ្ញុំចាំបានថា អ្នកដែលត្រូវបានចាប់ខ្លួនមានចំនួន៤២នាក់ រួមទាំងក្រុមការពារ របស់មេៗផង។ ហេតុការណ៍ចាប់ខ្លួននេះ ខ្ញុំបានឃើញដោយផ្ទាល់ភ្នែក។ ក្នុងចំណោមអ្នកដែលត្រូវ បានគេចាប់ខ្លួននោះ ខ្ញុំស្គាល់មានឈ្មោះដូចជា ពូសុត គណៈតំបន់នៅព្រៃវែង, ពូចាន់ (ហៅតឿ រាងល្អិត) ជាគណៈតំបន់ និងជាអនុភូមិភាគ (តែខ្ញុំមិនដឹងតំបន់ណាទេ)។ តាគឹម ប្រធានកងពលភូមិភាគបូព៌ា។ ការចាប់ខ្លួនអ្នកទាំងអស់នោះ គឺប្រហែលធ្វើឡើងនៅក្នុងឆ្នាំ១៩៧៨"។ លោកស្រីសាក្សីនេះជាការដក ស្រង់ដ៏វែងចេញពីចម្លើយរបស់កូនប្រុសអ្នកស្រី ហើយខ្ញុំដឹងថាហេតុការណ៍នេះវាកើតឡើងពីយូរណាស់ មកហើយ ហើយប្រហែលជាអ្នកស្រីពិបាកក្នុងការចងចាំ ប៉ុន្តែនៅពេលដែលខ្ញុំអានឲ្យអ្នកស្រីបែបនេះ តើវាអាចធ្វើឲ្យអ្នកស្រីនឹកឃើញខ្លះដែរឬទេ?

[១១:០៧:១៤]

**ឆ៖** ចាស ក្នុងហ្នឹងគឺខ្ញុំបានបញ្ជាក់ទៅលោកហើយ រឿងទាំងអស់នេះ ខ្ញុំមិនបានដឹងទេ។ ព្រោះរឿងរៀបចំយ៉ាងម៉េចៗ ព្រោះកូនវានៅជាមួយឪពុក រៀបចំម៉េច បើរឿងនៅការពារ នៅដឹកជញ្ជូន នៅបរឡានអីហ្នឹង ខ្ញុំគ្រាន់តែខ្ញុំដឹង មិនមែនថាមិនដឹងទេ។ ប៉ុន្តែត្រង់ភារកិច្ចរឿងប្រជុំបូព៌ា រឿងរៀបចំ យ៉ាងម៉េចៗ រូបខ្ញុំអត់ដឹងទាល់តែសោះ ខ្ញុំប៉ានសច្ចា គឺខ្ញុំអត់ដឹងទេរឿងទាំងអស់នេះ។

**ស៖** ខ្ញុំមានសំណួរជាក់លាក់មួយទៀត តើប្តីរបស់អ្នកស្រីធ្លាប់និយាយជាមួយអ្នកស្រីអំពី ហេង សំរិន ដែរឬទេ?

**ឆ៖** ចាស គាត់ធ្លាប់ហៅដែរ គាត់ហៅតែ បងៗ បងហេង សំរិនៗ ប៉ុន្តែខ្ញុំអត់ស្គាល់ បង ហេង សំរិន ហ្នឹង មុខម៉េច រាងរៅម៉េច ហើយការងារគាត់ម៉េច ខ្ញុំអត់ដឹង គ្រាន់តែគាត់ហៅរាប់អាន ឮគាត់ហៅ បងៗអីចឹង បងហេង សំរិនៗ។ តែចំពោះខ្ញុំ ខ្ញុំអត់ដែលឃើញគាត់ទេ អត់ដែលស្គាល់គ្នា ទេ។

**ស៖** តើអ្នកស្រីដឹងទេថា កូនប្រុសរបស់អ្នកស្រីធ្លាប់និយាយអំពីអ្វីដែលកើតឡើងនៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យជាមួយកូនស្រីរបស់អ្នកស្រី គឺកូនស្រីអ្នកស្រីដែលយើងទើបនិយាយហើយ។ តើកូនប្រុសរបស់អ្នកស្រី ឬក៏ប្តីរបស់អ្នកស្រីធ្លាប់និយាយអំពីបញ្ហានេះ ជាមួយកូនស្រីរបស់អ្នកស្រីដែល

កើតឆ្នាំ៦៤នោះដែរឬទេ?

**ឆ៖** ចាស ខ្ញុំស្ដាប់ដូចអត់ទាន់ត្រង់ហ្នឹង។ ស្ដាប់ថា កូនស្រី និងកូនប្រុស ហើយឪពុកនេះ? ចង់បញ្ជាក់លោកប្រធានម្ដងទៀត តើនិយាយយ៉ាងម៉េច ខ្ញុំស្ដាប់អត់ទាន់អំមិញនេះ? ខ្ញុំចាប់អត់បាន។

[១១:០៩:៤៧]

**ស៖** ខ្ញុំចង់សួរអ្នកស្រីថា គឺសួរអំពី សោ ភឹម និងហេង សំរិន ហើយខ្ញុំសួរអ្នកស្រីថា តើអ្នកស្រីដឹង ឬក៏អត់? ហើយអ្នកស្រីនិយាយថាអ្នកស្រីអត់ដឹងទេ។ ហើយព័ត៌មានទាំងអស់នេះ គឺយើងទទួលបានពីកូនប្រុសរបស់អ្នកស្រី។ ដូច្នេះ ខ្ញុំចង់ដឹងថា តើអ្នកស្រីធ្លាប់ឮកូនប្រុសរបស់អ្នកស្រីនិយាយជាមួយកូនស្រីរបស់អ្នកស្រីអំពីអ្វីដែលកើតឡើងនៅក្នុងឆ្នាំ៧៨ ដែរឬទេ? ដូច្នេះ ខ្ញុំចង់ដឹងថា តើកូនស្រីរបស់អ្នកស្រីដឹងអំពីអ្វីដែលកូនប្រុសរបស់អ្នកស្រីបាននិយាយនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមមេធាវីលោក វ៉ិចទ័រ កូប៉េ អាចពន្យល់អង្គជំនុំជម្រះបានទេថា តើសំណួរចុងក្រោយប៉ុន្មានសំណួរហ្នឹងវាពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនៅពេលនេះយ៉ាងដូចម្ដេចដែរ?

[១១:១០:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចជម្រាបបានលោកប្រធាន។ គឺថាចំណុចទាំងអស់នេះ ពាក់ព័ន្ធទៅនឹងផ្នែកដ៏សំខាន់ គឺការបោសសម្អាតនៅភូមិភាគបូព៌ា។ អ្វីដែលកើតឡើងនៅភូមិភាគបូព៌ា ដូចដែលយើងទាំងអស់គ្នាបានដឹងហើយ គឺថាប្ដីរបស់សាក្សីគាត់ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការវាយប្រយុទ្ធជាមួយនឹងកងកម្លាំងនៅភូមិភាគបូព៌ា។ ដូច្នេះ ខ្ញុំគិតថាសំណួរអំពីប្រធានបទនេះជូនទៅសាក្សីនេះគឺពិតជាសំខាន់ ហើយពិតជាមានភាពពាក់ព័ន្ធ។ ដូច្នេះ ខ្ញុំគួរតែអាចសួរបាន ដោយសារតែខ្ញុំធ្វើការសួរដេញដោលគាត់អំពីសក្ខីកម្មរបស់កូនប្រុសគាត់។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ។ សំណួរនេះ មិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ហើយខ្ញុំគិតថា នេះជាបទដ្ឋានពីរលោកប្រធាន ព្រោះថាព្រះរាជអាជ្ញា គាត់អាចសួរបានអំពី--

**ប្រធានអង្គជំនុំ៖**

តាំងសំណួរផ្សេងទៀត លោកអាចតាំងសំណួរបាន! ប៉ុន្តែសូមឲ្យចូលទៅក្នុងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។ យើងស្ដាប់ព្រះរាជអាជ្ញាសួរសាក្សីនេះ មិនឮដល់សួររឿងភូមិភាគបូព៌ាទេ។ យ៉ាងច្រើន គឺជុំវិញនូវបញ្ហាស្រុកក្រូចឆ្មារ ហើយនិងស្រុកព្រែកប្រសព្វ ដែលមានការពាក់ព័ន្ធជិតដិតទៅនឹងទំនប់ ១មករា ហើយវានៅក្នុងភូមិភាគកណ្ដាល ពីព្រោះទំនប់១មករា នៅក្នុងភូមិភាគកណ្ដាល។ លោកមិនអាចបំភ្លៃបានទេ បញ្ហានេះ។

[១១:១៣:០៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សីខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងប្រធានបទនេះ។ គឺមិនមែននិយាយអំពីភូមិភាគបូព៌ាទេ គឺនិយាយអំពីៗស្ថានភាពមកពីផ្នែកមួយទៀតនៃ នៅក្នុងប្រទេស គឺក្នុងខែមីនា ឆ្នាំ៧៨។ តើអ្នកស្រីធ្លាប់ឮអំពីការប្រជុំដែលគណៈមជ្ឈិមនៅក្នុងខែមិ -- ក្នុងខែកុម្ភៈ ឆ្នាំ៧៨ របស់បក្សកុម្មុយនីស្តក្នុងការសម្រេចថា លុបបំបាត់ការបះបោររបស់ សោ ភឹម ប្រឆាំងនឹងមេដឹកនាំរបស់ប្រទេសតាមរយៈការអន្តរាគមន៍ផ្ទាល់នោះ តើអ្នកស្រីធ្លាប់ឮទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនជំទាស់មេធាវីក្នុងការសួរសំណួរអំពីប្រធានបទនេះទេ ប៉ុន្តែគាត់កំពុងតែនាំមុខសាក្សី។ គាត់ប្រើសំណួរនាំមុខដែលគាត់មិនបានបញ្ជាក់ថា តើគាត់មានឯកសារអ្វីដែលនិយាយថា សាក្សីនោះមានភាពពាក់ព័ន្ធជាមួយព័ត៌មានទាំងអស់នេះ។ ដូច្នេះ វាមិនមានអ្វីបញ្ជាក់ថាសាក្សីហ្នឹងពាក់ព័ន្ធនោះទេ។ ដូច្នេះគាត់គួរតែមានឯកសារបង្ហាញ ហើយគាត់មិនត្រូវនាំមុខសាក្សីបែបនេះនោះទេ។

[១១:១៤:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំអាចមានសិទ្ធិសួរសាក្សីនេះ ថាតើគាត់ តាមរយៈប្ដីរបស់គាត់ គាត់បានដឹងអំពីសេចក្ដីសម្រេចរបស់វៀតណាម ក្នុងការចាប់ផ្ដើមបះបោរផ្ទៃក្នុង ឬក៏អត់។ ដូច្នេះខ្ញុំគិតថា នេះជាសំណួរដែលត្រឹមត្រូវបំផុត។

**លោក ខេល លីសាក់៖**

មិនមានភស្តុតាងបង្ហាញបែបនេះឡើយ។ ដូច្នេះបើសិនជាលោកមានភស្តុតាង លោកអាចសួរសំណួរបាន ប៉ុន្តែជាការពិតគឺមិនមានភស្តុតាង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចបង្ហាញបាន ប្រសិនបើលោកចង់ដឹង E3/77340-- គឺ E3/07/5.2.7 គឺជាឯកសារដែលមាននៅក្នុងសំណុំរឿងផងដែរ ដែលនិយាយអំពីខាងបក្សកុម្មុយនីស្តវៀតណាម ដែលមានសកម្មភាពចាប់ផ្ដើមនូវការបះបោរផ្ទៃក្នុង ដែលដឹកនាំដោយ សោ ភឹម ដែលជាមូលហេតុសំខាន់ដែលបណ្ដាលឲ្យមានការប៉ះពាល់ប្រដាប់អាវុធ ឬក៏ជម្លោះប្រដាប់អាវុធ ជាមួយនឹង សោ ភឹម ។ ដូច្នេះព័ត៌មានទាំងអស់ដែលសាក្សីហ្នឹងដឹង តាមរយៈស្វាមីរបស់គាត់ គឺពិតជាមានភាពពាក់ព័ន្ធយ៉ាងខ្លាំង។

[១១:១៦:០៣]

**លោក ខេល លីសាក់៖**

លោកប្រធាន ថាតើខ្ញុំអាចសួរបានទេថា តើគាត់ចង់និយាយអំពីសៀវភៅដែលសរសេរឡើងដោយ ប៊ីរល័រ ដែលវាហាក់ដូចជាឯកសារដែលព្រីននៅលើកំព្យូទ័រ ឬមួយក៏ឯកសារផ្សេងទៀត? តើលោកចង់ឲ្យសាក្សីគាត់និយាយអំពីសៀវភៅនិពន្ធដោយអ្នកដទៃទៀតឬ?

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេ ខ្ញុំចង់និយាយអំពីសេចក្ដីសម្រេចខែកុម្ភៈឆ្នាំ៧៨ បើគាត់មិនដឹងទេ ក៏ឆ្លើយថាមិនដឹងទៅគឺវាចប់រឿងទៅហើយ។

**ប្រធានអង្គជំនុំ៖**

ដាក់លេខ ERN ឲ្យបានច្បាស់លាស់មក! លោកអត់មានបង្ហាញលេខ ERN ឲ្យបានច្បាស់លាស់ផង។ ដកស្រង់ឲ្យបានច្បាស់លាស់មក!

**លោក រ៉ិចទ័រ កូប៉េ៖**

គឺ E3/7340 គឺដំបូងដាក់ E3/07/5.2.7, ERN មានលេខ 01002002 រហូតទៅដល់ 8។ ក្នុងពេលឥឡូវនេះ គឺយើងមានតែឯកសារជាភាសាអង់គ្លេសតែប៉ុណ្ណោះ គឺជាការដកស្រង់ពីសៀវភៅ ដោយអ្នកនិពន្ធអាមេរិកឈ្មោះ វីល្លៀម ឌូកយ័រ ដែលៗមានចំណងជើងថា "វៀតណាម ចិន ជាឫស គល់នៃជម្លោះ" ហើយ ចាន់ដា ក៏បាននិយាយអំពីសេចក្ដីសម្រេចខែកុម្ភៈ ឆ្នាំ៧៨ផងដែរ។ ហើយក៏មានសារព័ត៌មានរបស់ទស្សនាវដ្ដី *"ហ្វាអ៊ីស អ៊ីកូណូមី រីវ្យូ"* ដែលនិយាយអំពីសេចក្ដីសម្រេចខែកុម្ភៈ ឆ្នាំ ៧៨ ដែលគេដឹងអំពីច្រើន អំពីសេចក្ដីសម្រេចនេះ។ ដូច្នេះខ្ញុំគិតថាខ្ញុំគួរតែមានសិទ្ធិសួរសាក្សីនេះ អំពីសំណួរមួយនេះ។

[១១:១៨:២២]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមើលទៅដូចជាមិនមានមូលដ្ឋានអ្វី ក្នុងការសួរសាក្សីអំពីសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តវៀតណាម ដែលសរសេរនៅក្នុងសៀវភៅ។ ដូច្នេះ ព្រោះថាខ្ញុំគិតថា វាដូចជាមិនមានមូលដ្ឋានអ្វី ដែលយើងអាចចាប់ផ្ដើមសួរសំណួរទាក់ទងទៅនឹងសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តវៀតណាមនេះបានទេ។

[១១:១៨:៤៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីមានភាពច្បាស់លាស់នោះ តើលោកមេធាវី កូប៉េ អាចបញ្ជាក់ឲ្យបានច្បាស់ទេ ថាលោកនិយាយសំដៅដល់កិច្ចប្រជុំមួយណា? ខ្ញុំមិនយល់ថាតើជាកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ឬក៏របស់បក្សកុម្មុយនីស្តវៀតណាម? បន្ទាប់មកទៀត យើងនឹងពិនិត្យមើលថាតើ លោកអាចសួរសំណួរបាន ឬមិនបាន។

**លោក វ៉ិចទ័រ កូប៉េះ**

គឺការប្រជុំរបស់គណមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ដែលគេហៅថា *ហ្វ័ស ផ្លេនទិន* គឺនៅក្នុងខែកុម្ភៈឆ្នាំ៧៨ ដែលជាសេចក្តីសម្រេចដ៏សំខាន់មួយដែលគេធ្វើឡើងនៅពេលនោះ រួមបញ្ចូលទាំងការបះបោរផ្ទៃក្នុងដែលដឹកនាំដោយ សោ ភឹម ហើយបណ្តាលឲ្យមានការបរាជ័យក្នុងធ្វើអន្តរាគមន៍ដែលៗៗចំណុចនេះនាំទៅដល់ការប៉ះៗទង្គិចដោយប្រដាប់អាវុធ ជាមួយភូមិភាគបូព៌ា ហើយប្តីរបស់សាក្សី គាត់បានទទួលពាក់ព័ន្ធទៅក្នុងរឿងនេះដែរ។ ដូច្នេះ ខ្ញុំចង់ដឹង។

[១១:២១:៤៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំយល់មិនច្រឡំទេ គឺថា លោកមិនមានឯកសារពាក់ព័ន្ធទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំនេះទេ ហើយលោកក៏មិនមានរបាយការណ៍ផ្លូវការដែលចេញមកពីអជ្ញាធរវៀតណាមនោះដែរ គឺលោកយោងតាមរយៈសៀវភៅ អ៊ីចឹងគឺថាលោកអត់មានឯកសារ -- អត់មានកន្លែងយោងជាក់លាក់ពាក់ព័ន្ធនឹងឯកសារហ្នឹងទេ លោក -- សូមលោកបំភ្លឺបន្តិចទៅមើល៍។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ត្រឹមត្រូវហើយ ខ្ញុំមិនមានកិច្ចប្រជុំ -- កំណត់ហេតុកិច្ចប្រជុំទេ ហើយខ្ញុំគិតថាវៀតណាមក៏មិនចែករំលែកនូវកំណត់ហេតុកិច្ចប្រជុំនេះជាមួយយើងនោះដែរ ប៉ុន្តែយ៉ាងណាក៏ដោយ អ្នកសិក្សាស្រាវជ្រាវក៏ជាអ្នកជំនាញ គឺ ណាយ៉ាន់ ចាន់ដា ក៏បាននិយាយយោងអំពីកិច្ចប្រជុំនេះផងដែរ។ ហើយក្នុងការបោះពុម្ពផ្សាយឆ្នាំ៧៨ ក៏មានដែរ។ ដូច្នេះ ខ្ញុំគិតថានេះជាកិច្ចប្រជុំពេញអង្គដ៏សំខាន់របស់គណៈអចិន្ត្រៃយ៍ដែលបានចេញសេចក្តីសម្រេចដើម្បីបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំគិតថានេះជាការដឹងជាសាធារណៈ ជាព័ត៌មានរបស់អ្នកជំនាញដែលខ្ញុំនិយាយយោងទៅរក។

[១១:២៣:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកនិយាយយោងទៅលើ ឆេនដ័ល័រ ឬក៏ ណាយ៉ាន់ ចាន់ដា? តើលោកមានឯកសារយោងជាក់លាក់ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំដ៏សំខាន់មួយនេះទេ?

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ខ្ញុំទើបតែនិយាយយោងទៅលើឯកសារមួយ គឺឯកសាររបស់អ្នកនិពន្ធដ៏សំខាន់អាមេរិក

ដែលជំនាញខាងវៀតណាម គឺឈ្មោះ ខូកយ័រ ហើយខ្ញុំនិយាយយោងទៅឈ្មោះហ្នឹង គឺឈ្មោះ ណាយ៉ាន់ ចាន់ដា ដែលនិយាយអំពីជម្លោះប្រដាប់អាវុធនៅក្នុងសំណុំរឿង០០១ផងដែរ។ ហើយខ្ញុំក៏និយាយយោងទៅលើការបោះពុម្ពផ្សាយរបស់ទស្សនាវដ្ដី "ហ្វាអីស្ទើន អ៊ីកូណូមី" ដែលបោះពុម្ពឆ្នាំ៧៨ ដែលមាននៅក្នុងសំណុំរឿងផងដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តើលោកអាចផ្ដល់ ERN ជាក់លាក់នៃឯកសារយោងទាំងអស់នេះបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំទើបតែផ្ដល់លេខយោងជាភាសាអង់គ្លេស នៅក្នុងសៀវភៅរបស់ ខូកយ័រ។ ខ្ញុំអាចផ្ដល់ម្ដងទៀតប្រសិនបើលោកចង់បាន។ គឺមានលេខ 01002002 ដល់ 01002008។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹង ខ្ញុំចង់ដឹងថា ERN ហ្នឹងប្រហែលជាប្រាំមួយ ប្រាំពីរទំព័រ។ អ៊ីចឹងការកន្លែងយោងទៅលើកិច្ចប្រជុំហ្នឹងហ្នង ជាក់លាក់ហ្នឹង គឺនៅទំព័រមួយណា?

[១១:២៤:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងអាននូវការដកស្រង់ផ្ទាល់ពីសៀវភៅរបស់ វីល្លៀម ឌុកយ័រ ការដកស្រង់ហ្នឹង គឺដូចតទៅនេះ៖ "មូលហេតុសម្រាប់សកម្មភាពនៅកម្ពុជាគឺច្បាស់ ភស្តុតាងត្រូវបានចែកផ្សាយថា ប៉ុល ពត កំពុងតែបង្កបញ្ហា ហើយកំពុងតែព្យាយាមធ្វើឲ្យស្ថានភាពនៅកម្ពុជាដើម្បីឲ្យដឹងអំពីស្ថានភាពនៅក្នុងអាស៊ីអាគ្នេយ៍។ ប្រសិនបើហាណូយចង់រារាំងចិនមិនឲ្យវៀតណាមមានគោលជំហរនៅក្នុងប្រទេសកម្ពុជា ហើយនិង -- ដូច្នេះដំណោះស្រាយល្អ គឺការអន្តរាគមន៍របស់កងទ័ពវៀតណាម។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងនឹងទទួលបានការកៀបសង្កត់ពីអន្តរជាតិ ហើយយើងត្រូវប្រឈមផ្ទាល់ជាមួយនឹងចិន ការបះបោរផ្ទៃក្នុងដែលដឹកនាំដោយអ្នកប្រឆាំងនឹង ប៉ុល ពត នៅក្នុងប្រទេសគឺជាដំណោះស្រាយដ៏ល្អ ហើយវាជាដំណោះស្រាយដែលមិនចំណាយថវិកាច្រើនផង"។ ឥឡូវនេះយើងមកដល់ចំណុចនេះ ហើយនៅពេលចុងក្រោយគឺថា "កិច្ចប្រជុំអចិន្ត្រៃយ៍បានឯកភាព នាំឲ្យមានការបះបោរផ្ទៃក្នុងដឹកនាំដោយ សោ ភឹម ហើយនិងមានផែនការដើម្បីផ្តួលរំលំរដ្ឋាភិបាលក្រុងភ្នំពេញតាមរយៈការអន្តរាគមន៍ផ្ទាល់"។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

គឺនៅតែអត់មានឯកសារយោងជាក់លាក់ដដែល ដែលអ្នកនិពន្ធនេះផ្អែកទៅលើ។

**លោក វិុចទ័រ កូប៉េ៖**

គាត់មានព័ត៌មាន ហើយ ណាយ៉ាន់ ចាន់ដា ក៏ដឹងអំពីព័ត៌មានទាក់ទងនឹងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយក៏គាត់ទាំងពីរ គឺជាអ្នកស្រាវជ្រាវដ៏ល្បីល្បាញ ហើយគេទទួលស្គាល់ស្នាដៃរបស់គាត់។ ដូច្នេះ ខ្ញុំគិតថាវាគ្រប់គ្រាន់ហើយ ជាព័ត៌មានដែលគ្រប់គ្រាន់ទាក់ទងទៅនឹងកិច្ចប្រជុំខែកុម្ភៈឆ្នាំ៧៨នេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកអាចពន្យល់បានទេ ថាតើសាក្សីរូបនេះអាចឆ្លើយទៅនឹងសំណួររបស់លោកបានដោយរបៀបណា ពាក់ព័ន្ធទៅនឹងបញ្ហាប្រធានបទមួយនេះ អំពីការដឹងឮអំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តវៀតណាមនោះ? លោកគិតថាសាក្សីនោះប្រាកដជាអាចឆ្លើយទៅនឹងសំណួររបស់លោកបានមែនទេ?

**លោក វិុចទ័រ កូប៉េ៖**

ប្រហែលសាក្សីហ្នឹងមិនអាចដឹងទេ ប៉ុន្តែប្តីរបស់គាត់ប្រហែលជាដឹង ហើយប្តីរបស់គាត់អាចធ្លាប់និយាយប្រាប់គាត់ ប្រាប់កូនប្រុសរបស់គាត់ជាដើម។ សេចក្តីសម្រេចខែកុម្ភៈ ឆ្នាំ៧៨ គឺជាសេចក្តីសម្រេចដែលគេជជែក ក៏ដូចជាផ្សព្វផ្សាយច្រើននៅក្នុងប្រព័ន្ធព័ត៌មាន។ ដូច្នេះវាថាអាចប្តីរបស់គាត់នៅពេលក្រោយមកទៀត និយាយអំពីសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តវៀតណាមឆ្នាំ៧៨ ដែលនាំឲ្យមានការបះបោរផ្ទៃក្នុង បើគាត់មិនដឹងទេ គាត់ឆ្លើយថាមិនដឹងទេ គឺគ្រប់គ្រាន់ហើយ។

[១១:២៧:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមលើកឡើងដោយសង្ខេប គួរតែមានការកំណត់ត្រា គឺថាគាត់មិនបានដកស្រង់អំពីប្រភពអ្វីទាំងអស់។ របាយការណ៍នេះគ្រាន់តែជាការនិយាយ។ ប្រសិនបើវាជាព័ត៌មានដែលគេផ្សព្វផ្សាយច្រើននោះខ្ញុំគិតថាប្រហែលជាមេធាវីការពារក្តីអាចដកស្រង់មកច្រើនហើយ ប៉ុន្តែគាត់មិនបានផ្តល់ប្រភព

ផ្សេងប៉ុណ្ណោះ។ គាត់ដកស្រង់តែមួយ។ ដូច្នេះបញ្ហាសំខាន់មួយទៀត ខ្ញុំគិតថាវាមិនមានមូលដ្ឋានអ្វីក្នុងការសួរសាក្សីអំពីប្រធានបទនេះបានឡើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាវាហាក់ដូចជារឿងគួរឲ្យសោកស្តាយណាស់ ដែល៣០ឆ្នាំជាងក្រោយមក គ្មានអ្នកណាម្នាក់នៅក្នុងតុលាការដឹងអំពីហេតុការណ៍នេះឡើយ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំគិតថាខ្ញុំគួរតែមានសិទ្ធិសួរសំណួរនេះ។ ប្រសិនបើសាក្សីមិនដឹង គាត់ឆ្លើយថាមិនដឹងទៅ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគ្រាន់តែចង់ឆ្លើយតបទៅនឹងផ្នែកដំបូងរបស់លោកតែប៉ុណ្ណោះ។ ប្រសិនបើលោកនិយាយថា ឬក៏លោកនិយាយយោងទៅលើមនុស្ស ឬក៏លោកនិយាយអំពីសៀវភៅ វាជាការដែលកំណត់តាំងពីយូរមកហើយ លោកគួរតែលើកនិយាយយោង។ មិនចាំបាច់ថាតើយើងនៅតុលាការនេះប៉ុន្មានឆ្នាំនោះទេ វាអត់ជាបញ្ហាទេ យ៉ាងណាក៏ដោយខ្ញុំគិតថាទុកសិទ្ធិនេះជូនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ សំណួរនេះមិនមានមូលដ្ឋានអីគ្រប់គ្រាន់សម្រាប់សាក្សីឆ្លើយតបនោះបានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធានដែលបានចេញសេចក្តីសម្រេច។

[១១:២៩:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី លោកស្រីបាននិយាយនៅក្នុងសក្ខីកម្មរបស់លោកស្រីដែលថាមានម្តងៗ អៀង ធីរិទ្ធ គាត់បានទៅធ្វើទស្សនកិច្ចនៅទំនប់។ តើលោកស្រីមានបានផ្តល់សក្ខីកម្មបែបនេះទេ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ពេលនោះ ខ្ញុំបាននិយាយហើយ និយាយទៀតៗ ច្រើនដងហើយ រឿងបងគាត់ទៅទស្សនកិច្ចជាមួយប្រតិភូ ប្រតិភូអីទេ ភ្លេចបាត់ហើយខ្ញុំ បានទៅធ្វើនៅកន្លែងនោះ បានបងប្អូនប្រជាជនគេទទួល អ្អូអរអឺចឹង តែអារឿងស្អីទៀត ខ្ញុំមិនចាំ ខ្ញុំចាំតែគាត់ទៅ។ ហើយបានទទួលគាត់តែប៉ុណ្ណឹង។ ប៉ុន្តែខ្ញុំនិយាយច្រើនដងហើយ និយាយពីរឿងបងទៅទស្សនកិច្ចនៅចំការលើពីរទៅបីដង មិនដឹងជាប៉ុន្មាន

ដងហើយទេ បញ្ចាក់ហើយបញ្ចាក់ទៀតៗ។ អានេះខ្ញុំនៅចាំប៉ុណ្ណឹង បើចុះខ្ញុំមិនចាំ ចេះតែលើកបញ្ហោមក ខ្ញុំមិនចាំទេ។

**សៈ** ខ្ញុំដឹងថាវាជាហេតុការណ៍កន្លងយូរណាស់មកហើយ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំនឹងព្យាយាម។ តើអ្នកស្រីចាំទេ នៅពេលដែលគាត់ទៅទីនោះ គាត់បាននិយាយអំពីការធ្វើទស្សនកិច្ចនៅភូមិភាគពាយ័ព្យ តើគាត់ធ្លាប់និយាយអំពីបទពិសោធន៍របស់គាត់នៅពេលដែលគាត់ចុះទៅទស្សនកិច្ចនៅភូមិភាគពាយ័ព្យ ដែរឬទេ?

**ឆៈ** ខ្ញុំសូមជម្រាបរឿងទស្សនកិច្ចនៅភូមិភាគពាយ័ព្យ។ ខ្ញុំអត់ចាំទេ ហើយអត់ចាំ ក៏អត់ដឹង ដែរ។ ខ្ញុំសូមនិយាយប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះតទៅរហូត ដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាល តុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូប នេះនៅក្នុងពេលសម្រាកថ្ងៃត្រង់ និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់ សក្ខីកម្មនៅបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម សាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះនៅរសៀល នេះ ឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៤:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវី

ការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកលោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**សៈ** បាទ មុនពេលសម្រាកអម្បាញ់មិញនេះ យើងនិយាយអំពី អៀង ធីរិទ្ធ។ លោកស្រីបាននិយាយថា លោកស្រីមិនចាំអំពីការសន្ទនាគ្នាជាមួយគាត់នោះទេ ប៉ុន្តែកូនស្រីរបស់លោកស្រីធ្វើការនៅសង្គមកិច្ច។ កូនស្រីរបស់លោកស្រីប្រហែលជាបាននិយាយអំពីការសន្ទនារបស់គាត់ជាមួយនឹង អៀង ធីរិទ្ធ។ អ៊ីចឹង សំណួរខ្ញុំចង់សួរថា តើលោកស្រីចាំអំពីសកម្មភាពវិទ្ធ្វេទកម្មរបស់ អៀង ធីរិទ្ធ នៅពាយ័ព្យដែរឬទេ ចំពោះពួកអ្នកដែលលួចស្រូវ លួចអង្ករពីសហករណ៍? តើលោកស្រីមានបានឮគេនិយាយអំពីរឿងរ៉ាវបែបនេះឬទេ អំពើវិទ្ធ្វេទកម្មលួចស្រូវ លួចអង្ករពីសហករណ៍អីជាដើមនេះ?

**លោកស្រី ស៊ូ សឿន៖**

**ឆៈ** ចាស ខ្ញុំមិនបានដឹងទេរឿងឃាតកម្មនៅខាងខេត្តហ្នឹង ខ្ញុំអត់បានចាំផង ក៏អត់បានដឹងទៀត។

**សៈ** ប្រហែលជាសំណួររបស់ខ្ញុំអម្បាញ់មិញនេះ មិនសូវច្បាស់។ ខ្ញុំនិយាយអំពីការលួចស្រូវ ពីប្រជាជន គឺបង្អត់អាហារប្រជាជន លួចស្រូវនៅឃ្លាំង ថានេះគឺជាអំពើរបស់ពួកបះបោរនៅភូមិភាគពាយ័ព្យ។ តើលោកស្រីធ្លាប់ឮគេនិយាយពីលួចស្រូវលួចអី ដើម្បីបង្អត់ប្រជាជនឬទេ នៅភូមិភាគពាយ័ព្យនេះ?

**ឆៈ** ចាស ចុះហេតុអីខ្ញុំដឹងដល់នៅបូព៌ា ដែលខេត្ត-- អ៎! ភូមិភាគពាយ័ព្យ។ ដូច្នេះ ខ្ញុំអត់ដឹងទេ ព្រោះវានៅឆ្ងាយពីគ្នាដែរ ហើយការងារវាផ្សេងគ្នា ខ្ញុំអត់អាចដឹងទេ។ តែការនិយាយ ការស្តីអី ក៏គ្មានពីណានិយាយ ផ្សាយផ្សព្វដើម្បីអ្នកនេះអ៊ីចេះ អ្នកនោះអ៊ីចឹង ខ្ញុំអត់ដឹងទេ ខ្ញុំមិនដឹង។

**សៈ** បាទ ឥឡូវ ខ្ញុំសូមចោទសំណួរទាក់ទងទៅនឹងស្រុកលោកស្រីវិញម្តង។ ចំពោះមុខខ្ញុំ ខ្ញុំមានឯកសារមួយ គឺជាតួលេខ E3/952 គឺជាតួលេខដែលផ្ញើដោយប្តីរបស់លោកទៅប៉ុល ពត នៅថ្ងៃទី០២ មេសា ឆ្នាំ១៩៧៦។ គាត់និយាយអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅស្រុកចំការលើ គឺស្រុកលោកស្រីតែម្តង។ ERN ជាភាសាអង់គ្លេស 00182658, ជាភាសាខ្មែរ 000766--, ជាភាសាបារាំង 0035 0762 ដល់ 3។ ខ្ញុំអានអ្វីដែលប្តីរបស់លោកស្រីផ្ញើជូនទៅ ប៉ុល ពត ហើយខ្ញុំសូមឲ្យលោកស្រីឆ្លើយតបនៅពេលបន្ទាប់មក។ គាត់និយាយអំពីស្ថានភាពខ្មាំងនៅក្នុងភូមិភាគបូព៌ា គាត់និយាយថា៖ ខ្មាំងមិនទាន់

មានសកម្មភាពនៅឡើយទេ ក៏ប៉ុន្តែគាត់ថានៅស្រុកចំការលើសកម្មភាព គឺថាជាអតីតយោធា ដែលមានពាក់ព័ន្ធជាមួយចាម ហើយនិងពាក់ព័ន្ធជាមួយប្រធានសហករណ៍។ ពួកគេប្រើឯកសារចម្លងរបស់លន់ នល់ ហើយនិងប្រើសេចក្ដីប្រកាសនៅថ្ងៃទី១៨ មីនា ដើម្បីបិទនៅតាមដើមឈើនៅក្បែរភូមិ ហើយគេបានធ្វើសកម្មភាពផ្សេងទៀតផងដែរ ដូចជាការដុតព្រៃ បំផ្លាញដំណាំ ចេក ល្ហុងអីជាដើម។

លោកស្រីសាកស្រី តើលោកស្រីចាំអំពីខ្មាំងនៅក្នុងស្រុករបស់លោកស្រី ដូចដែល -- ដូចជាមានកម្លាំងមួយចំនួនដែលដុតព្រៃ បំផ្លាញដល់ដំណាំចេក ល្ហុងអីជាដើមនេះ លោកស្រីមានចាំទេ?

**ឆ៖** ចាស រឿងដុតព្រៃដុតអី ខ្ញុំមិនបានចាំទេ ជម្រាបប្រធានអ៊ីចឹង គឺថាវាយូរហើយ ដូច្នេះក៏វាភ្លេច។ រឿងហ្នឹងខ្ញុំថា សូមទោសចុះ ខ្ញុំភ្លេច ខ្ញុំស្ដាប់អត់បាន ក្ដាប់អត់បាន។

[១៣:៤០:៤៨]

**ស៖** ខ្ញុំយល់ហើយលោកស្រី។ នៅក្នុងទូរលេខដដែលនេះ ដែលផ្ញើទៅបង ប៉ុល ប្ដីរបស់លោកស្រីបាននិយាយពីបញ្ហាគ្រុនក្ដៅរាករូសជាដើម នៅក្នុងចំណោមមនុស្សនៅក្នុងភូមិភាគពាយ័ព្យ។ នៅលេខ ERN ដដែលគាត់សរសេរដូចតទៅនេះ៖ គាត់សរសេរថា "ដោយសារតែគាត់ធ្វើ -- ដោយសារថាមិនមានដាំទឹក ហើយផឹកទឹកឆ្អិនអីជាដើម នេះជាមូលហេតុនៃបញ្ហាជំងឺ" ហើយគាត់សរសេរបន្តទៀតថា "វិធានការត្រូវចាត់ គឺត្រូវធ្វើយ៉ាងណាឲ្យបន្ថយម៉ោងការងារ ស្របតាមមាគ៌ាបក្ស ធ្វើយ៉ាងណាដើម្បីឲ្យបងប្អូនផឹងទឹកក្ដៅ"។ សំណួរ តើការពិពណ៌នាទាំងអស់នេះ ធ្វើឲ្យលោកស្រីនឹកឃើញទេ តើរឿងរ៉ាវទាំងអស់នេះ មានកើតឡើងនៅក្នុងស្រុករបស់លោកស្រីមែនទេ? ហើយមានចេញវិធានការ ឬក៏ដំណោះស្រាយអ្វីដែរឬទេ ពីថ្នាក់លើ?

**ឆ៖** ចាស ខ្ញុំសូមទោសចុះ ដូចជាខ្ញុំវាទៅភាំងមួយនេះទៅ ខ្ញុំក្ដាប់អត់បានដែរ។ ពេលនោះប្រហែលជាខ្ញុំឈឺ ហើយខ្ញុំមិនបានដឹងអារឿងអ៊ីចឹងទេ។ សូមអត់ទោស សូមទោស វាភ្លេចមែន មិនមែននេះទេ ខ្ញុំនិយាយដោយត្រង់ គឺភ្លេចមែន ហើយមិនបានចាប់អារម្មណ៍ផង។ ភ្លេចឈឹងអ៊ីចឹងទៅ។

**ស៖** បាទ អត់បញ្ហាអីទេ លោកស្រី។ ឥឡូវខ្ញុំសូមបន្តទៅមុខទៀត ខ្ញុំសូមចូលទៅនិយាយសំណួរទូទៅទាក់ទងទៅនឹងស្ថានភាពចំណីអាហារ ហើយនិងពេលសម្រាកជាដើម។ លោកស្រីបានឆ្លើយទៅនឹងសំណួរមួយដែលសួរដោយ -- ទាក់ទងទៅនឹងគោលបំណងនៃទំនប់១មករា លោកស្រីបានឆ្លើយថាគោលបំណងគឺដើម្បីទប់ទឹក ហើយនិងស្រោចស្រពស្រែចម្ការ។ គោលដៅចុងក្រោយនៃទំនប់នោះ សំណួរគឺសួរថា តើគោលនេះ គឺដើម្បីធ្វើឲ្យជីវភាពប្រសើរឡើង ឬក៏យ៉ាងម៉េច? តើគោលបំណងចុង

ក្រោយនៃការសង់ទំនប់ហ្នឹង គឺធ្វើឲ្យជីវភាពប្រសើរឡើង ឬក៏យ៉ាងណា?

**ឆ៖** ចាស តាមខ្ញុំយល់ខ្លះ គឺធ្វើទំនប់១មករានេះ ដើម្បីជួយប្រជាជនឲ្យមានជីវភាពប្រសើរឡើង មិនឲ្យអាប់អួរទេ គឺឲ្យប្រសើរឡើង។ សូមខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១៣:៤៤:១៧]

**ស៖** លោកស្រីក៏បាននិយាយផងដែរថា លោកស្រីផ្ទាល់ ហើយនិងកម្មាភិបាលខ្ពស់ -- ជាន់ខ្ពស់មួយចំនួនទៅភ្នំពេញដើម្បីចូលរួមវគ្គរៀនសូត្រ ដែលដឹកនាំដោយ នួន ជា។ តើលោកស្រីដឹងដែរឬទេថាតើនៅក្នុងពេលវគ្គអប់រំទាំងអស់ហ្នឹង គាត់មានបាននិយាយអំពីគោលបំណងចុងក្រោយនៃរបបសង្គមនិយមដែរឬទេ គឺថាត្រូវធ្វើយ៉ាងណាឲ្យជីវភាពប្រសើរឡើង? តើគេបាននិយាយអំពីចំណុចនេះដែរឬទេទាក់ទងទៅនឹងសង្គមនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** ចាស ខ្ញុំទទួលបានតែការអប់រំខាងភារកិច្ច តែខាងរឿងដែលលោកបានលើកទាំងអស់នេះខ្ញុំអត់បានចាំទេ វាយូរឆ្នាំមកទៅហើយ។ អ៊ីចឹង ដូច្នេះខ្ញុំវាមានវិបត្តិៗខាងអារម្មណ៍ ហើយវាឈឺច្រើនដូច្នេះភ្លេចភ្លាំងអស់ក្នុងការអនុវត្តវាយ៉ាងណា។ ទៅប្រជុំហើយ ទៅៗ មកវិញក៏មកៗ វាដូចថាវាក្តាប់ -- ចាប់អីវាមិនជាប់។ នេះ ខ្ញុំសូមទោសអ៊ីចឹង។

**ស៖** ខ្ញុំយល់ហើយលោកស្រីសាក្សី។ បើសិនជាខ្ញុំផ្តល់ឧទាហរណ៍មួយចំនួនជូនដល់លោកស្រីឲ្យជាក់ស្តែងតែម្តង ប្រហែលជាលោកស្រីអាចនឹកឃើញវិញ។ ឧទាហរណ៍ តើលោកស្រីមានចាំដែរឬទេថា នួន ជា បាននិយាយប្រាប់លោកស្រី ហើយនិងកម្មាភិបាលនារីផ្សេងទៀតថា តើរបបការងារហើយនិងពេលសម្រាកនៅរបបកម្ពុជាប្រជាធិបតេយ្យនោះ វាយ៉ាងណាដែរ? ឧទាហរណ៍ដូចថា កម្មករត្រូវការសម្រាក៣ថ្ងៃក្នុង១ខែ ឬក៏អនុ -- ត្រូវនឹង១០ ឬ១៥ថ្ងៃ ដើម្បីទៅលេងបងប្អូន ឬក៏ទៅការសិក្សាជាដើមនេះ តើលោកស្រីមានចាំពីវិធានការដាក់លាក់ស្តីអំពីម៉ោងការងារ ហើយនិងម៉ោងសម្រាកដែរឬទេ?

[១៣:៤៦:៥៦]

**ឆ៖** ចាស ខ្ញុំបានឆ្លើយច្រើនដងហើយ ត្រង់ហ្នឹង ប៉ុន្តែខ្ញុំថាខ្ញុំមិនចាំទេ។ ការអប់រំរបស់គាត់ពន្យល់របស់គាត់ ខ្ញុំវាភ្លេចអស់ហើយ ខ្ញុំក្តាប់អត់ជាប់ទេ។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

**ស៖** ឥឡូវ ខ្ញុំសូមឲ្យឧទាហរណ៍ជាក់លាក់ ជាក់ស្តែងមួយចំនួន។ តើលោកស្រីគិតថា ទោះបីជាខ្ញុំឲ្យឧទាហរណ៍ហើយ លោកស្រីក៏នៅតែនឹកមិនឃើញដដែលឬក៏យ៉ាងណា?

**ឆ៖** ចាស ខ្ញុំនឹកមិនឃើញ។ បានថា មូលហេតុ ខ្ញុំបញ្ជាក់បន្តិចចុះ! ដែលខ្ញុំនឹកមិនឃើញ គឺអារម្មណ៍ ហើយនិងនេះវា ហៅថា វាស្តាប់រាប់មិនអស់។ ដូច្នេះ ការចងចាំវាមិនសូវចាំជាប់ទេ បាត់ទៅជួនកាល ងាប់មួយអាទិត្យទៅ រស់ឡើងវិញ។ អ៊ីចឹង ដូចជាការឆ្លើយក្នុងសំណួរនេះវាភាគច្រើន ខ្ញុំមិនសូវចាំ។ នេះ ខ្ញុំជម្រាបប្រធានអ៊ីចឹង។

**ស៖** បាទ ឥឡូវខ្ញុំសូមព្យាយាមជាលើកចុងក្រោយថា ឲ្យឧទាហរណ៍ទាក់ទងនឹងស្ត្រី ហើយនិងកុមារ។ តើលោកស្រីមានដឹងដែរឬទេថា នៅក្នុងពេលប្រជុំទាំងអស់នោះ នួន ជា បាននិយាយអំពីថាគាត់ហ្នឹងបានថា -- តើគាត់បាននិយាយអំពីរយៈពេលសម្រាក២ខែ គឺហៅសម្រាប់នារីមានផ្ទៃពោះនោះសម្រាកសម្រាប់នារីមានផ្ទៃពោះ ២ខែ។ តើលោក នួន ជា បាននិយាយអ៊ីចឹងទេ?

[១៣:៤៩:១០]

**ឆ៖** ចាស ក្នុងពេលអ្នកដែលមានផ្ទៃពោះ នៅក្នុងសហករណ៍នីមួយៗ គឺត្រូវមានច្បាប់ទម្លាប់ គឺថានៅក្នុង មិនទាន់ឆ្លងទន្លេ គឺសម្រាកកន្លះខែ ឬ១ខែ។ ដល់ឆ្លងទន្លេហើយ បាន២ខែ ឆ្លង សម្រាកបាន២ខែ។ នេះ គឺការគាត់អប់រំ គឺអ៊ីចឹង។

**ស៖** ចុះទាក់ទងនឹងកុមារវិញ តើ នួន -- លោកស្រី មានបានចាំដែរឬទេថា តើ នួន ជា បាននិយាយអំពីគោលនយោបាយ សំដៅធ្វើមជ្ឈមណ្ឌលសម្រាប់កុមារអីជាដើមនេះ លោកស្រីមានចាំទេថាគាត់និយាយអំពីបញ្ហាហ្នឹងទេ?

**ឆ៖** ចាស ក្នុងកាលហ្នឹងគឺ ខ្ញុំដូចជាក្តាប់មិនជាប់ ក្តាប់មិនបាន។ ហើយចុះនឹកឃើញថា វាភ្លេចអ៊ីចឹងទៅ រកពាក្យឆ្លើយមិនឃើញទេ ព្រោះខ្ញុំនឹកមិនឃើញ។

**ស៖** បាទ ខ្ញុំយល់។ ខ្ញុំសូមឲ្យលើកឧទាហរណ៍លើកចុងក្រោយ ទាក់ទងនឹងអ្វី ប្រហែលជាអាច ត្រូវបាននិយាយដោយ នួន ជា នៅពេលប្រជុំនោះ។ តើលោកស្រីមានចាំដែរឬទេ ថាតើគាត់ធ្លាប់បាននិយាយប្រាប់លោកស្រី ហើយនិងកម្មាភិបាលនារីផ្សេងទៀត ថាត្រូវប្រើឧបករណ៍សំខាន់ៗអ្វីខ្លះសម្ភារៈសំខាន់ៗអ្វីខ្លះ ដូចឧទាហរណ៍ដូចជាមុងៗភួយអីជាដើម ដែលត្រូវចែកចាយទៅក្នុងសហករណ៍នីមួយៗហ្នឹង។ នួន ជា បាននិយាយពីការបែងចែកសម្ភារៈសំខាន់ៗបែបហ្នឹងទេ?

**ឆ៖** ចាស រឿង បង នួន ជា គាត់មិនបាននេះទេ គាត់រៀបចំតាមភាគ។ ដូច្នេះភាគគេ រៀបចំតាមស្រុក ហើយរឿង ផ្គត់ផ្គង់ពីរឿង មុងភួយ គឺចែកតាមសហករណ៍ មានតែពីតំបន់មកស្រុក តែត្រង់ថាគាត់រៀបចំខាងលើ ខ្ញុំអត់បានទទួលទេ។ អត់បានទទួលពាក្យទេ និយាយឲ្យអស់ចុះ អត់បាន

ទទួលពាក្យគាត់ទេ ខ្ញុំទទួលតែត្រឹមតំបន់ ហើយនិងស្រុក ទទួលចែកសហករណ៍។

[១៣:៥២:១៧]

**ស៖** មុននឹងបន្តិចអ្នកស្រីបាននិយាយថា លោកគិតថា -- លោកស្រីគិតថាស្ថានភាពអាហារនោះសមរម្យ ហើយតើលោកស្រីមានចាំទេ ថាមជ្ឈិមចេញសេចក្តីណែនាំទាក់ទងនឹងរបបអាហារដែរឬទេ ទៅតាមចេញរបបអាហារតាមប្រភេទពលករ ឬក៏លោកស្រីមិនចាំអ្វីនោះទេ?

**ឆ៖** ចាស ខ្ញុំមិនចាំទេ ជម្រាបឲ្យត្រង់ទៅ គឺខ្ញុំមិនចាំវាភ្លេចមែន ភ្លេចហើយ មិនចាំទេ សុំមានមតិ។

**ស៖** លោកស្រីសាក្សីខ្ញុំសូមអានសម្រង់មួយរបស់បុគ្គលម្នាក់ ដែលខ្ញុំនឹងប្រាប់ឈ្មោះនៅពេលក្រោយ។ សម្រង់នេះ និយាយអំពីស្ថានភាពអាហារនៅក្រោមកម្ពុជាប្រជាធិបតេយ្យចន្លោះពី៧៥-៧៩ ទាក់ទងទៅនឹងស្រុករបស់លោកស្រីហើយតំបន់លោកស្រីផងដែរ។ ខ្ញុំសូមអានសម្រង់នេះ បន្ទាប់មកទៀតខ្ញុំនឹងសួរសំណួរលោកស្រី សួរលោកស្រីថា តើលោកស្រីយល់ស្របដែរឬទេ។

បាទ លោកប្រធានខ្ញុំសូមដកស្រង់ឯកសារមួយ គឺឯកសារ E3/7333 និងស្មើនឹងឯកសារ E307/5.2.17 ដែលគេហៅសៀវភៅ ឈ្មោះថា “សៀវភៅ ភ្នែកម្ចាស់”។ ERN ជាភាសាអង់គ្លេស 001002277 នៅចុងទំព័រ១៥៦។ សម្រង់ដូចតទៅនេះ៖ “ប្រជាជនធ្វើការលំបាកលំបិនណាស់ ក៏ប៉ុន្តែពួកគេមិនទុក្ខវេទនាអីទេ ពួកគេសើចសប្បាយ ហើយរបបអាហារនៅសហករណ៍នោះមិនខ្វះអីប៉ុណ្ណឹងទេ វាមិនដូចផ្ទះខ្ញុំនៅភ្នំពេញទេ ក៏ប៉ុន្តែវាមានម្ហូបអាហារគ្រប់គ្រាន់។ នេះជាការពិតពេលដែលខ្ញុំនិយាយថាមានម្ហូបអាហារគ្រប់គ្រាន់នេះខ្ញុំមិនកុហកទេ។” តើលោកស្រីយល់ស្របនឹងសម្រង់ដែលខ្ញុំអានជូនអម្បាញ់មិញនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

យើង -- ឥឡូវនេះគេកំពុងតែចោទសំណួរមួយដើម្បីបានមតិយោបល់ពីគាត់ ប៉ុន្តែអ្វីដែលគាត់កំពុងអានអម្បាញ់មិញនេះដូចមិនទាក់ទងទៅនឹងស្រុករបស់លោកស្រីសាក្សីនេះទេ។ អ៊ីចឹងគាត់កំពុងតែចោទសំណួរមួយដើម្បីឲ្យបានយោបល់ពីគាត់។ អ៊ីចឹងក៏មិនមានអង្គហេតុណាមួយដែលអាចជាយុត្តិកម្មនៃសំណួររបស់គាត់ទេ។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំគ្រាន់តែសួរគាត់ថា អ្វីដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ ផ្ទុះបញ្ចាំងអំពីបទពិសោធន៍គាត់ ឬក៏ការពិតនៃរបបអាហារនៅក្នុងសហករណ៍ដែលគាត់នៅនោះដែរឬក៏អត់។ អ៊ីចឹងខ្ញុំគិតថា ខ្ញុំគ្រាន់តែចង់ឲ្យគាត់មើល ឬក៏ផ្ទៀបនឹងអ្វីដែលគាត់ដឹងដែរសម័យនោះប៉ុណ្ណឹងទេ លោកប្រធានថាតើអ្វីដែលខ្ញុំអានជូននេះវាផ្ទុះបញ្ចាំងពីការពិតដែរឬក៏អត់។

[១៣:៥៦:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៧:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើងតបទៅនឹងសំណួរ ហើយបដិសេធនូវការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកស្រីសាក្សី តើអ្វីដែលខ្ញុំទើបតែនឹងអានអម្បាញ់នេះគឺជាការពិពណ៌នាត្រឹមត្រូវលើស្ថានភាពម្ហូបអាហារ និងស្បៀងអាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំក្តាប់បានភារកិច្ចក្នុងស្រុកទេ គឺថាវាមិនខ្សត់ខ្សោយទេ គឺថាវាគួរសមនឹងជីវភាពបងប្អូនដែលខំធ្វើការ។ នេះខ្ញុំនិយាយក្នុងរង្វង់ការគ្រប់គ្រងនៅស្រុកចំការលើ។ ខ្ញុំយល់តែប៉ុណ្ណឹង។

**ស៖** អ៊ីចឹងលោកស្រីយល់ស្របជាមួយនឹងខ្ញុំដែរឬទេ ក្នុងការនិយាយថា លោកស្រីយល់ស្របនឹងសម្រង់ដែលខ្ញុំទើបតែអានជូនលោកស្រីអម្បាញ់មិញនេះ គឺចង់និយាយថាលោកស្រីយល់ស្របថាអ្វីដែលខ្ញុំអាននេះផ្ទុះបញ្ចាំងអំពីការពិតហើយ។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរសាជាថ្មីម្តងទៀត ដូចជាទំនងជាតាំងសំណួរនាំមុខហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោកស្រីសាក្សីខ្ញុំទើបអានសម្រង់ជូនលោកស្រីស្តាប់អម្បាញ់មិញ បើតាមការខ្ញុំអានជូនអម្បាញ់មិញនេះ តើវាផ្ទុះបញ្ចាំងនឹងការពិតដែរឬទេ បើតាមការចងចាំរបស់លោកស្រីទាក់ទងទៅនឹង

ស្ថានភាពអាហារនៅសម័យនោះ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំបានឆ្លើយពីមុនហើយ ឆ្លើយថាក្នុងរង្វង់ស្រុកខ្ញុំហ្នឹង គឺថាជីវភាពវាសមរម្យៗនឹងការងាររបស់បងប្អូន ហើយឲ្យខ្ញុំនិយាយម៉េចទៀត។

[១៤:០០:០៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំ អម្បាញ់មិញនេះ ខ្ញុំដកស្រង់សន្និសីទរបស់សម្តេចឪនៅខែមករា ឆ្នាំ១៩៧៩ នៅទីក្រុងប៉េកាំង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំសុំចោទសំណួរមួយចំនួនទាក់ទងទៅនឹងម៉ោងធ្វើការនៅទំនប់១មករា។ តើលោកស្រីមានចាំដែរឬទេ ថានៅពេលណាមួយនោះ សារមួយចេញទាក់ទងទៅនឹងទស្សនាវដ្តីទង់បដិវត្ត ចេញ ទាក់ទងទៅនឹងពលករដែលធ្វើការនៅពេលយប់ជាដើម។ តើមានទស្សនាវដ្តីណាមួយចេញនិយាយអំពីកម្មករទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

លោកស្រីចៅក្រមហ្វេនស៍ អម្បាញ់មិញនេះ ពេលគាត់អន្តរាគមន៍អត់មានឮសំឡេងចូលមីក្រូទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍របស់លោកថា សាក្សីនេះមិនចេះអាននោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំស្មានតែគាត់ចេះអានបន្តិចបន្តួចដែរ។ ឥឡូវនេះ ខ្ញុំសូមរៀបសំណួរខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រី តើលោកស្រីមានចាំថានៅពេលដែលលោកស្រីទៅរៀនសូត្រ តើមានបញ្ហាទាក់ទងនឹងការធ្វើការពេលយប់ដែរឬទេ? ហើយដែលត្រូវធ្វើយ៉ាងម៉េចកាត់បន្ថយម៉ោងការងារពេលយប់ ការធ្វើការងារពេលយប់? តើមាន -- លោកស្រីមានឮនិយាយអំពីបញ្ហាហ្នឹងទេ ពេលដែល

លោកស្រីទៅប្រជុំនោះ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ពេលខ្ញុំទៅប្រជុំស្តាប់គាត់អធិប្បាយ គឺមិនបានឲ្យបងប្អូនធ្វើការយប់ទេ។ អាហ្នឹង ខ្ញុំស្តាប់បានតែប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំសូមចោទសំណួរមួយទៀត ទាក់ទងទៅនឹងម៉ោងធ្វើការនៅលើការដ្ឋាន។ តើលោកស្រីនៅចាំម៉ោងធ្វើការងារនៅទំនប់១មករា ទេ លោកស្រីចាំថាគេចាប់ផ្តើមធ្វើការម៉ោងប៉ុន្មាន សម្រាកនៅពេលណា? សម្រាកអាហារថ្ងៃត្រង់នៅពេលណា ហើយធ្វើការចប់នៅម៉ោងប៉ុន្មានដែរ? តើម៉ោងធ្វើការហ្នឹងដូចគ្នាទាំងអស់ កម្មករទាំងអស់ដែលធ្វើការនៅទំនប់១មករា ត្រូវតែចាប់ផ្តើម ហើយនិងបញ្ចប់នៅម៉ោងដូចគ្នា ឬក៏យ៉ាងណា?

[១៤:០៣:០៧]

**ឆ៖** ចាស ទំនប់ ១មករាហ្នឹង ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ខ្ញុំមិនដឹងម៉ោងពេលវេលាណាទេ ព្រោះខ្ញុំហាក់ដូចជាភ្ញៀវ គ្រាន់តែទៅលេង ដូច្នេះគ្មានភារកិច្ចអីទៅសួរគេថាម៉ោងប៉ុន្មាន ពេលប៉ុនណាត្រូវដេក ឬត្រូវសម្រាក។ នេះភារកិច្ចខ្ញុំគ្រាន់តែទៅលេង ទៅមើលគេ មិនបានទៅគិតថាអារឿងអីចឹងទេ ដូច្នេះ ខ្ញុំមិនចាំៗម៉ោងពេលរបស់គេទេ។

**ស៖** សូមអរគុណលោកស្រីសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសួរចប់ ហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បន្តផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រី ស៊ូ សឿន! ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៅនឹងចម្លើយរបស់លោកស្រី។ ជាបឋម ខ្ញុំចង់បានការបញ្ជាក់អំពីលោកស្រីពាក់ព័ន្ធទៅនឹងមជ្ឈដ្ឋានសង្គមរបស់ឪពុកម្តាយលោកស្រី។

តើពិតទេដែលថា គ្រួសាររបស់លោកស្រីហ្នឹង ជាគ្រួសារកសិករ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ការពិតមែន គឺគាត់ធ្វើកសិករ ធ្វើស្រែតាំងពីក្មេងរហូតដល់ចាស់ រហូវដល់ការតស៊ូ និយាយពីរឿងអ៊ីចេះតែម្តង។ ហើយខាងរៀនអក្សរសាស្ត្រ វប្បធម៌ក៏ទាបដែរ គាត់មិនចេះអីជ្រៅជ្រះទេ គឺកសិករសុទ្ធសាធ។ ចាស ខ្ញុំជម្រាបប៉ុណ្ណឹង។

[១៤:០៥:៣៦]

**ស៖** ហើយប្តីលោកស្រី និងលោកស្រីហ្នឹង មានដើមកំណើតនៅតំបន់តែមួយមែនទេ?

**ឆ៖** ចាស នៅតំបន់តែមួយ ស្រុកតែមួយ គ្រាន់តែភូមិខុសគ្នា។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានរៀបការនៅឆ្នាំ៥៨ ហើយនៅឆ្នាំ៧៦ គេចាត់តាំងឲ្យលោកស្រីធ្វើការនៅក្នុងគណៈស្រុកចំការលើ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ លោកស្រី?

**ឆ៖** ចាស ប្រហែលជាខ្ញុំអត់ចាំ មិនដឹងជាមកហ្នឹង គឺគេចាត់តាំងពីណា។ ខ្ញុំយល់ថា គេរៀបចំឆ្នាំចិតប៉ុន្មាន ក៏ដូចមិនចាំ។

**ស៖** អ៊ីចឹងពិតទេ ថាលោកស្រីធ្វើការនៅគណៈស្រុកហ្នឹង នៅចំការលើ មែនទេ?

**ឆ៖** ចាស នៅចំការលើមែន ប៉ុន្តែធ្វើបាន១ឆ្នាំ។

**ស៖** មិនអីទេ ខ្ញុំយល់ហើយ។ ចុះមុនពេលនៅចំការលើ គឺលោកស្រីបានចំណាយពេល៦ខែនៅកំពង់ធំ មែនទេ?

**ឆ៖** ចាស ខ្ញុំដូចអត់ចាំ។ ឥឡូវ ចំណាយខែ -- អ៎! ចំណាយ៦ខែ នៅកំពង់ធំ ខ្ញុំដូចអត់បានចាំទេ ព្រោះវាភ្លេចបាត់ហើយ។

**ស៖** ចុះកន្លែងដែលលោកស្រីជួបប្តីលោកស្រីហ្នឹង គឺជួបគ្នានៅក្នុងស្រុកណាដែរ?

**ឆ៖** ដូចថា -- ចាស ចេញពីផ្ទះទៅ ឬមួយក៏លោកប្រធានចង់សួរពីឆ្នាំណា ចេញទៅជួបប្តី?

**ស៖** ខ្ញុំដឹងថា ខ្ញុំចង់ពីស្រុកដែលលោកស្រីរស់នៅជាមួយឪពុកម្តាយ ហើយនិងស្រុកដែលលោកស្រីបានគ្នាជាប្តីប្រពន្ធជាមួយប្តីលោកស្រីនោះ?

[១៤:០៨:២៦]

**ឆ៖** ចាស ដល់ពេលខ្ញុំនៅជាមួយឪពុកម្តាយ ដល់ពេលបានជួបគ្នាជាគ្រួសារ ក៏នៅក្នុងស្រុកហ្នឹងដែរ។ នៅស្រុកឈូកខ្សាច់ហ្នឹង នៅឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ក្រោយមក

ខ្ញុំមករកស៊ី គេហៅស្រុកចំការអណ្ដូង នៅធ្វើចម្ការធ្វើស្រែនៅចំការអណ្ដូង។ មានតែពីរកន្លែងហ្នឹងទេ មកពីស្រុកមក មករកស៊ី ធ្វើចម្ការនៅចំការអណ្ដូង តែឲ្យដឹងឆ្នាំណា ដែលត្រូវចេញពីផ្ទះ។ ឆ្នាំណា ត្រូវនៅចំការអណ្ដូង ខ្ញុំអត់ចាំ។

**ស៖** នៅពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រីបាន លើកឡើងអំពីមន្ទីរពេទ្យដែលមាននៅក្នុងស្រុកចំការលើ នៅពេលដែលលោកស្រីធ្វើការនៅទីនោះ។ លោកស្រីពន្យល់ថាមានកម្រិតផ្សេងៗគ្នា ខ្ញុំមិនចង់បំភ្លៃសម្ដីរបស់លោកស្រីទេ អ៊ីចឹងខ្ញុំនឹងដកស្រង់ សម្ដីរបស់លោកស្រីកាលពីម្សិលមិញ គឺប្រហែលមុនម៉ោងដប់ប្រាំ ប្រាំបីនាទីបន្តិច លោកស្រីនិយាយថា "នៅថ្នាក់ស្រុកក៏មានមន្ទីរពេទ្យដែរ ហើយនៅសង្កាត់ហ្នឹង ក៏មានមន្ទីរពេទ្យដែរ។ យើងដោះស្រាយ បញ្ហាសុខភាពអ្នកជំងឺនៅតាមឃុំ នៅតាមសង្កាត់ បើសិនជាស្ថានភាពធ្ងន់ធ្ងរ យើងបញ្ជូនទៅមន្ទីរ ពេទ្យស្រុក ពីមន្ទីរពេទ្យសង្កាត់ទៅ។ ប្រសិនបើនៅតែធ្ងន់ធ្ងរទៀត យើងបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរ ពេទ្យតំបន់ ឬក៏មន្ទីរពេទ្យខេត្ត"។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកស្រីថា នៅពេលដែល លោកស្រីទៅដល់ចំការលើ តើលោកស្រីដឹងទេថា តាំងពីពេលណាមកដែលគេសាងសង់មន្ទីរពេទ្យឃុំ ឬក៏មន្ទីរពេទ្យសង្កាត់នេះ? លោកស្រីនៅចាំទេថា តើមន្ទីរឃុំ ឬមន្ទីរពេទ្យសង្កាត់ហ្នឹងមានតាំងពីពេល ណាមក?

[១៤:១១:០៣]

**ឆ៖** ចាស ពេលលោកប្រធានសួរអ៊ីចឹង ខ្ញុំក៏ភ្លាប់មិនបានដែរ ព្រោះការរៀបចំ ដឹងគេរៀបចំពី ពេលណាមក ព្រោះទៅក្រោយគេ គេដឹងតែប្រធាន -- គេនិយាយតែរៀបចំមន្ទីរពេទ្យស្រុក ហើយមន្ទីរ សង្កាត់។ មន្ទីរពេទ្យសង្កាត់ក៏មាន មន្ទីរពេទ្យស្រុកក៏មាន ប៉ុន្តែរៀបពីឆ្នាំណា ខ្ញុំអត់ចាំទេ។

**ស៖** មិនចាំបាច់បញ្ជាក់ឆ្នាំទេ លោកស្រីគ្រាន់តែបញ្ជាក់ថាគេរៀបចំពេទ្យសង្កាត់ហ្នឹងតាំងពីមុន របបខ្មែរក្រហមទៅទៀតនៅក្នុងរបបលន់ នល់ ឬក៏គេរៀបចំនៅក្នុងរបបលន់ នល់។ លោកស្រីអាច បញ្ជាក់បានទេថា គេរៀបចំមន្ទីរពេទ្យឃុំ ឬសង្កាត់ហ្នឹងក្នុងរបបណាដែរ?

**ឆ៖** ចាស ការរៀបចំមន្ទីរពេទ្យហ្នឹង គឺរៀបចំក្នុងសម័យពួកខ្ញុំអ្នកធ្វើការហ្នឹង ប៉ុន្តែគ្រាន់តែថា មិនចាំថ្ងៃ មិនចាំខែ មិនចាំឆ្នាំ។ រៀបចំ ពេលរៀបចំធ្វើស្រែធ្វើចម្ការចែកជាសហករណ៍ហ្នឹង គេរៀបចំ មន្ទីរពេទ្យតែម្ដង។ អាហ្នឹង គឺរៀប -- តាមខ្ញុំចាំ គឺអ៊ីចឹង។

**ស៖** ដូច្នេះ បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺគេរៀបចំមន្ទីរពេទ្យហ្នឹង គឺនៅក្នុងអំឡុងរបបខ្មែរ

ក្រហមតែម្តង គឺអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីប្រសូត្រពីគ្រួសារកសិករ ហើយលោកស្រីរស់នៅក្នុងស្រុកបារាយណ៍ (សូមទោស) គឺកំពង់ធំ បន្ថែមពីលើបទពិសោធន៍នៅចំការលើ។ អ៊ីចឹងខ្ញុំចង់ដឹងថា នៅក្នុងអំឡុងយុវវ័យនោះ ពេលដែលលោកស្រីនៅក្នុងជាយុវវ័យនុ៎ង តើមានពេទ្យច្រើនទេនៅក្នុងស្រុកបារាយណ៍?

[១៤:១៣:៤៨]

**ឆ៖** ចាស អង្កាល់ខ្ញុំនៅវ័យក្មេង ដឹងស្រាប់ហើយពីសង្គមនុ៎ង ទៅមួយៗមិនមែនមានកង់ម៉ូតូជិះ ដឹងទៅដឹងថា រៀបចំមន្ទីរពេទ្យបារាយណ៍មានប៉ុន្មាន ឃុំមានប៉ុន្មាន គឺខ្ញុំអត់ដឹងទេ។ សម័យនោះដើររហូតដូចអ៊ីចេះ កន្លែងមួយទៅកន្លែងមួយវាឆ្ងាយដែរ។ ដូច្នេះ ខ្ញុំមិនសូវបានការរៀនសូត្រផងក៏មិនសូវបានទៅណា នៅធ្វើស្រែធ្វើចម្ការជាមួយម៉ែឪ។ ការរៀបចំមន្ទីរពេទ្យ ទាល់តែអ្នកឈឺខ្លាំងបានស្គាល់មន្ទីរពេទ្យ បើឈឺល្មមៗនៅនឹងផ្ទះហ្នឹង។ នេះខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកស្រីចាំទេ នៅពេលដែលលោកស្រីនៅក្មេងហ្នឹង ពេលលោកស្រីឈឺម្តងៗលោកស្រីទៅមន្ទីរពេទ្យណាដែរ?

**ឆ៖** ចាស ពេលខ្ញុំឈឺ ឬក៏គ្រួសារ ក៏ម៉ែឪខ្ញុំឈឺ ស្រុកពីដើម ស្រុកស្រែមិនសូវទៅរកមន្ទីរពេទ្យទេ។ គេមានជំនឿគេ ដូច្នេះ គេមានជំនឿគ្រូ ជំនឿអារក្សអ៊ីចឹង បន់ទៅ ជាទៅ ផឹកថ្នាំខ្មែរទៅ ជាទៅ។ ដូច្នេះ ក្រលំបាកមិនបានទៅដល់មន្ទីរពេទ្យ ដល់ស្រុកទេ។ នេះ ខ្ញុំជម្រាប។

**ស៖** នៅពេលដែលលោកស្រីនិយាយថា លោកស្រីប្រើថ្នាំបុរាណហ្នឹង តើមានគ្រូៗខ្មែរទេ ឬក៏លោកស្រីលេបថ្នាំហ្នឹងលេបតែខ្លួនឯង នៅក្នុងគ្រួសារហ្នឹងធ្វើលេបខ្លួនឯង ឬក៏មានគ្រូខ្មែរគេអ្នកចេញថ្នាំហ្នឹងឲ្យ?

**ឆ៖** ចាស ពីសង្គម គឺមានគ្រូខ្មែរគេ កាប់ដើមឈើលក់ឲ្យអ្នកដែលកសិករយើង ខ្លះក៏ស្គាល់បងស្គាល់ប្អូនទៅ គេកាប់ឲ្យទៅ។ ថ្នាំក្តៅ ថ្នាំត្រជាក់ចុះ -- បញ្ចុះកំដៅអី មានអី មានតែសម្បកគយកមកបំពោកទៅ ហើយផឹកថ្នាំទៅ ថ្នាំខ្មែរហ្នឹង ផឹកទៅក៏ត្រជាក់ទៅ ជាទៅ។ អាហ្នឹង និយាយពីរឿងការរស់នៅរបស់កសិករ គឺអ៊ីចឹង។ មិនសូវស្គាល់ទេ មន្ទីរពេទ្យ។ ហើយពីដើមក៏មិនសូវឈឺផង ចាស ខ្ញុំជម្រាបប៉ុណ្ណឹង។

[១៤:១៦:៣៨]

**ស៖** ខ្ញុំក្នុងការបកប្រែអម្បាញ់មិញនេះ ខ្ញុំឮថា នៅក្នុងរបប ខ្ញុំចង់ដឹងថា លោកស្រីសំដៅលើរបបមួយណាដែរ?

**ឆ៖** ចាស ខ្ញុំឮដូចថា ខ្ញុំស្ដាប់មិនទាន់ ឬយ៉ាងម៉េច? ខ្ញុំដូចថា លោកស្រីសួរ -- លោកប្រធានសួរខ្ញុំថា ពីសម័យសង្គមណាទៅរកមន្ទីរពេទ្យ? ខ្ញុំឆ្លើយតាមខ្ញុំរស់នៅតាមពីសង្គមចាស់ យើងពីដើមមកពេលមិនទាន់កើតកុម្មុយនីស្ដឯណា ដូច្នេះខ្ញុំនិយាយពីរឿងខ្ញុំនៅក្មេង។ លោកសួរខ្ញុំថានៅក្មេង ខ្ញុំក៏និយាយតាមនៅក្មេង នៅយុវវ័យ និយាយតាមគ្រូខ្មែរ គ្រូអីហ្នឹង មន្ទីរពេទ្យហ្នឹង មិនសួរបានទៅដល់ទេ អានេះខ្ញុំសំដៅអ៊ីចឹង។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ឥឡូវនេះ ខ្ញុំចូលទៅចំណុចផ្សេង គឺពាក់ព័ន្ធទៅនឹងទំនប់១មករា ជាពិសេស។ លោកស្រីបានឆ្លើយបញ្ជាក់ទៅនឹងមេធាវី នួន ជា ថាលោកស្រីដឹងថាការសាងសង់ទំនប់១មករានេះ គឺដើម្បីកែលម្អបញ្ហាកសិកម្ម ហើយនិងដើម្បីឲ្យមានស្បៀងអាហារគ្រប់គ្រាន់។ កាលពីម្សិលមិញ ក្រោយម៉ោងដប់បួន ដប់ប្រាំពីរនាទី លោកស្រីបាននិយាយថា គេធ្វើទំនប់ហ្នឹងគឺសម្រាប់ប្រជាជននៅក្នុងតំបន់ហ្នឹង រហូតទៅដល់ស្រុកបារាយណ៍។ កាលពីម្សិលមិញដដែលហ្នឹងក៏លោកស្រីបានឆ្លើយថា លោកស្រីទៅទំនប់កន្លែងដែលគេធ្វើការហ្នឹង គឺទៅញឹកញាប់ដែរ។

អ៊ីចឹង លោកស្រីអាចកំណត់បានទេថា តើអ្នកដែលធ្វើការដែលមកពីស្រុករបស់លោកស្រីហ្នឹងទៅធ្វើការនៅទំនប់ហ្នឹង គឺបើយើងគិតទៅថា គាត់ -- ពួក -- ទំនប់ -- ផ្នែកដែលពួកគាត់ធ្វើការហ្នឹងស្ថិតនៅក្នុងឃុំណាដែរ?

**ឆ៖** ខ្ញុំអត់ចង់បញ្ជាក់សាឡើងវិញទេ ព្រោះខ្ញុំនិយាយច្រើនដងហើយ។ ទំនប់១មករាៗហ្នឹងគឺថាតាំងពីថ្ងៃខ្ញុំចូលមករហូតដល់ថ្ងៃនេះ ចង់បញ្ជាក់យ៉ាងម៉េច? លោកប្រធាន បញ្ជាក់យ៉ាងម៉េច? ខ្ញុំនិយាយហើយ និយាយទៀតៗពីរបីសា គួរតែថាឲ្យខ្ញុំភ្លាប់បាន ព្រោះទំនប់១មករាហ្នឹង ខ្ញុំបានជម្រាបហើយថា ខ្ញុំទៅដូចជាភ្ញៀវទេ ខ្ញុំមិនមែនទៅជាអ្នកគ្រប់គ្រង ឬក៏អ្នកអីទេ ទៅមួយភ្លែតៗ។ ដូច្នេះអារឿងទំនប់១មករាហ្នឹង ខ្ញុំបានឮនឹងត្រចៀកហើយ ហើយបញ្ជាក់ហើយបញ្ជាក់ទៀត ហើយត្រង់កន្លែងទំនប់១មករា គឺនៅស្រុកកំពង់ថ្មៗ ខ្ញុំបានជម្រាបហើយ ជម្រាបទៀត។ ធ្វើឲ្យខ្ញុំនិយាយយ៉ាងម៉េចទៀត!

[១៤:២០:២២]

**ស៖** លោកស្រីសាក្សី ខ្ញុំយល់ថា លោកស្រីអស់កម្លាំង គេសួរលោកស្រីច្រើន ប្រហែលសំណួរអាចច្រំដែល ក៏ប៉ុន្តែខ្ញុំសួរគឺដើម្បីសុំការបញ្ជាក់ពីលោកស្រី ពីព្រោះថា ចម្លើយលោកស្រីហ្នឹងពេលខ្លះទៅវាមិនសូវច្បាស់អ៊ីចឹងហើយបានជាខ្ញុំសួរបញ្ជាក់។ ខ្ញុំយល់អំពីសក្ខីកម្មរបស់លោកស្រីដែលលោកស្រីបញ្ជាក់ថា លោកស្រីមិននៅ មិនទៅទំនប់ហ្នឹងញឹកញាប់ទេ ហើយខ្ញុំក៏យល់ដែរថា គឺទំនប់ហ្នឹងស្ថិតនៅក្នុងស្រុកកំពង់ធំ។ ក៏ប៉ុន្តែនៅចំពោះមុខតុលាការនេះ សាក្សីជាច្រើនបានមកផ្តល់សក្ខីកម្ម ហើយយើងយល់ថា ទំនប់នេះគឺថាវាលាតសន្ធឹងច្រើនគីឡូម៉ែត្រណាស់ ហើយកម្មករហ្នឹងអាចធ្វើការក្នុងឃុំផ្សេងៗគ្នា អ៊ីចឹងហើយបានខ្ញុំចង់ដឹងថា នៅទីតាំងដែលលោកស្រីបានឃើញទោះបីជាឃើញម្តងម្កាលក៏ដោយនោះ ឃើញអ្នកដែលមកពីស្រុកលោកស្រីធ្វើការនោះ ខ្ញុំចង់ដឹងថា ទីតាំងដែលពួកគាត់ធ្វើការហ្នឹងគឺស្ថិតនៅផ្នែកណានៃទំនប់ គឺស្ថិតនៅក្នុងឃុំណាឲ្យប្រាកដ។ ខ្ញុំមិនដឹងថា សំណួរខ្ញុំច្បាស់ ឬមិនច្បាស់ទេ។

[១៤:២១:៤០]

**ឆ៖** ចាស សំណួរសួរខ្ញុំគឺច្បាស់ហើយ ប៉ុន្តែគ្រាន់ថា បើទំនប់ហ្នឹងគឺនៅក្នុងស្រុកកំពង់ថ្ម មិនមែនស្រុកកំពង់ធំទេ កំពង់ធំជាខេត្ត កំពង់ថ្មជាស្រុក ហើយធ្វើលាតសន្ធឹងរាប់រយគីឡូ។ ដូច្នេះ វាមិនដឹងជាចូលភូមិណា ឃុំណា អ៊ីចឹងបានខ្ញុំគ្រាន់តែថា ស្រុកៗកំពង់ថ្ម ហើយខេត្តកំពង់ធំ។ ឯប្រជាជនវាច្រើនផ្នែករាប់ម៉ឺនរាប់សែននាក់ ឲ្យខ្ញុំចាំយ៉ាងម៉េច! ហើយខ្ញុំទៅក្នុងនាមអ្នកដើរលេង។

**ប្រធានអង្គជំនុំ៖**

លោកស្រី ស៊ូ សឿន អ៊ីចេះណ៎ះ! ទី១ លោកស្រីមានករណីយកិច្ចឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគី។ បញ្ហាទី ២ គឺ ប្រសិនបើសំណួរណាដែលសួរទៅ ហើយលោកស្រីមិនដឹង គឺលោកស្រីឆ្លើយថាមិនដឹងទៅ វាជាការ ក៏ជាៗចម្លើយតបនឹងសំណួរដែរ។ មិនជៀសវាងបញ្ហាប្រឈមជាមួយនឹងភាគីពាក់ព័ន្ធដែលមានសិទ្ធិក្នុងការតាំងសំណួរសាក្សី ព្រោះនេះជានីតិវិធីសួរតាមបែបតុលាការអាចសំណួរដដែល ប៉ុន្តែវាមិនមែនដដែលសុទ្ធសាធទេ បើដដែលហើយ តុលាការមិនអនុញ្ញាតឲ្យភាគីតាំងសំណួរដដែលៗចំពោះសាក្សីទេ។ ប៉ុន្តែវាមានសំណួរខុសៗគ្នា គ្រាន់តែស្រដៀងគ្នាបន្តិចបន្តួចស្រដៀងៗគ្នាព្រោះជាការបញ្ជាក់បន្ថែមឲ្យច្បាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១៤:២៣:៤៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំយល់ថាលោកស្រីមិនចាំទេ ថាផ្នែកដែល ផ្នែកទំនប់ដែលកម្មករមកពីស្រុករបស់លោកស្រីធ្វើហ្នឹងនៅកន្លែងណា។ ឥឡូវនេះខ្ញុំចង់និយាយអំពីចំនួនកម្មករ។ កាលពីម្សិលមិញលោកស្រីនិយាយថាប្រហែលជាកម្មករ២០.០០០ ទៅដល់ ៣០.០០០ ឬក៏អាចទៅដល់ ៤០.០០០ផងនៅទំនប់នោះ នៅការដ្ឋាននោះ។ កូនប្រុសរបស់លោកស្រី –កែ ពេជ្រវណ្ណៈ– ដែលត្រូវបានស្តាប់ចម្លើយនៅក្នុងឯកសារ E3/35, ERNជាភាសាបារាំង គឺ 00367721, ERNជាភាសាខ្មែរ 00340563, ជាភាសាអង់គ្លេស 00346149 ទៅដល់ 50។ កូនប្រុសរបស់លោកស្រីបានឆ្លើយទៅនឹងសំណួរដែលគេសួរថា "តើអ្នកណាជាអ្នកទទួលខុសត្រូវនៅការដ្ឋានទំនប់១មករា?" គាត់បានឆ្លើយដូចតទៅ៖ "គឺគណៈភូមិភាគកណ្តាលជាអ្នកទទួលខុសត្រូវរួម។ គណៈកម្មាធិការនោះមានគ្នាបួននាក់ គឺមានឪពុករបស់ខ្ញុំ ពូស្រេច ពូគុល និងពូចន។ ពូស្រេង ពូគុល និងពូចន ជាគណៈតំបន់៤១, ៤២ និង ៤៣។ គណៈតំបន់ទាំងបីជាអ្នករៀបចំប្រមូលកម្លាំងមកលើកទំនប់ ១មករា នោះ។ តាមផែនការ មួយតំបន់ត្រូវការមនុស្ស ១០.០០០នាក់ ប៉ុន្តែជាក់ស្តែងខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានទេ។ ហើយកម្លាំងទាំងនោះ ត្រូវមានការផ្លាស់ប្តូរវេនគ្នាផងដែរ"។ សូមបញ្ចប់ការដកស្រង់ចម្លើយរបស់កូនលោកស្រី។ អ៊ីចឹងតាមរយៈចម្លើយរបស់កូនលោកស្រីហ្នឹងគឺយើងឃើញថា ប្រហែលជាមានមនុស្ស ៣០.០០០នាក់ដែលធ្វើការនៅការដ្ឋានទំនប់១មករានោះ។ អ៊ីចឹងលោកស្រីមានចងចាំ មានចាំអំពីផែនការហ្នឹងទេថា ចំនួន ៣០.០០០ហ្នឹងគឺវាត្រឹមត្រូវជាង វាមិនដូចដែលលោកស្រីឆ្លើយពីម្សិលមិញថា ៤០.០០០ទេ។

**ឆ៖** ចាស ប្រហែលជាត្រឹមត្រូវប៉ុណ្ណឹងហើយ ព្រោះខ្ញុំចេះតែនិយាយលើកឡូតែថា ៣០.០០០ ទៅ ៤០.០០០ អាហ្នឹងមាត់វាចេះតែថា ៣០.០០០ ទៅ ៤០.០០០ ដូចតែ ៣០០០ ទៅ ៤០០០អ៊ីចឹង។ មាត់វា គេហៅថា ជាប់ពាក្យស្លោកអ៊ីចឹង។ តែការពិតទៅ ប្រហែលជា ៣០.០០០មែន។

**ស៖** នៅពេលដែលលោកស្រីនិយាយថា -- អ៊ីចេះវិញ គឺថា ម្សិលមិញនៅពេលដែលគេសួរថាតើមនុស្សមកពីស្រុកលោកស្រីប៉ុន្មាននាក់ដែលធ្វើការនៅទំនប់នោះ? លោកស្រីបាននិយាយថាលោកស្រីមិនដឹងទេ។ អ៊ីចឹងបើលោកស្រីមិនដឹងអ៊ីចឹង តើលោកស្រីផ្អែកលើមូលដ្ឋានអីបានជាលោកស្រីប៉ាននិយាយថា មនុស្សធ្វើការនោះ គឺមាន ៣០.០០០នាក់នៅការដ្ឋាននោះ បើគ្រាន់តែស្រុកលោកស្រីៗមិនដឹងផង ថាមានមនុស្សប៉ុន្មាននាក់ទៅធ្វើការ។ អ៊ីចឹងលោកស្រីអាចសន្និដ្ឋានថា ជារួម ៣០.០០០នាក់

ហ្នឹងបានដោយផ្អែកលើមូលដ្ឋានអីដែរ?

[១៤:២៧:៥១]

**ធ៖** ចាស ខ្ញុំដូចថា វា -- ខ្ញុំបានជម្រាបហើយថា ផ្អែកលើកម្លាំងតាមស្រុកនីមួយៗ ប៉ុនគ្រាន់ស្រុកខ្ញុំហ្នឹងគឺ ខ្ញុំពឹងផ្អែកទៅលើស្រុករបស់ខ្ញុំគាត់អ្នករៀបចំ អ្នកកាន់បញ្ជី។ ដូច្នេះ ខ្ញុំអត់បានអានអត់បានសរសេរ អត់បានមើលសៀវភៅ ដូច្នេះអត់ចាំ អត់ចាំទេ មិនដឹងចំនួនប៉ុន្មាន? តាមសង្កាត់មួយៗក៏មិនដឹងចំនួនប៉ុន្មាន? ក្នុងរួម ក្នុងសង្កាត់ ដូចថា មួយស្រុកចម្ការលើមាន ប្រាំសង្កាត់ ក្នុងមួយសង្កាត់ៗតើគេយកប៉ុន្មាន ខ្ញុំអត់ចាំភ្លេចអស់ មិនចាំតែម្តង។

**ស៖** មិនអីទេ លោកស្រី ខ្ញុំឈប់សួរលោកស្រីពីរឿងតួលេខនេះហើយ។ លោកស្រីបានឆ្លើយថាលោកស្រីកម្រទៅការដ្ឋានទំនប់ ១មករាណាស់។ ក៏ប៉ុន្តែលោកស្រីបញ្ជាក់ថា ពេលដែលលោកស្រីទៅទីនោះ គឺមិនឃើញមានគ្រឿងម៉ាស៊ីនអីទេ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹងថាសាក្សីជាច្រើនបានមកផ្តល់សក្ខីកម្មនៅទីនេះ ហើយអ្នកខ្លះបាននិយាយថា មានគ្រឿងម៉ាស៊ីន មានគ្រឿងចក្រ ដូចជាលោក ឱ ហូ, ប៊ុច សុខា, អ៊ុត សេង ជាដើមនោះ គាត់និយាយថា គាត់ឃើញមានម៉ាស៊ីន មានគ្រឿងចក្រនៅពេលដែលបែករបបខ្មែរក្រហម។ ហើយមានមនុស្សម្នាក់ទៀតនោះ ដែលធ្វើការជាមួយប្តីរបស់លោកស្រីនោះ គឺឈ្មោះ អៀង ចាម។ តើលោកស្រីធ្លាប់ឮឈ្មោះហ្នឹងទេ?

**ធ៖** ចាស ខ្ញុំសូមបញ្ជាក់។ រឿងកម្លាំងធ្វើទំនប់នេះ គឺដឹងតែកម្លាំងពលកម្មជាមនុស្សហើយ។ ប៉ុន្តែខ្ញុំបាននិយាយបញ្ជាក់ថា ក្រោយមកគឺឃើញមានគ្រឿងចក្រទៅជួយ ជួយរុញ ជួយនេះដែរ ខ្ញុំបានបញ្ជាក់អ៊ីចឹងហើយចាស។ ហើយខ្ញុំសូមតទៀតថា អ្នកដែលឆ្លើយថា ឈ្មោះ ដូចខាងលើមិញនេះ ខ្លះក៏ស្គាល់ ខ្លះងាប់បាត់ទៅ។ ខ្ញុំសូមជម្រាបប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរបំភ្លឺពាក់ព័ន្ធនឹងចម្លើយរបស់លោកស្រី លោកស្រីថា ក្រោយមកថាមានម៉ាស៊ីនមកជួយកម្មករ។ អ៊ីចឹង លោកស្រីចាំថា នៅពេលណាដែរ ដែលមានគ្រឿងម៉ាស៊ីនហ្នឹងមកជួយកម្មករហ្នឹង?

**ធ៖** ចាស ខ្ញុំដូចអត់ចាំ អត់ដឹងឆ្នាំណា អត់បានចាំទេ ដឹងថា ក្រោយមក ទំនប់ហ្នឹងកកើតជាដូចថាជាថ្នល់ចុះ បានឃើញទំនប់ -- អ៎! គ្រឿងចក្រហ្នឹងគេទៅជួយ គេទៅជួយខ្វា ជួយរុញ ជួយទាញអានេះគ្រាន់តែឃើញទេ។ អាហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។ តែឆ្នាំអី ខ្ញុំអត់ចាំ។

[១៤:៣១:២២]

**ស៖** អៀង ឆាំ ប្រហែលជាលោកស្រីមិនចាំគាត់ទេ ប៉ុន្តែគាត់បានឆ្លើយនៅក្នុងឯកសារE3/5513 គឺនៅសំណួរចម្លើយ៦៤។ ពេលនោះ គេសួរគាត់ដូចតទៅ៖ “ក្នុងការសាងសង់ទំនប់ និងស្ពាន១មករា តើមានឧបករណ៍បច្ចេកទេសអ្វីខ្លះដែលគេប្រើប្រាស់?” គាត់ឆ្លើយដូចតទៅ៖ “នៅក្នុងផ្នែករបស់ខ្ញុំ គេប្រើឧបករណ៍ដូចជា ដេកាត់ ដេស៊ីស ដេសេត អាប៊ុល មានប្រដាប់វាយថ្ម គឺសម្រាប់ -- មានឧបករណ៍លើកថ្ម លើកដីលើកអីទៀត”។ សូមបញ្ចប់ការដកស្រង់។ តើនៅខាងស្រុករបស់លោកស្រីហ្នឹង លោកស្រីមានឃើញអាប៊ុល មានឃើញម៉ាស៊ីនចាក់បេតុង មានឃើញម៉ាស៊ីនលើកដី មានឃើញអីទេ?

**ឆ៖** ខាងស្រុកខ្ញុំមិនមានទេ មានតែកម្លាំង។ ឃើញកម្លាំងទំនប់ភ្លោះ ប្រឡាយ អត់ឃើញគ្រឿងចក្រទៅទេ។

**ស៖** ប៉ុន្តែអម្បាញ់មិញនេះ លោកស្រីនិយាយថា នៅពេលណាមួយនោះគេមានគ្រឿងចក្រមកជួយធ្វើការ។ អ៊ីចឹង លោកស្រីចាំទេថា គ្រឿងហ្នឹង គ្រឿងចក្រប្រភេទណាខ្លះដែលគេយកមកដល់ការដ្ឋានហ្នឹង?

**ឆ៖** ចាស ការដ្ឋានហ្នឹងការដ្ឋានស្រុកចំការលើតែម្តងឬម៉េច? អ៊ីចឹងបានខ្ញុំសួរ។

**ស៖** គឺនៅការដ្ឋានធ្វើការ។ អ៊ីចឹងលោកស្រីនិយាយអំពីគ្រឿងម៉ាស៊ីនហ្នឹង មិនមែននៅទំនប់១មករាទេ លោកស្រីនិយាយពីគ្រឿងម៉ាស៊ីននៅស្រុកលោកស្រីទេ ឬក៏ខ្ញុំស្តាប់ច្រឡំ?

**ឆ៖** ចាស ខ្ញុំចង់សួរអ៊ីចឹងដែរ។ សួរបញ្ជាក់ថា ខ្ញុំដឹងតែនៅទំនប់១មករា តែនៅចំការលើជីកប្រឡាយតែកម្លាំងនោះទេ។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង។

[១៤:៣៤:០៤]

**ស៖** អ៊ីចឹង នៅពេលដែលលោកស្រីនិយាយអំពីគ្រឿងចក្រមកដល់នៅពេលក្រោយហ្នឹង លោកស្រីសំដៅ មកដល់ស្រុកណាដែរ មិនមែនស្រុកចំការលើទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំសំដៅទៅទំនប់១មករាហ្នឹង ក្រោយមកបានឃើញគ្រឿងចក្រទៅដល់ ប៉ុន្តែគ្រាន់តែថាឆ្នាំណាៗ ខ្ញុំអត់ចាំ។ បានតែឃើញ។ បានឃើគ្រឿងចក្រទៅជួយកម្លាំងបងប្អូនសហករណ៍ហ្នឹងតែឆ្នាំណា ខ្ញុំអត់ចាំ។

**ស៖** ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីអាចសង្កេតឃើញនៅទំនប់១មករា លោកស្រីបានឆ្លើយថា គឺមានបញ្ហាអនាម័យ មានរុយ។ ដោយសារតែសាក្សីមួយចំនួនដែលមកផ្តល់

សក្ខីកម្មនៅទីនេះ គាត់បាននិយាយអំពីការបាញ់ថ្នាំកម្ចាត់មូស។ អ៊ីចឹងតើលោកស្រីមានដឹងទេថាគេបាញ់ថ្នាំកម្ចាត់រុយទេ?

**ឆ៖** ចាស ខ្ញុំភ្លេចអត់បានដែរ។ រឿងបាញ់ថ្នាំអ៊ីខ្ញុំភ្លេចអត់បានទេ។

**ស៖** លោកស្រីក៏បាននិយាយអំពីការប្រើប្រាស់ទឹកនៅការដ្ឋានទំនប់ ១មករា។ លោកស្រីបានបញ្ជាក់ថា កម្មករដងទឹកពីស្ទឹង ពីប្រភពទឹកមួយចំនួន -- សាក្សី អ៊ុត សេង គាត់បានពន្យល់ថា នៅកន្លែងខ្លះនុំង គេមានដាំទឹកឲ្យកម្មករផឹក ដើម្បីឲ្យមានអនាម័យល្អ។ អ៊ីចឹងតើលោកស្រីដឹងទេថា នៅផ្នែក ឬក៏នៅស្រុកលោកស្រីហ្នឹង គេមានចាត់វិធានការដូចគ្នាហ្នឹងទេ? គេដាំទឹកដើម្បីឲ្យកម្មករហូបនោះ?

**ឆ៖** ចាស តាមសហករណ៍គេដាំ ៗគ្រាប់សហករណ៍ទាំងអស់។ គេដាំឲ្យបងប្អូនហូប ឲ្យគេដាក់ថ្នាំខ្មែរក្នុងហ្នឹងទៀត ដើមឈើដើមអីដើម្បីការពារគ្រុនចាញ់ ការពាររាករូស។ ត្រង់ទំនប់ ១មករា ខ្ញុំភ្លេចអត់បានទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

សម្រាប់ជាប្រតិចារឹក អម្បាញ់មិញនេះ ខ្ញុំច្រឡំ ដោយសារនិយាយថាសាក្សី ការពិតមិនមែនទេ គឺដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា។ លោកប្រធានខ្ញុំត្រូវចូលទៅដល់ប្រធានបទថ្មី ហើយតើខ្ញុំ -- លោកប្រធានគិតថា ឈប់សម្រាកសិន ឬក៏ខ្ញុំបន្តទៀត?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ដល់ពេលសមស្របសម្រាកដែរហើយ។ បាទ ជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបីខ្វះប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨ នាទី ដល់ម៉ោង ១៤:៥៦ នាទី)*

[១៤:៥៦:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោកខៀវ សំផន សួរដេញដោលសាក្សី អង្គជំនុំជម្រះផ្សព្វផ្សាយនូវសេចក្តីសម្រេចលើសំណើសុំនានា សុំផ្អាកសវនាការទាក់ទិននឹងការដាក់បង្ហាញឯកសារពីក្នុងសំណុំរឿង០០៣ ឯកសារE319/23។

អង្គជំនុំជម្រះកត់សម្គាល់ពីការដាក់បង្ហាញចម្លើយសាក្សីនានាពីក្នុងសំណុំរឿង០០៣ ឯកសារ E319/23 និងឯកសារបន្តបន្ទាប់ទៀតនាពេលខាងមុខ និងសំណើនានាពីភាគី សុំពេលវេលាដើម្បីពិនិត្យមើលចម្លើយសាក្សីទាំងនេះ មុនពេលចាប់ផ្តើមសក្ខីកម្មសាក្សីទាក់ទិននឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។

តាមការលើកឡើងរបស់សហព្រះរាជអាជ្ញាចម្លើយសាក្សីចំនួនពីរក្នុងចំណោមចម្លើយនានា ក្នុងការដាក់បង្ហាញនេះ មានចំនួន ១៦ទំព័រជាភាសាអង់គ្លេស។ ពាក់ព័ន្ធនឹងការដ្ឋានព្រលានយន្តហោះកំពង់-ឆ្នាំង ចម្លើយសាក្សីទាំងពីរនេះ ត្រូវបានផ្តល់ជូនមេធាវីការពារក្តីនិងសហមេធាវីនាំមុខនៅថ្ងៃនេះ ដើម្បីផ្តល់ឱកាសឲ្យភាគីក្នុងការពិនិត្យលើចម្លើយសាក្សីទាំងពីរនេះ អង្គជំនុំជម្រះនឹងលើកការស្តាប់សក្ខីកម្មសាក្សីដែលត្រូវបានកំណត់ធ្វើនៅថ្ងៃចន្ទ ទី០៨ ខែមិថុនា ទៅធ្វើសវនាការស្តាប់សក្ខីកម្មនៅសប្តាហ៍ក្រោយចាប់ពីថ្ងៃអង្គារ រហូតដល់ថ្ងៃសុក្រវិញ។

[១៤:៥៨:៤៥]

មេធាវីការពារក្តីលើកឡើងបន្ថែមទៀតថា ចម្លើយសាក្សីផ្សេងទៀតដែលស្ថិតក្នុងការដាក់បង្ហាញនេះ ដែលជាប់ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុងនិងរចនាសម្ព័ន្ធយោធាក្នុងភូមិភាគបូព៌ា អាចទាក់ទងនឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងដែរ។

សហព្រះរាជអាជ្ញាលើកឡើងថា ចម្លើយសាក្សីទាំងនេះជាប់ពាក់ព័ន្ធតិចតួចទៅនឹងការដ្ឋាននានាប្រសិនបើមាន ហើយថា ចម្លើយសាក្សីទាំងអស់ដែលត្រូវបង្ហាញថ្មីៗ នឹងផ្តល់ជូនមេធាវីការពារក្តីនិងសហមេធាវីនាំមុខ ត្រឹមថ្ងៃអង្គារសប្តាហ៍ក្រោយ។ ទោះបីជាការវាយតម្លៃពេញលេញទៅលើខ្លឹមសារនៃចម្លើយសាក្សីទាំងនេះ នឹងអាចធ្វើទៅបានបន្ទាប់ពីចម្លើយទាំងនេះត្រូវបានផ្តល់ឲ្យមេធាវីការពារក្តី និងសហមេធាវីនាំមុខក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ថា នៅរយៈពេលជាច្រើនខែទៀត ទម្រាំសវនាការដំណើរការទៅដល់ប្រធានបទ ស្តីពីការបោសសម្អាតផ្ទៃក្នុង ដែលពាក់ព័ន្ធជាចម្បង ដល់ចម្លើយសាក្សីទាំងនោះ។ ភាគីនឹងនៅមានពេលវេលាច្រើនទៀតនៅក្នុងការពិនិត្យលើចម្លើយសាក្សីនានា ដែលនៅសេសសល់មុនពេលចាប់ផ្តើមពិភាក្សាលើប្រធានបទស្តីពីការបោសសម្អាតផ្ទៃក្នុង រួមទាំងក្នុងអំឡុងពេល

ឈប់សម្រាកមិនធ្វើសវនាការនៅពាក់កណ្តាលឆ្នាំនេះផងដែរ។ ហេតុនេះ អង្គជំនុំជម្រះយល់ថា ពុំចាំបាច់ពន្យារពេលស្តាប់សក្ខីកម្មសាក្សីស្តីពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងដោយផ្អែកលើមូលដ្ឋាននេះទេ។ ទោះជាយ៉ាងណាអង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះនឹងពិចារណាទៅលើសំណើនានា ដែលមាន សំអាងហេតុដើម្បីកោះហៅសាក្សីសាជាថ្មីដោយផ្អែកលើមូលដ្ឋាននៃការដាក់បង្ហាញចម្លើយសាក្សីចុងក្រោយទៅតាមករណីជាក់ស្តែង។

ចុងក្រោយអង្គជំនុំជម្រះកត់សម្គាល់ថា ភាគីក៏បានស្នើសុំឲ្យអង្គជំនុំជម្រះពន្យារពេលស្តាប់សក្ខីកម្មសាក្សីស្តីពីការដ្ឋានទំនប់ត្រពាំងថ្ម រហូតដល់ក្រោយពេលឈប់សម្រាកមិនធ្វើសវនាការនៅពាក់កណ្តាលឆ្នាំនេះ ដើម្បីមានពេលវេលាច្រើនទៀត សម្រាប់ត្រៀមរៀបចំ សវនាការដែលត្រូវបានកំណត់កាលបរិច្ឆេទដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយ។ សំណើនេះ នឹងត្រូវដោះស្រាយក្នុងករណីសមស្រប។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១៥:០១:៤១]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រី ស៊ូ សឿន ខ្ញុំនឹងបន្តសួរបន្តិចទៀតទេ មិនយូរទៀតទេ សូមលោកស្រីកុំភ័យ។ លោកស្រីបាននិយាយថា នៅក្នុងក្របខ័ណ្ឌនៃការងារ -- មុខងាររបស់លោកស្រីក្នុងឋានៈជាសមាជិកគណៈស្រុក លោកស្រីមើលការខុសត្រូវលើសហករណ៍។ តើនៅក្នុងការមើលការខុសត្រូវនេះ លោក-ស្រីមានប្រជុំជាមួយនឹងប្រធានសហករណ៍ដែរឬទេ? ធ្លាប់ប្រជុំជាមួយប្រធានសហករណ៍ដែរឬទេ?

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំទទួលខុសត្រូវគឺ ខ្ញុំប្រជុំ ប៉ុន្តែមិនប្រជុំក្នុងសហករណ៍ទេ គឺហៅសង្កាត់ដែលគេទទួលខុសត្រូវនីមួយៗ ភូមិនីមួយៗ -- សង្កាត់នីមួយៗដើម្បីយកមកប្រជុំនៅស្រុក។ អានេះដែលឆ្នាំដែលខ្ញុំបានធ្វើ ការងារស្រុក។ សូមឆ្លើយប៉ុណ្ណឹង។

**ស៖** នៅក្នុងពេលប្រជុំនៅមន្ទីរស្រុក តើក្នុងឋានៈជាសមាជិកគណៈស្រុកហ្នឹង លោកស្រីធ្លាប់

ណែនាំប្រធានសហករណ៍ហ្នឹងឲ្យប្រព្រឹត្តទៅលើប្រជាជន១៧មេសា ខុសពីប្រជាជនមូលដ្ឋានដែរឬទេ?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ថា ពេលហៅប្រធានសង្កាត់ អញ្ជើញគាត់មកប្រជុំក្នុងការរៀបចំកម្លាំងនូវការងារ រៀបចំការងារ ក៏ដូចជារៀបចំធ្វើទំនប់ ធ្វើប្រឡាយ ក៏ដូចជារៀបចំម្ហូបអាហារបានរៀបចំសព្វគ្រប់ទាំងអស់ បានពិភាក្សាគ្នា ចាត់តាំងកម្លាំង អ្នកណាត្រូវនៅរៀបចំខាងផ្ទះបាយ អ្នកណារៀបចំទៅធ្វើការពលកម្ម គឺបានចាត់ចែងអ៊ីចឹង។

[១៥:០៤:០០]

**ស៖** បាទ ខ្ញុំយល់ពីចំណុចហ្នឹងហើយគឺថា នៅក្នុងការបែងចែកការងារ ហើយនិងការធ្វើផែនការ តើលោកស្រីធ្លាប់ណែនាំឲ្យប្រជាជន១៧មេសាហ្នឹង ទទួលរបបអាហារតិចជាងប្រជាជនមូលដ្ឋាន ប្រជាជនចាស់នោះ។ លោកស្រីធ្លាប់ចេញសេចក្តីណែនាំ យ៉ាងដូច្នេះដែរឬទេ?

**ឆ៖** ចាស មិនមែនការពិតដូចគេថា ប្រជាជនថ្មី ប្រជាជន១៧មេសា ហើយនិងប្រជាជនចាស់បែងចែកទេ គឺរោងបាយតែមួយ ការរៀបចំម្ហូបម្ហាតែមួយ។ អានេះ ខ្ញុំក្តាប់បាននៅក្នុងស្រុក ដែលតាមការរាយការណ៍របស់សង្កាត់។ អត់មានបែងចែកថា អ៊ូ! អ្នកថ្មី ឬអ្នកចាស់ អត់មានទេ។

**ស៖** នៅក្នុងចំណុចហ្នឹងដដែល លោកស្រីបានណែនាំប្រធានសហករណ៍និងប្រធានសង្កាត់ហ្នឹងឲ្យធ្វើបាបប្រជាជនថ្មី ព្រោះថាគេមានវណ្ណភាពមិនល្អ។ តើលោកស្រីធ្លាប់ចេញការណែនាំយ៉ាងដូច្នេះទៅប្រធានសហករណ៍ ហើយនិងប្រធានសង្កាត់ដែរឬទេ ចៅសង្កាត់ដែរឬទេ?

**ឆ៖** ចាស មិនមែនដូចពាក្យគេនិយាយទេ គឺគ្មានពីណានឹងបែងចែក ហើយនិងអ្នកថ្មី និងអ្នកចាស់ទេ គឺស្មើគ្នាទាំងអស់ ការហូបចុកការអីទាំងអស់ហ្នឹង។ តាមការពិត គឺខ្ញុំមិនបានណែនាំសង្កាត់ត្រូវធ្វើអ៊ីចេះ ធ្វើអ៊ីចុះ អារឿងអ្នកថ្មី រឿងអ្នកចាស់ អត់មានទេ។

[១៥:០៦:២០]

**ស៖** ខ្ញុំសួរលោកស្រីយ៉ាងដូច្នេះ ព្រោះយើងធ្លាប់ស្តាប់ឮសាក្សី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលបាននិយាយថា ដោយសារតែខ្លួននុ៎ងជាប្រជាជន១៧មេសា បានជាគេប្រព្រឹត្តលើខ្លួននោះ ខុសពីផ្សេង នៅលើកទំនប់១មករានេះ។ អ៊ីចឹងហើយ ខ្ញុំចង់ដឹងថា តើមកពីមានការណែនាំចេញពីភូមិភាគ ឬក៏តំបន់ ឬក៏លោកស្រីធ្លាប់ផ្ទាល់ហ្នឹង បានចេញសេចក្តីណែនាំយ៉ាងដូច្នេះ។ លោកស្រីឆ្លើយថា មិនធ្វើអ៊ីចឹងទេ លោកស្រីមិនបានណែនាំយ៉ាងដូច្នេះនោះទេ ហើយលោកស្រីក៏មិនដែលបានទទួលសេចក្តីណែនាំ ឬពីតំបន់ ឬពីភូមិភាគនោះដែរ ដែលណែនាំឲ្យប្រព្រឹត្តតែទៅលើប្រជាជនថ្មីហ្នឹង ខុសពី

ប្រជាជនចាស់នុង់ តើខ្ញុំសង្ខេបយ៉ាងដូច្នេះនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ បានលោកប្រធានរៀបចំបានមតិពន្យល់ខ្ញុំអ៊ីចឹង ខ្ញុំក៏យល់ស្របដែរ ព្រោះការរស់នៅក្នុងស្រុក ក្នុងសង្កាត់របស់ខ្ញុំ មិនដែលថាណែនាំប្រជាជនចាស់ ដើម្បីធ្វើបាបប្រជាជនថ្មី គឺមិនមានទេ។ ទស្សនៈមួយៗ គឺមិនមានធ្វើបាបប្រជាជនយើង ជាតិខ្មែរដូចគ្នាទេ។ ចាស សូមមានមតិតែប៉ុណ្ណឹង។

[១៥:០៨:០៣]

**ស៖** ខ្ញុំសន្មតថា លោកស្រីនិយាយពីបទពិសោធន៍របស់លោកស្រីផ្ទាល់នៅក្នុងស្រុករបស់លោកស្រី ក៏ប៉ុន្តែតើលោកស្រីយល់ស្របដែរឬទេ តើនៅកន្លែងផ្សេងទៀតនោះ ប្រធានសហករណ៍ ឬក៏នៅស្រុកផ្សេងទៀតនោះ មិនដឹងថាគេធ្វើយ៉ាងណានោះទេ គេប្រព្រឹត្តទៅលើប្រជាជនថ្មីហ្នឹង យ៉ាងណានោះទេ តើលោកស្រីយល់ស្របនឹងការនិយាយរបស់ខ្ញុំទេ?

**ឆ៖** ចាស ខ្ញុំក្តាប់មិនបានដែរ ក្តាប់បានតែនៅស្រុក ដល់តែអ្នកផ្សេង ទស្សនៈវាមិនខុសគ្នាប៉ុន្មានទេ ប្រជាជនថ្មី និងប្រជាជនចាស់ហ្នឹង បើតាមខ្ញុំយល់ខ្លះ។ ចាស មានប៉ុណ្ណឹង។

**ស៖** លោកស្រីបាននិយាយជាមួយចៅក្រម ឡាវ៉ែន អំពីការរៀនសូត្រដែលលោកស្រីបានទៅទទួលនៅភ្នំពេញ ទាក់ទងទៅនឹងការគ្រប់គ្រងសហករណ៍អីជាដើមនោះ។ តើលោកស្រីអាចបញ្ជាក់បានដែរឬទេថា នៅពេលប្រជុំទាំងអស់នោះ ការរៀនសូត្រទាំងអស់នោះ លោកស្រីមិនបានទទួលការណែនាំឱ្យធ្វើបាបប្រជាជន១៧មេសា ឬក៏ប្រព្រឹត្តលើប្រជាជន១៧មេសា ខុសពីប្រជាជនដែលចាស់នោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ថ្នាក់លើមិនដែលបានណែនាំប្រជា -- ណែនាំកម្មាភិបាលទៅទទួលពីគាត់ហ្នឹង គឺមិនបានណែនាំថា "អ្ហ៎! ប្រជាជនថ្មី ប្រជាជនចាស់ ត្រូវធ្វើបាបប្រជាជនថ្មី ត្រូវបង្អត់បាយបង្អត់អី" គឺអត់ទេ គាត់និយាយតែពីរឿងសហករណ៍ធ្វើម៉េចឱ្យបានជីវភាពគ្រប់គ្រាន់ ធ្វើស្រែធ្វើចម្ការដើម្បីបង្កើនផលឱ្យបានគ្រប់គ្រាន់ចែកបងប្អូនសហករណ៍ហូប ឱ្យមានកម្លាំងនឹងធ្វើពលកម្ម។ ចាស មានប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកស្រីសាក្សីដែលអត់ឆ្លើយសំណួរខ្ញុំ។

[១៥:១០:៣៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានខ្ញុំសួរចប់ហើយ ប៉ុន្តែសហភាតារបស់ខ្ញុំលោកមេធាវី គង់ សំអុន គាត់ចង់សួរបន្ត

ទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ។ លោក -- សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះនិងភាគី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកស្រី ស៊ូ សឿន! ខ្ញុំមានសំណួរតិចតួចទេដើម្បីសួរបញ្ជាក់ជាចុងក្រោយ ហើយខ្ញុំយល់ថាអ្នកស្រីហត់នឿយច្រើនហើយក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ហើយខ្ញុំសង្ឃឹមថាអ្នកស្រីនឹងជួយសហការដើម្បីឆ្លើយនូវសំណួរតាមលទ្ធភាព។ ទាក់ទងទៅនឹងឯកសារ E3/5794 ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី ត្រង់លេខ ERN ជាភាសាខ្មែរ 00348830, ភាសាអង់គ្លេស 00360114, ភាសាបារាំង 00367806។ ខ្ញុំសូមដកស្រង់៖ “សំណួរ៖ តើការបោសសម្អាតនិងការបាត់ខ្លួននោះភាគច្រើន ជាអ្នក១៧មេសា ឬជាប្រជាជនមូលដ្ឋាន? ឆ្លើយ៖ ភាគច្រើនជាពួក១៧មេសា ប៉ុន្តែអ្នកចូលរួមក៏មានបាត់ខ្លួនដែរ នៅពេលដែលខ្ញុំសួរគេពីការបាត់ខ្លួននេះ គេបានប្រាប់ខ្ញុំថា កិច្ចការគេៗដឹង កិច្ចការខ្ញុំៗដឹង។ ខ្ញុំមិនហ៊ានសួរគេទេ ខ្លាចជាប់ដោយទាំងខ្ញុំទៀត”។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រីទៅលើប្រយោគមួយដែលអ្នកស្រីប្រើថា “កិច្ចការគេៗដឹង កិច្ចការខ្ញុំៗដឹង” ថាតើនេះជាគោលការណ៍ដែលអ្នកស្រីទទួលបានពីណាមក ហេតុអ្វីបានជាមានគោលការណ៍នេះយកមកអនុវត្ត?

[១៥:១២:៥៤]

**លោកស្រី ស៊ូ សឿន៖**

**ឆ៖** ចាស ខ្ញុំក៏មិនថាមានទទួលពីណាទេ គឺវិន័យធ្វើការគឺអ៊ីចឹង យើងមានសិទ្ធិតែត្រឹមថាខ្លួនយើង គ្រប់គ្រងខ្លួនយើងប៉ុណ្ណឹង ប៉ុន្តែយើងការងារផ្សេងទៀត អត់មានសិទ្ធិសួរគេទេ។ ចាស មានប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបានឮសក្ខីកម្មរបស់អ្នកស្រីនៅក្នុងសវនាការរយៈពេល២ថ្ងៃកន្លងមកនេះ ជារឿយៗអំពីថា ការងារគេៗដឹង ការងាររបស់អ្នកស្រីៗដឹង។ ហើយអម្បាញ់មិញនេះ អ្នកស្រីបានបញ្ជាក់អំពីការអនុវត្តនេះផងដែរ ខ្ញុំចង់សួរបន្ថែមថា តើអ្នកស្រីទទួលការអប់រំទាក់ទងទៅនឹងការងារ ដែលថា “ការងារគេៗដឹង ការងារយើងៗដឹង” នេះដែរឬទេ?

**ឆ៖** ចាស សូមប្រធានបញ្ជាក់ម្តងទៀត ដូចខ្ញុំស្តាប់អត់ទាន់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់ថា តើលោកស្រីទទួលការអប់រំក្នុងការអនុវត្តការងារទាក់ទងនឹងថា ការងារគេៗដឹង ការងារយើងៗដឹង ពីថ្នាក់លើ ឬក៏ពីអ្នកណាដែលអ្នកស្រីគិតថាទទួលព័ត៌មានទាក់ទងចំណុចនេះដែរទេ?

**ឆ៖** ចាស រឿងនេះ គឺអប់រំត្រឹមប្រធាន លេខាស្រុក --អំ! លេខាតំបន់។ គឺភារកិច្ចយើងៗដឹង ភារកិច្ចគេៗដឹង ខ្ញុំទទួលត្រឹមតំបន់ កិច្ចការគេៗដឹង កិច្ចការខ្ញុំៗធ្វើការខ្លួនឯងគឺដឹង ខ្ញុំទទួលត្រឹមតំបន់។

[១៥:១៥:២៩]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបន្ថែមថាតើនេះជាគោលនយោបាយរបស់បក្ស ឬមួយជាទម្លាប់អ្វីដែរ អ្នកស្រីអាចជួយពន្យល់បានទេ?

**ឆ៖** ខ្ញុំ -- ចាស ខ្ញុំគ្រង់ហ្នឹងគឺដូចជារឿងថា វាភ្លេចភ្លាំងដែរ វាត្រឹមច្បាប់ចែងត្រឹមតំបន់ ឬក៏យ៉ាងណាក៏ភ្លេចហើយ រកនឹកមិនឃើញបានខ្ញុំបញ្ជាក់អំមិញហ្នឹង នឹកមិនឃើញទេ។

**ស៖** បាទ មិនអីទេអ្នកស្រី។ ខ្ញុំចង់សួរបន្ថែមថា តើនេះជាគោលការណ៍ដែលសមាជិកបក្សរបស់បក្សកុម្មុយនីស្តកម្ពុជាយល់ដឹងជ្រួតជ្រាបជាទូទៅដែរទេ?

**ឆ៖** ដូចរកនឹកនិយាយមិនឃើញ បើជ្រួតជ្រាប -- កំណត់ខ្លួនឯង ក៏កំណត់មិនបាន ដូច្នេះទៅកំណត់អ្នកដទៃក៏មិនបាន ខ្លួនឯងគឺកំណត់មិនបានអារម្មណ៍ ក៏គិតថាចាំមិនបាន កំណត់មិនបាន ។ សូមអត់ទោសចុះ។

**ស៖** បាទ មិនថ្វីទេ តែគ្រាន់តែខ្ញុំចង់បញ្ជាក់បន្តិចថា សំណួររបស់ខ្ញុំហ្នឹងគឺទាក់ទងទៅនឹងគោលការណ៍ដែលថា "ការងារគេៗដឹង ការងារយើងៗដឹង" ថាតើគោលការណ៍បែបនេះ មានការយល់ដឹងជាទូទៅដែរទេ ឬក៏មានតែអ្នកស្រីទេដែលដឹង ហើយអ្នកដទៃទៀតមិនបានដឹងពីគោលការណ៍បែបហ្នឹង?

[១៥:១៧:៤៣]

**ឆ៖** ចាស ឲ្យខ្ញុំឆ្លើយជំនួសថាអ្នកដទៃគេយល់ដូចខ្ញុំ ខ្ញុំកំណត់មិនបានទេ កំណត់តែខ្លួនខ្ញុំក៏កំណត់មិនបានផង ទៅកំណត់អ្នកដទៃម៉េចបាន បើវាមិនចងចាំ។

**ស៖** បាទ សូមអរគុណ។ កាលពីម្សិលមិញ ម៉ោង ១៤:១១:២៩ នៅក្រោមហ្នឹងបន្តិច អ្នកស្រីបានឆ្លើយនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងលោក ខៀវ សំផន ដែលអ្នកស្រី

ឆ្លើយថាថ្នាក់លើរបស់ប្ដីអ្នកស្រី គឺមានឈ្មោះមួយចំនួនរាប់បញ្ចូលទាំងលោក ខៀវ សំផន ផងក្នុងនោះ។ ខ្ញុំចង់សួរថា តើអ្នកស្រីដឹងថាលោក ខៀវ សំផន ជាថ្នាក់លើរបស់ប្ដីអ្នកស្រីដោយរបៀបណា?

**ផ៖** ចាស ខ្ញុំដឹងថាថ្នាក់លើពីបងៗខាងលើមកដល់ក្រោម គឺដឹងតាមរយៈគ្រួសារដែលរៀបចំគណៈភូមិភាគហៅកម្មាភិបាលទៅធ្វើការនៅតាមភូមិភាគ ដូច្នេះការណ៍ហ្នឹងក៏ផ្សព្វផ្សាយទៅតាមហ្នឹងទៅ ហើយវែងឆ្ងាយទៀត ខ្ញុំអត់ចាំទេ ចាំតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីមានដឹងពីការងាររបស់ប្ដីរបស់អ្នកស្រីដែលត្រូវធ្វើសេចក្ដីរាយការណ៍ទៅលោក ខៀវ សំផន ដែរទេ?

**ផ៖** ចាស ម៉េចខ្ញុំត្រូវដឹង ព្រោះការងារខ្ញុំបានលើកហើយតើ! ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថាការងារគាត់ៗដឹង ការងារខ្ញុំៗដឹង។ បើភូមិភាគផ្សាយថា ឥឡូវរៀបចំកម្លាំងកម្មាភិបាលត្រឹមណា អ្នកទទួលបានត្រឹមហ្នឹង។ ការងារគាត់ខ្ញុំមិនដឹងទេ។

[១៥:២០:៣២]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីដឹងពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ផ៖** ចាស ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីដឹងពីសមាជិកភាពរបស់ប្ដីលោកស្រីក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ផ៖** ចាស ខ្ញុំមិនដឹងទេ ព្រោះមិនយល់រឿងសមាជិកភាពយ៉ាងម៉េចផង។

**ស៖** បាទ សមាជិកភាពដែលខ្ញុំនិយាយនៅពេលនេះ គឺសំដៅដល់ឋានៈនៅក្នុងជួរបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា។ អ្នកស្រីយល់បានទេ?

**ផ៖** ចាស ខ្ញុំអត់យល់ទេ។

**ស៖** បាទ សូមអរគុណ។ ចុះលោកស្រីធ្លាប់ស្គាល់លោក ខៀវ សំផន ពីមុនមកទេ? ពីសម័យអាចថា មុន៧៥?

**ផ៖** ខ្ញុំអត់ដែលស្គាល់គាត់ផង។

**ស៖** បាទ សូមអរគុណ។ ចុះក្រោយឆ្នាំ៧៥ អ្នកស្រីដឹង ខ្ញុំចង់និយាយពីឆ្នាំ៧៥ ដល់ឆ្នាំ១៩៧៩ អ្នកស្រីដឹងពីឋានៈរបស់លោក ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរទេ?

**ផ៖** ចាស ពេលនោះ ខ្ញុំអត់ដឹងគាត់យ៉ាងម៉េចទេ ខ្ញុំមិនសូវដឹងដែរហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបែងចែកដាច់ដោយឡែកពីគ្នារវាងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងថ្នាក់ដឹកនាំរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យបានទេ?

**ឆ៖** ចាស ខ្ញុំស្ដាប់អត់បានទេ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីបានបញ្ជាក់អំពីថា ថ្នាក់លើរបស់ប្ដីអ្នកស្រី ដែលមានឈ្មោះលោក ខៀវ សំផន នេះ តាមការរៀបរាប់របស់អ្នកស្រី ការផ្ដល់សក្ខីកម្មបែបនេះរបស់អ្នកស្រីផ្អែកលើមូលដ្ឋានអ្វីពិតប្រាកដ អ្នកស្រីអាចបញ្ជាក់បានទេ?

[១៥:២៤:៤៧]

**ឆ៖** ចាស ខ្ញុំសម្គាល់ឃើញថា ស្គាល់គាត់ពេលទៅជួបគ្នានៅក្នុងព្រៃឃើញការទាក់ទងគាត់ធ្វើការជាមួយនឹងបង ខៀវ សំផន តែការងារអ្វី គឺខ្ញុំស្ដាប់មិនបានទេ។

**ស៖** បាទ សូមអរគុណ។ ការសម្គាល់ឃើញរបស់អ្នកស្រីនៅក្នុងព្រៃ តើអ្នកស្រីចង់សំដៅនៅក្នុងអំឡុងពេលណា អ្នកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស ខ្ញុំបញ្ជាក់មិនបានទេ ខ្ញុំអង្គុយគិតថា ភ្លេចហើយ ពេលណា ឆ្នាំណា ខ្ញុំអត់ចាំ។

**ស៖** លោកស្រីបញ្ជាក់អំពីពេលវេលាទាក់ទងថា ក្រោយឆ្នាំ៧៩ – ឆ្នាំ១៩៧៩ ឬក៏មុនឆ្នាំ១៩៧៩ អ្នកស្រីអាចធ្វើការបែងចែកចំណុចហ្នឹងបានទេ?

**ឆ៖** ចាស ខ្ញុំដូចជាភ្លេចហើយ រកនឹកមិនឃើញ។ មិនដឹងមុន៧៩ ក្នុងអំឡុង៧៦-៧៧អី មិនបានចាប់អារម្មណ៍ទេ ភ្លេចហើយ រកនឹកមិនឃើញ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណអ្នកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃអង្គារ ទី០៩ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃអង្គារ ដើមសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-975 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៥:២៦:៥៨]

អង្គជំនុំជម្រះអរគុណលោកស្រី ស៊ូ សឿន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សី ក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

ការផ្តល់សក្ខីកម្មរបស់លោកស្រីបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ ហើយមានសេចក្តីសុខ សេចក្តីចម្រើន និងធ្វើដំណើរវិលត្រឡប់ទៅវិញ ប្រកបដោយសុវត្ថិភាព។

អង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយគាំទ្រកិច្ចដំណើរការក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី ស៊ូ សឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅថ្ងៃអង្គារទី០៩ ខែមិថុនា ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:២៨ នាទី)*